# រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រកៀរគរចំណូល

## របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា

ខែមករា ឆ្នាំ២០២៥

# បុព្វកថា

ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព ស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចដែលជាសមិទ្ធផលដ៏ថ្លៃថ្លាសម្រាប់រយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចរីកលូតលាស់លឿន ជាមួយអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមជាង៧%ក្នុងមួយឆ្នាំនៅមុនវិបត្តិកូវីដ១៩។ សមិទ្ធផលនេះសម្រេចបានតាមរយៈការអនុវត្តនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ព្រមទាំងកម្មវិធីកែទម្រង់ផ្សេងៗជាបន្តបន្ទាប់ប្រកបដោយស្មារតីបុរេសកម្មនិងការទទួលខុសត្រូវខ្ពស់ ក្នុងការលើកកម្ពស់ភាពប្រកួតប្រជែងនិងការធ្វើពិពិធកម្មសេដ្ឋកិច្ច។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញឱ្យអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលចំនួន២ដំណាក់កាលរួចមកហើយគឺ **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨** និង **យុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣** ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលចូលរួមចំណែកកសាងនូវមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការប្រមូលចំណូលដែលកំពុងឈានទៅរកកម្រិតឧត្តមានុពលតាមរយៈសមិទ្ធផលនិងវឌ្ឍនភាពនានានៃការកែទម្រង់ស្ថាប័ន ការលើកកម្ពស់អភិបាលកិច្ច ការអភិវឌ្ឍសមត្ថភាពមន្ត្រីជាពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ និងការបញ្ជ្រាបការយល់ដឹងជូនដល់ប្រជាពលរដ្ឋអំពីច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ព្រមទាំងកិច្ចសម្របសម្រួលអន្តរក្រសួង-ស្ថាប័ន ក្នុងការគ្រប់គ្រងការប្រមូលចំណូល។ យុទ្ធសាស្ត្រកៀរគរចំណូលទាំង២ដំណាក់កាលនេះក៏បានរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងទី៤** និងកម្មវិធីគោលនយោបាយនានាដែលផ្តល់នូវលទ្ធភាពគ្រប់គ្រាន់ដល់រាជរដ្ឋាភិបាល ក្នុងការបែងចែកធនធានទៅតាមគោលដៅអាទិភាពប្រកបដោយប្រសិទ្ធភាព និងភាពទុកចិត្តបាននៃថវិកា។ បន្ថែមពីនេះ រាជរដ្ឋាភិបាលក៏បន្តពង្រឹងអភិបាលកិច្ចនៃស្ថាប័នសាធារណៈ រក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ បង្កើតការងារសមរម្យជូនប្រជាពលរដ្ឋ ពង្រីកនិងលើកកម្ពស់គុណភាពសេវាសាធារណៈដូចជា វិស័យអប់រំ សុខាភិបាល និងសេវាមូលដ្ឋានចាំបាច់ផ្សេងទៀតដែលធានាបាននូវសន្តិសុខនិងសុខុមាលភាពជូនដល់ប្រជាជនទោះបីស្ថិតក្នុងបរិការណ៍ណាក្តី។

**យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ជាកិច្ចការងារបន្តក្នុងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈមួយដំណាក់កាលទៀតដើម្បីធានាឱ្យបាននូវចីរភាពកំណើនសេដ្ឋកិច្ច ធានាឱ្យបាននូវយុត្តិធម៌និងសមធម៌ក្នុងការបង់ពន្ធ និងបន្តធានាឱ្យបាននូវកំណើនចំណូល និងប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល សំដៅឆ្លើយតបទៅនឹងតម្រូវការចំណាយក្នុងការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយប្រកាន់ខ្ជាប់នូវអភិក្រមចំនួន ៥ គឺ ១)-ធានាកំណើនសេដ្ឋកិច្ច បង្កើតបរិយាកាសអំណោយផលដល់សកម្មភាពសេដ្ឋកិច្ច និងជំរុញសកម្មភាពពាណិជ្ជកម្ម ២)-មិនបង្កើតប្រភេទពន្ធថ្មីនិងមិនដំឡើងអត្រាពន្ធអាករលើកលែងតែអាករពិសេសលើទំនិញនិងសេវាដែលប៉ះពាល់ដល់សុខភាពរបស់ប្រជាជន សង្គម និងបរិស្ថាន បន្តការអនុវត្តគោល-នយោបាយលើកទឹកចិត្តមានស្រាប់ដែលចំគោលដៅនិងមានវិចារណកម្ម និងធានាយន្តការប្រមូលពន្ធមិនឱ្យត្រួតគ្នា ៣)-ពង្រឹងយន្តការឆ្លើយតបជាមួយអ្នកជាប់ពន្ធតាមរយៈការប្រើប្រាស់បច្ចេកវិទ្យានិងការពង្រឹងក្រមប្រតិបត្តិមន្ត្រីប្រមូលចំណូល ៤)-រៀបចំវិធានការដែលមានលក្ខណៈយុទ្ធសាស្ត្រមុតស្រួចនិងមានចំនួន

តិចដែលមានចរិតបង្កើតចំណូល ប៉ុន្តែមិនបង្កឱ្យមានវិការភាពសេដ្ឋកិច្ច (economic distortion) និងជានាបាននូវសមធម៌ (equity) និងយុត្តិធម៌ក្នុងការបង់ពន្ធ និង ៥)-ជំរុញការចូលរួមពីវិស័យឯកជនដើម្បីជានាឱ្យបាននូវទស្សនរួម ភាពគ្រប់ជ្រុងជ្រោយនៃវិធានការ និងភាពជាក់ស្តែងនិយមដែលផ្សារភ្ជាប់ទៅនឹង**ចក្ខុវិស័យ**ប្រែក្លាយប្រព័ន្ធចំណូលរដ្ឋឱ្យកាន់តែទំនើប មានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយសុភបរមាដែលអាចឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍនិងការវិវឌ្ឍនៃរចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ចជាតិ។

ឈរលើមូលដ្ឋាននេះ **យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** នឹងបន្តដើរតួនាទីជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចកម្ពុជាយ៉ាងសំខាន់ តាមរយៈការចាប់យកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាចាំបាច់នានា ពិសេសបច្ចេកវិទ្យាព័ត៌មាន និងការតម្រង់ទិសឆ្ពោះទៅរកបរិវត្តកម្មរដ្ឋបាលសារពើពន្ធឌីជីថលឱ្យកាន់តែមានភាពស្អាតស្អំ ឆ្លាតវៃ ប្រកបដោយសមត្ថភាព និងការបន្តធ្វើវិចារណកម្មគោលនយោបាយសារពើពន្ធនិងមិនមែនសារពើពន្ធ ដើម្បីសម្រេចឱ្យបាននូវឋានៈប្រទេសមានចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០។ ទន្ទឹមនេះ យុទ្ធសាស្ត្រនេះមានគោលបំណងពង្រឹងការប្រមូលចំណូលឱ្យកាន់តែប្រសើរដោយមានការថ្លឹងថ្លែង បន្តរក្សាចលនការនិងសម្ទុះនៃសេដ្ឋកិច្ច ព្រមទាំងផ្តល់នូវភាពត្រឹមត្រូវ តម្លាភាព និងភាពយុត្តិធម៌ដល់អ្នកបង់ពន្ធដោយផ្តោតលើចំណូលសក្តានុពលនិងមិនបង្កផលវិបាកអវិជ្ជមានដល់សេដ្ឋកិច្ច។ ដើម្បីសម្រេចឱ្យបាននូវគោលបំណងខាងលើ យុទ្ធសាស្ត្រនេះបានកំណត់គោលដៅ ប្រមូលចំណូលឱ្យអស់សក្តានុពល រួមទាំងលើកកម្ពស់ស័ក្តិសិទ្ធិភាពនៃប្រព័ន្ធប្រមូលចំណូលរដ្ឋទាំងមូលដោយ ១)- រក្សានិងជំរុញការប្រមូលចំណូលចរន្តឱ្យបានដល់ក្នុងរង្វង់**១៦%** នៃផ.ស.ស. នៅពេលកំណើនសេដ្ឋកិច្ចត្រឡប់មកកាន់គន្លងសក្តានុពលវិញ ២)- ធានាឱ្យបាននូវភាពច្បាស់លាស់ ភាពត្រឹមត្រូវនៃប្រព័ន្ធពន្ធ និងភាពអាចព្យាករណ៍បាននៃការផ្លាស់ប្តូរ និង ៣)- បន្តពង្រីកវិសាលភាពនិងពង្រឹងគុណភាពប្រព័ន្ធចំណូលមិនមែនសារពើពន្ធ។

តាងនាមឱ្យរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះការខិតខំប្រឹងប្រែងទាំងកម្លាំងកាយនិងកម្លាំងចិត្តរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលទាំង២ដំណាក់កាលកន្លងមកប្រកបដោយជោគជ័យ។ ខ្ញុំសង្ឃឹមថាមន្ត្រីរដ្ឋាភិបាលទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនៅគ្រប់ក្រសួង-ស្ថាប័ន ព្រមទាំងតួអង្គដែលពាក់ព័ន្ធទាំងអស់នឹងចូលរួមគាំទ្រដោយពេញទំហឹងនិងបន្តខិតខំប្រឹងប្រែងអនុវត្តយុទ្ធសាស្ត្រនេះប្រកបដោយសុច្ឆន្ទៈ បុរេសកម្ម អន្តរសកម្ម និងស្មារតីទទួលខុសត្រូវខ្ពស់។ ជាទីចុងបញ្ចប់ ខ្ញុំសូមអនុម័តនិងប្រកាសដាក់ឱ្យអនុវត្តនូវ **យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ចាប់ពីពេលនេះតទៅ។

ថ្ងៃ សុក្រ ៤កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែមករា គ.ស. ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# មាតិកា


**ជំពូកទី១ សេចក្តីផ្តើម** ........ ១

**ជំពូកទី២ វិធានការគោលនយោបាយដែលបាននិងកំពុងអនុវត្តក្នុងឆ្នាំ២០២៤** ........ ៥

**ជំពូកទី៣ ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ........ ៨

៣.១. ចក្ខុវិស័យ ........ ៨

៣.២. គោលបំណង និងគោលដៅ ........ ៨

៣.៣. អភិក្រមនៃការរៀបចំយុទ្ធសាស្ត្រ ........ ៩

**ជំពូកទី៤ ការធ្វើទំនើបភាវូបនីយកម្ម រដ្ឋបាលសារពើពន្ធ** ........ ៩

៤.១. ការធ្វើទំនើបភាវូបនីយកម្ម នៃអគ្គនាយកដ្ឋានពន្ធដារ ........ ៩

ក. ក្របខ័ណ្ឌអភិបាលកិច្ច និងស្ថាប័ន ........ ១០

ខ. មុខងារស្នូល ........ ១១

គ. មុខងារគាំទ្រ ........ ១៤

៤.២. ការធ្វើទំនើបភាវូបនីយកម្ម នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ........ ១៦

ក. កិច្ចសម្រួលពាណិជ្ជកម្ម ........ ១៦

ខ. ការពង្រឹងអភិបាលកិច្ច និងស្ថាប័ន ........ ១៩

គ. មុខងារគាំទ្រ ........ ២០

**ជំពូកទី៥ ការធ្វើទំនើបកម្ម និងវិចារណកម្មគោលនយោបាយពន្ធ** ........ ២២

៥.១ ពន្ធលើប្រាក់ចំណូល ........ ២២

៥.២ ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ........ ២៤

៥.៣ អាករពិសេស ........ ២៤

៥.៤. អាករលើតម្លៃបន្ថែម ........ ២៥

៥.៥. ពន្ធពាក់ព័ន្ធនឹងអចលនទ្រព្យ ........ ២៧

៥.៦. ការគ្រប់គ្រងចំណាយសារពើពន្ធ ........ ២៨

៥.៧. ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ........ ២៩

៥.៨. ពន្ធក្នុងវិស័យល្បែងពាណិជ្ជកម្ម ........ ៣១

៥.៩. ពន្ធលើសេវាកម្មឌីជីថល ........ ៣១

៥.១០. ពន្ធលើការបំភាយកាបូន ........ ៣២

**ជំពូកទី៦ ការពង្រឹងរដ្ឋបាល និងគោលនយោបាយចំណូលមិនមែនសារពើពន្ធ** ........ ៣៣

៦.១ ការពង្រឹងអភិបាលកិច្ច និងស្ថាប័ននៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ........ ៣៤

៦.២. ការពង្រឹងមុខងារស្នូលក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ ........ ៣៦

ក. ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ........ ៣៧

ខ. ចំណូលពីសហគ្រាសសាធារណៈ ........ ៣៩

គ. ចំណូលពីសេវាសាធារណៈ ....................................................................................... ៤០
ឃ. ចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្ម ........................................................................ ៤១
ង. ចំណូលមិនមែនសារពើពន្ធដទៃទៀត ............................................................................. ៤២
៦.៣. ការពង្រឹងមុខងារគាំទ្រការគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ ........................................ ៤៣
**ជំពូកទី៧ ការគ្រប់គ្រងហានិភ័យ** ............................................................................. ៤៦
**ជំពូកទី៨ ការត្រួតពិនិត្យ និងវាយតម្លៃ** ........................................................................ ៤៨
**ជំពូកទី៩ សេចក្តីសន្និដ្ឋាន** .................................................................................. ៥០
**បរិសិដ្ឋ** ........................................................................................................ ៥២

# ជំពូកទី១
# សេចក្តីផ្តើម

ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់រាជរដ្ឋាភិបាលរយៈពេលជាង២ទសវត្សរ៍កន្លងមកតាមរយៈការអនុវត្ត **«នយោបាយឈ្នះ-ឈ្នះ»** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** កម្ពុជាទទួលបានសុខសន្តិភាពពេញលេញនៅទូទាំងប្រទេសរួមទាំងសម្រេចបាននូវការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាទីមោទកៈ ធានាបាននូវចីរភាពកំណើនសេដ្ឋកិច្ចក្នុងអត្រាខ្ពស់ជាមធ្យមប្រមាណជាង ៧% ក្នុងមួយឆ្នាំ កាត់បន្ថយភាពក្រីក្រនិងវិសមភាពសង្គមជាបន្តបន្ទាប់ និងទទួលបានឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ លើសពីនេះ ការដាក់ចេញនិងអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលទាំង២ ដំណាក់កាល មិនគ្រាន់តែបានបង្កើនចំណូលរដ្ឋជារួមទេ ថែមទាំងបានប្រែក្លាយប្រព័ន្ធចំណូលកម្ពុជាឱ្យមានលក្ខណៈទំនើប និងកាន់តែប្រហាក់ប្រហែលទៅនឹងការអនុវត្តជាអន្តរជាតិ។

នាអាណត្តិថ្មីនីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** ដើម្បីធានាបាននូវកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅបន្តរក្សាឱ្យបានរឹងមាំនូវចលនការនៃសុខសន្តិភាពនិងជំរុញសម្ទុះនៃការអភិវឌ្ឍប្រទេសជាតិក្នុងរយៈពេលមធ្យមនិងវែងទៅមុខ តាមរយៈការកែទម្រង់មុតស្រួចលើគ្រប់វិស័យ ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជាពោលគឺក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ជាមួយនឹងការវិវឌ្ឍនៃស្ថានភាពសង្គមសេដ្ឋកិច្ចនិងការត្រៀមចាកចេញពី **ក្រុមបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច** (Least Developed Countries - LDCs) ចំណូលថវិកាជាតិនឹងដើរតួជាប្រភពហិរញ្ញប្បទានកាន់តែសំខាន់ សម្រាប់ធានាការសម្រេចបាននូវចក្ខុវិស័យប្រកបដោយមហិច្ឆតានេះ។ ក្នុងបរិការណ៍នេះ ការបន្តអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូល ដែលស្ថិតក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** នៅតែជាកិច្ចការកែទម្រង់ស្នូលមួយនៅក្នុងចំណោមកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីធានាឱ្យបាននូវចីរភាពកំណើនសេដ្ឋកិច្ច រក្សាបានចលនការនៃការប្រមូលចំណូល ធានានូវយុត្តិធម៌និងសមធម៌សម្រាប់អ្នកបង់ពន្ធ ព្រមទាំងជាមូលដ្ឋានសម្រាប់បន្តធានាប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល ដើម្បីឆ្លើយតបទៅនឹងតម្រូវការចំណាយរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**។

ក្រោយរាជរដ្ឋាភិបាលបានដាក់ចេញនិងអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលទាំង ២ ដំណាក់កាលកន្លងមកពោលគឺចាប់តាំងពីឆ្នាំ២០១៤ ការប្រមូលចំណូលចរន្ត ដោយក្នុងនោះមានចំណូលសារពើពន្ធ (ចំណូលពន្ធដារនិងពន្ធគយ) និងចំណូលមិនមែនសារពើពន្ធមានការកើនឡើង និងមានភាពធន់ គួរឱ្យកត់សម្គាល់ ទោះបីជាកម្ពុជាបានទទួលរងឥទ្ធិពលពីភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល ជាច្រើនឆ្នាំ ដែលបណ្តាលមកពីស្លាកស្នាមនៃវិបត្តិកូវីដ១៩ ការផ្ទុះឡើងនូវសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន សង្គ្រាមនៅមជ្ឈិមបូព៌ា គួបផ្សំជាមួយនឹងការផ្លាស់ប្តូរយ៉ាងគំហុកនៃគោលនយោបាយរូបិយវត្ថុសកល និងគោលនយោបាយហិរញ្ញវត្ថុ

សាធារណៈក្នុងបណ្តាប្រទេសធំៗ ។ ជាក់ស្តែង ចំណូលចរន្តសរុបបានកើនឡើងពី១៥,១% នៃផ.ស.ស.ក្នុងឆ្នាំ២០១៣ រហូតដល់២០,៧% នៃផ.ស.ស.ក្នុងឆ្នាំ២០២៣ ដោយប្រើប្រាស់ផ.ស.ស.ឆ្នាំគោលចាស់ (ឬកើនឡើងពី១១,៦% នៃផ.ស.ស.ក្នុងឆ្នាំ២០១៣ ដល់១៥,៣% នៃផ.ស.ស.ក្នុងឆ្នាំ២០២៣ ដោយប្រើប្រាស់ផ.ស.ស.ឆ្នាំគោលថ្មី)។ បន្ថែមពីនេះ រាជរដ្ឋាភិបាលបានបន្តធ្វើការកែទម្រង់រដ្ឋបាលប្រមូលចំណូលតាមរយៈការធ្វើទំនើបកម្មប្រព័ន្ធប្រមូលចំណូល កែលម្អការគ្រប់គ្រងចំណូល ពង្រឹងអភិបាលកិច្ចរបស់ស្ថាប័នអនុវត្ត ពង្រឹងអនុលោមភាពរបស់អ្នកជាប់ពន្ធនិងធុរជន និងបង្កើនគុណភាពសេវារដ្ឋបាលចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធឱ្យកាន់តែមានប្រសិទ្ធភាព រួមមាន ការអនុវត្តការចុះបញ្ជី ការដាក់លិខិតប្រកាសពន្ធ និងការបង់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក ការដាក់ឱ្យអនុវត្តនូវថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ការបន្តធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីគយលើការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ការអនុវត្តប្រព័ន្ធ e-Customs និងមុខងារប្រតិវេទន៍គយក្នុងប្រព័ន្ធ ASYCUDA និងការប្រើប្រាស់ប្រព័ន្ធ NRMIS និង SARMIS ដើម្បីគ្រប់គ្រងទិន្នន័យចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋជាដើម។ រាជរដ្ឋាភិបាលក៏បានធ្វើវិចារណកម្មគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធពាក់ព័ន្ធជាបន្តបន្ទាប់ ដូចជាការរៀបចំក្របខ័ណ្ឌគោលនយោបាយសម្រាប់ត្រៀមអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ការរៀបចំគោលការណ៍ណែនាំស្តីពីការកែទម្រង់អាករពិសេស២០២៤-២០២៨ ការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាជាដើម។ ការកែទម្រង់ទាំងអស់នេះបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការរក្សាបាននូវការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធក្នុងកម្រិតខ្ពស់ និងប្រកបដោយភាពធន់ ជាពិសេសក្នុងបរិការណ៍ដែលកម្ពុជានិងសកលលោកបានជួបប្រទះនឹងបញ្ហាប្រឈមផ្សេងៗគ្នាជាបន្តបន្ទាប់ ។

ទោះបីជាការកែទម្រង់ប្រព័ន្ធពន្ធកម្ពុជាមានវឌ្ឍនភាពប្រសើរក្តី ក៏ពុំទាន់មានលក្ខណៈពេញលេញ និងមានភាពធន់គ្រប់គ្រាន់ទៅនឹងបម្រែបម្រួលនៃបរិការណ៍សកលដែលនៅបន្តមានភាពមិនប្រាកដប្រជាខ្ពស់និងពុំទាន់អាចសម្របបានល្អទៅតាមការផ្លាស់ប្តូររចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចនៅឡើយ។ កម្ពុជាបន្តពឹងផ្អែកខ្លាំងលើពន្ធប្រយោល (Indirect tax) ជាជាងពន្ធផ្ទាល់ (Direct tax) និងពុំទាន់អាចកៀរគរចំណូលពីការអនុវត្តពន្ធដែលមានស្រាប់និងពង្រីកមូលដ្ឋានគិតពន្ធឱ្យអស់សក្តានុពលនៅឡើយទេ ជាពិសេសសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលនៅមានកម្រិតខ្ពស់។ បន្ថែមពីនេះ ការបន្តកើនឡើងនៃចំណាយសារពើពន្ធតាមរយៈការលើកទឹកចិត្តផ្សេងៗនិងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី បានធ្វើឱ្យរិចរិលដល់មូលដ្ឋានគិតពន្ធជាបន្តបន្ទាប់។ ជាក់ស្តែង ចំណែកនៃចំណូលពន្ធប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានការថមថយពោលគឺចំណែកពន្ធប្រយោលលើការនាំចូលនៃចំណូលពន្ធសរុបថមថយពី៤០,៩% ក្នុងឆ្នាំ២០១៨ មកត្រឹម២៨% ក្នុងឆ្នាំ២០២៣ ខណៈចំណែកពន្ធពាណិជ្ជកម្មអន្តរជាតិនៃចំណូលពន្ធសរុបធ្លាក់ចុះពី១២,៦% ក្នុងឆ្នាំ២០១៨ មកត្រឹម១០,៦% ក្នុងឆ្នាំ២០២៣។ រីឯចំណែកនៃចំណូលពន្ធប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារបានកើនឡើងជាបន្តបន្ទាប់ពោលគឺពីប្រមាណ២១,៥% ក្នុងឆ្នាំ២០១៨ ទៅដល់៣៤,៨% ក្នុងឆ្នាំ២០២៣ ខណៈចំណែកពន្ធប្រយោលក្នុងស្រុក (អាករលើតម្លៃបន្ថែមនិងអាករពិសេស) នៃចំណូលពន្ធសរុបបានកើនឡើងពីអត្រាប្រមាណ១៦,៦% ក្នុងឆ្នាំ២០១៨ ទៅដល់១៨,៣% ក្នុងឆ្នាំ២០២៣។ លទ្ធផលនេះសបញ្ជាក់ពី

និន្នាការដែលផ្លាស់ប្ដូរពីការពឹងផ្អែកលើចំណូលពីការនាំចូល មកពឹងផ្អែកលើចំណូលពីសកម្មភាពក្នុងស្រុក ដែលបាននិងកំពុងរីកលូតលាស់គួរឱ្យកត់សម្គាល់។ ដូចនេះ ការបន្តកែលម្អប្រព័ន្ធសារពើពន្ធឱ្យស្របតាម ឧត្តមានុវត្តន៍អន្តរជាតិនឹងចូលរួមចំណែកដល់ការរក្សាស្ថិរភាពចំណូល ការប្រមូលពន្ធប្រកបដោយសមធម៌និង ការពង្រីកមូលដ្ឋានគិតពន្ធ។ កិច្ចការងារសំខាន់ទាំងនេះត្រូវបន្តផ្ដោតការយកចិត្តទុកដាក់នៅក្នុងយុទ្ធសាស្ត្រ កៀរគរចំណូលដំណាក់កាលបន្តបន្ទាប់ខាងមុខ។

បន្ថែមលើនេះ រដ្ឋបាលប្រមូលចំណូលនៅតែបន្តជួបបញ្ហាប្រឈមមួយចំនួនដែលជារនាំងដល់កិច្ចការ របស់រាជរដ្ឋាភិបាល ក្នុងការប្រមូលចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធឱ្យអស់សក្ដានុពល។ ជាក់ស្ដែង អគ្គនាយកដ្ឋានពន្ធដារនៅបន្តជួបបញ្ហាប្រឈមចម្បងៗដូចជា ការបន្តកើតមាននូវសកម្មភាពគេចវេះនិងបន្លំ ពន្ធដែលមានលក្ខណៈជាប្រព័ន្ធនិងស្មុគស្មាញ ភាពមានកម្រិតនៃកិច្ចសហការជាមួយអ្នកជាប់ពន្ធនិងមន្ត្រី លើការដោះស្រាយបំណុលនិងការស៊ើបអង្កេតបទល្មើសផ្សេងៗ ភាពមានកម្រិតនៃការយល់ដឹងរបស់អ្នក ជាប់ពន្ធលើកាតព្វកិច្ចអនុលោមភាពពន្ធដារ ព្រមទាំងភាពយឺតយ៉ាវក្នុងការដោះស្រាយវិវាទពន្ធដារ ការធ្វើ សវនកម្ម និងដំណើរការបង្វិលសងអាករលើតម្លៃបន្ថែម។ ចំណែកឯអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក៏នៅបន្តជួបបញ្ហាប្រឈមមួយចំនួនដូចជា ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមិនទាន់ត្រូវបានធ្វើសមាហរណកម្ម និងសន្ទានកម្មពេញលេញ និងពុំទាន់ឆ្លើយតបបានគ្រប់គ្រាន់នៅឡើយទៅនឹងការវិវឌ្ឍថ្មីៗនៃបច្ចេកវិទ្យានិង ពាណិជ្ជកម្មអន្តរជាតិ ដែលធ្វើឱ្យនីតិវិធីគយមួយចំនួនបន្តមានភាពស្មុគស្មាញនិងចំណាយរយៈពេលយូរ ភាពមានកម្រិតនៃយន្តការវាយតម្លៃប្រសិទ្ធភាព និងការអនុវត្តការងាររបស់មន្ត្រីនៅតាមប៉ុស្តិ៍គយនិងច្រកនាំ ចូល និងភាពមានកម្រិតនៃកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ។ មិនខុសគ្នាទៅនឹងរដ្ឋបាលប្រមូល ចំណូលសារពើពន្ធដែរ ក្រសួង-ស្ថាប័នទទួលបន្ទុកអនុវត្តកិច្ចការប្រមូលចំណូលមិនមែនសារពើពន្ធនៅបន្ត ជួបបញ្ហាប្រឈមមួយចំនួន ដូចជាភាពមានកម្រិតនៃសមត្ថភាពមន្ត្រីទទួលបន្ទុកការប្រមូលនិងគ្រប់គ្រង ចំណូល ភាពមានកម្រិតនៃកិច្ចសហការរវាងក្រសួង-ស្ថាប័នអនុវត្តទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិពាក់ព័ន្ធ នឹងការរៀបចំលិខិតបទដ្ឋានគតិយុត្តលើការចាត់ចែងប្រភេទចំណូលសារពើពន្ធ ពិសេសលើយន្តការតាមដាន និងវាយតម្លៃ ហើយម្យ៉ាងទៀតប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យលើការអនុវត្តរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក៏ពុំ ទាន់អនុវត្តបានទូលំទូលាយនៅឡើយ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ចេញនូវ **យុទ្ធសាស្ត្រកៀរគរចំណូលរបស់ រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ដោយបានកំណត់ចក្ខុវិស័យ គោលបំណង គោលដៅ និង អភិក្រមច្បាស់លាស់ ស្របជាមួយនឹងការដាក់ចេញនូវវិធានការគន្លឹះសម្រាប់ការធ្វើទំនើបភាវូបនីយកម្ម រដ្ឋបាលសារពើពន្ធនិងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ និងការធ្វើវិចារណកម្មគោលនយោបាយពន្ធ ដោយកំណត់នូវសូចនាករសមិទ្ធកម្មនិងសកម្មភាពគន្លឹះសម្រាប់ការតាមដាននិងវាយតម្លៃ ដើម្បីធានាឱ្យ បាននូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ។ ក្នុងដំណាក់កាលថ្មីនេះ **យុទ្ធសាស្ត្រ កៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** នឹងបន្តដោះស្រាយបញ្ហាប្រឈម ដោយផ្ដោតលើការងារចម្បងចំនួន ៨ ដូចខាងក្រោម៖

- **ទី១** បន្តធ្វើទំនើបកម្មនិងពង្រឹងអភិបាលកិច្ចនិងស្ថាប័ន តាមរយៈការវិភាគមុខងារនិងកែសម្រួលរចនាសម្ព័ន្ធ ការពង្រឹងចំណេះដឹងនិងក្រមប្រតិបត្តិវិជ្ជាជីវៈរបស់មន្ត្រី និងការប្រើប្រាស់បច្ចេកវិទ្យាចាំបាច់ពិសេសបច្ចេកវិទ្យាឌីជីថល
- **ទី២** ធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធជំនាន់២បូក (Tax Administration 2 Plus) និងឈានឆ្ពោះទៅរដ្ឋបាលសារពើពន្ធជំនាន់៣ (Tax Administration 3.0) ដែលមានលក្ខណៈទំនើបនិងផ្តល់សេវាជូនដល់អ្នកជាប់ពន្ធកាន់តែងាយស្រួល
- **ទី៣** បន្តធ្វើសមាហរណកម្មនិងសន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឱ្យបានពេញលេញ ធ្វើសាមញ្ញកម្មនិងឌីជីថលូបនីយកម្មនីតិវិធីគយ និងបំពាក់ឧបករណ៍បច្ចេកវិទ្យាកាន់តែទំនើប សំដៅសម្រួលដល់រំហូរពាណិជ្ជកម្ម បង្កើនភាពប្រកួតប្រជែង និងពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល
- **ទី៤** រៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រទិន្នន័យចាំបាច់និងធនធានមនុស្ស ដើម្បីចាប់ផ្តើមអនុវត្តពន្ធចំនួន ២ ប្រភេទដែលមានស្រាប់ក្នុងច្បាប់ស្តីពីសារពើពន្ធជាធរមានរួមមានពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គលនិងពន្ធលើចំណេញមូលធន
- **ទី៥** បន្តកែទម្រង់អាករពិសេស ស្របតាមគោលការណ៍ណែនាំស្តីពីការកែទម្រង់អាករពិសេស ២០២៤-២០២៨
- **ទី៦** ពិនិត្យឡើងវិញនូវចំណាយសារពើពន្ធ (Tax Expenditure) ដែលកើនឡើងជាបន្តបន្ទាប់
- **ទី៧** បន្តចូលរួមអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការបង្កលក្ខណៈងាយស្រួលដល់ការឈានចូលក្នុងតំបន់នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឬប្រព័ន្ធអភិវឌ្ឍន៍អន្តរកាលមួយ មុននឹងធ្វើសមាហរណកម្មពេញលេញចូលប្រព័ន្ធផ្លូវការ និង
- **ទី៨** បន្តពង្រឹងអភិបាលកិច្ច ស្ថាប័ន និងគោលនយោបាយចំណូលមិនមែនសារពើពន្ធផ្តោតលើការកៀរគរចំណូលសក្តានុពលពីចំណូលពីការលក់កាបូន ចំណូលពីធនធានរ៉ែ ចំណូលពីសហគ្រាសសាធារណៈ ភាគហ៊ុនរបស់រដ្ឋ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុ និងចំណូលពីសេវាសាធារណៈជាដើម។

**យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ត្រូវបានរៀបចំឡើងដោយបន្តរក្សាមុខសញ្ញានៃការកែទម្រង់ស្នូលទាំង៣ ដែលមានក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ រួមមាន ១)-ការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ ២)-ការធ្វើទំនើបកម្មនិងវិចារណកម្មគោលនយោបាយពន្ធ និង ៣)-ការពង្រឹងរដ្ឋបាលនិងគោលនយោបាយចំណូលមិនមែនសារពើពន្ធ ដែលទាំងនេះ គឺជាការបន្តកិច្ចការងារកែទម្រង់ និងការបន្តពង្រឹងជាមូលដ្ឋានសម្រាប់រដ្ឋបាលសារពើពន្ធនិងមិនមែនសារពើពន្ធ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមដែលនៅសេសសល់ក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ តាមរយៈការដាក់ចេញនិងអនុវត្តនូវវិធានការគន្លឹះនិងមុតស្រួចជាបន្តបន្ទាប់ដោយចាប់ផ្តើមពី **វេទិការាជរដ្ឋាភិបាលផ្នែកឯកជនលើកទី១៩** ។ ការរៀបចំឯកសារនេះ ត្រូវបានបែងចែកជា ៩ ជំពូកសំខាន់ៗរួមមាន ១)-សេចក្តីផ្តើម ២)-វិធានការគោលនយោបាយនិងសកម្មភាពគាំទ្រដែលបាន

និងកំពុងអនុវត្តក្នុងឆ្នាំ២០២៤ ៣)-ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ៤)-ការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ ៥)-ការធ្វើទំនើបកម្មនិងវិចារណកម្មគោលនយោបាយពន្ធ ៦)-ការពង្រឹងរដ្ឋបាលនិងគោលនយោបាយចំណូលមិនមែនសារពើពន្ធ ៧)-ការគ្រប់គ្រងហានិភ័យ ៨)-ការត្រួតពិនិត្យនិងវាយតម្លៃ និង ៩)-សេចក្តីសន្និដ្ឋាន។

# ជំពូកទី២

# វិធានការគោលនយោបាយដែលបាននិងកំពុងអនុវត្តក្នុងឆ្នាំ២០២៤

បើទោះបីជា **យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ទទួលបានការអនុម័តពីរាជរដ្ឋាភិបាលឱ្យអនុវត្តជាផ្លូវការនៅដំណាច់ឆ្នាំ២០២៤ក៏ដោយក្តី រដ្ឋបាលសារពើពន្ធនិងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ (tax administration and non-tax revenue administration) បាននិងកំពុងជំរុញការងារកែទម្រង់របស់ខ្លួនដោយឥតដកឃ្លា បន្ទាប់ពីការបិទបញ្ចប់ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣។ ក្នុងឆ្នាំ២០២៤កន្លងទៅនេះ ទាំងរដ្ឋបាលសារពើពន្ធនិងរដ្ឋបាលចំណូលមិនមែនសារពើពន្ធបានបន្តបំពេញការងារឥតស្រាកស្រាន្ត តាមរយៈការដាក់ចេញនិងអនុវត្តនូវវិធានការគន្លឹះមុតស្រួចជាបន្តបន្ទាប់ ជាពិសេសក្នុងក្របខ័ណ្ឌនៃការកែទម្រង់អភិបាលកិច្ចនិងស្ថាប័នរបស់ខ្លួន ស្របតាមទិសដៅនៃការកែទម្រង់របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដែលបានជំរុញគ្រប់ស្ថាប័នរដ្ឋឱ្យធ្វើការពិនិត្យនិងពង្រឹងមុខងារនិងរចនាសម្ព័ន្ធការងារផ្ទៃក្នុងឡើងវិញ សំដៅធានាឱ្យមានលក្ខណៈកាន់តែប្រទាក់ក្រឡា គាំទ្រគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមកជាជវភាពនៃប្រព័ន្ធតួអង្គតែមួយ។

ការអនុវត្តវិធានការគន្លឹះសំខាន់ៗនៃការកែទម្រង់រដ្ឋបាលសារពើពន្ធ និងរដ្ឋបាលចំណូលមិនមែនសារពើពន្ធក្នុងឆ្នាំ២០២៤ មានដូចខាងក្រោម៖

❖ **រដ្ឋបាលសារពើពន្ធ**

***អគ្គនាយកដ្ឋានពន្ធដារ***

- **ការអនុវត្តវិធានការកែទម្រង់គន្លឹះនិងមុតស្រួចទាំង ៥៦ នៃផ្នែកការផ្តល់សេវាពន្ធក្រោមដែនសមត្ថកិច្ចពន្ធដារ** ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩
- **ការលើកទឹកចិត្តផ្នែកពន្ធដល់អ្នកអភិវឌ្ឍអចលនទ្រព្យ និងប្រជាពលរដ្ឋជាម្ចាស់អចលនទ្រព្យ** តាមរយៈការពន្យារពេលលើការអនុវត្តពន្ធចំណេញមូលធន ការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់លើអចលនទ្រព្យ សម្រាប់លំនៅដ្ឋានគ្រប់ប្រភេទដែលជាបុរីមានតម្លៃក្រោមឬស្មើនឹង៧ម៉ឺនដុល្លារអាមេរិក ព្រមទាំងការលើកលែងការយកពន្ធលើដីធ្លីមិនបានប្រើប្រាស់សម្រាប់ដីក្រោម៥ហិកតាក្នុងមួយកន្លែង
- **ការកែតម្រូវលិខិតប្រកាសពន្ធដោយអនុញ្ញាតឱ្យអ្នកជាប់ពន្ធធ្វើការកែតម្រូវលិខិតប្រកាសពន្ធឡើងវិញដោយស្ម័គ្រចិត្ត** ដោយមិនជាប់ប្រាក់ពិន័យនិងការប្រាក់ពន្ធរហូតដល់ដំណាច់ខែមិថុនាឆ្នាំ២០២៥

- **ការដាក់ឱ្យអនុវត្តនិយាមប្រតិបត្តិ (SOP) ឬសៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីប្រតិបត្តិ** ចំនួន៩ ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ការផ្តល់សេវាអ្នកជាប់ពន្ធ និងការដាក់លិខិតប្រកាសសារពើពន្ធនិងការបង់ប្រាក់ពន្ធ ព្រមទាំងសម្រាប់ណែនាំលើការអនុវត្តពន្ធមួយចំនួនរួមមានពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រា ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើដីធ្លីមិនបានប្រើប្រាស់
- **ការអនុវត្តសកម្មភាពក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អ.ព.ជ.ក្នុងឆ្នាំ២០២៤** ដែលសម្រេចបាននូវការដាក់ចេញនូវសេចក្តីពិពណ៌នាមុខតំណែងនិងលក្ខខណ្ឌការងាររបស់មន្ត្រីពន្ធដារ ការពង្រឹងសមត្ថភាពមន្ត្រីផ្តល់សេវាពន្ធដារ និងការបណ្តុះបណ្តាលនិងផ្សព្វផ្សាយជូនដល់អ្នកជាប់ពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជនទូទៅអំពីច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងកម្មវិធីទូរស័ព្ទជាដើម និង
- **ការអនុវត្តផែនការប្រតិបត្តិ២០២៤-២០២៨** ដែលផ្តោតសំខាន់លើការបង្កើនភាពងាយស្រួលក្នុងការប្រើប្រាស់សេវាអេឡិចត្រូនិក សម្រាប់ការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ ការផ្សព្វ-ផ្សាយនិងការបញ្ជ្រាបការយល់ដឹងលើអនុលោមភាពនៃអ្នកជាប់ពន្ធ ការបន្តពង្រឹងការគ្រប់គ្រងការប្រមូលបំណុលពន្ធ ការពង្រឹងមុខងារសវនកម្មផ្ទៃក្នុង និងការបន្តធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធទំនើប២បូក និងបន្តក្លាយខ្លួនទៅជារដ្ឋបាលសារពើពន្ធទំនើបជំនាន់៣.០ (Tax Administration 3.0)។

*អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*

- **ការអនុវត្តវិធានការកែទម្រង់គន្លឹះនិងមុតស្រួចទាំង ១៤ នៃផ្នែកកិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ**ដែលបានដាក់ចេញក្នុង ក្នុងវេទិកាពរជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩
- **ការដាក់ឱ្យអនុវត្តជាផ្លូវការនូវប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window)** កាលពីខែឧសភា ឆ្នាំ២០២៤ ដែលបានពង្រីកវិសាលភាពគ្របដណ្តប់ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការចេញអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងឯកសារផ្សេងទៀតសម្រាប់ទំនិញនាំចេញនិងនាំចូល
- **ការបន្តអភិវឌ្ឍនិងពង្រីកមុខងារ ធ្វើវិសិដ្ឋកម្មនិងសមាហរណកម្មមុខងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធ**ដូចជាមុខងារគ្រប់គ្រងសន្និធិគយបណ្តោះអាសន្ន បណ្ណាល័យអេឡិចត្រូនិក មុខងារប្រើប្រាស់ឯកសារប្រតិវេទន៍គយអាស៊ាន ការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មីសម្រាប់វិភាគទិន្នន័យ និងការធ្វើសមាហរណកម្មមុខងារប្រតិវេទន៍គយសង្ខេបក្នុងប្រព័ន្ធអាស៊ីគូដា
- **ការបន្តពង្រឹងសមត្ថភាពស្ថាប័ន វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីគយ** តាមរយៈការគ្រប់គ្រងមន្ត្រីគយនិងរដ្ឋាករតាមប្រព័ន្ធបច្ចេកវិទ្យា និងត្រួតពិនិត្យកិច្ចការរដ្ឋបាលជាប្រចាំ

ការវាយតម្លៃសមិទ្ធកម្មការងារដើម្បីផ្តល់ការលើកទឹកចិត្តឬដាក់ទណ្ឌកម្ម ការចុះធ្វើសវនកម្មផ្ទៃក្នុងតាមអង្គភាពគយនិងរដ្ឋាករ និងការចាត់វិធានការតឹងរឹងខាងវិន័យចំពោះមន្ត្រីគយ

- **ការបង្កើតយន្តការឆ្លើយតបបញ្ហាពាក់ព័ន្ធនឹងគយ និងពង្រឹងការអនុវត្តការទទួលព័ត៌មានត្រឡប់និងទទួលពាក្យបណ្តឹង** ដើម្បីលើកកម្ពស់វប្បធម៌នៃការបង់ពន្ធត្រឹមត្រូវ តម្លាភាពនៃការផ្តល់សេវាសាធារណៈ សុចរិតភាព និងការប្រឆាំងអំពើពុករលួយ និង
- **ការបន្តពង្រឹងសមត្ថភាពមន្ត្រីនិងសមត្ថភាពគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធនិងសុវត្ថិភាពប្រព័ន្ធ** តាមរយៈការបណ្តុះបណ្តាលលើការងារបច្ចេកទេសគយ ការងារសវនកម្ម ជំនាញស៊ើបអង្កេតបទល្មើសនិងជំនាញពាក់ព័ន្ធផ្សេងទៀត ក៏ដូចជាការដាក់ឱ្យអនុវត្តមជ្ឈមណ្ឌលទិន្នន័យស្តង់ដារ Tier III ( DATA Center Tier III Standard ) និងការប្រើប្រាស់បច្ចេកវិទ្យាថ្មី។

❖ **រដ្ឋបាលចំណូលមិនមែនសារពើពន្ធ**

- **ការដាក់ឱ្យប្រើប្រាស់ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ជំនាន់ថ្មី** សម្រាប់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត អង្គភាពសាធារណៈប្រហាក់ប្រហែល និងនីតិបុគ្គលសាធារណៈផ្សេងៗ
- **ការពង្រឹងអភិបាលកិច្ចនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ** តាមរយៈការពិនិត្យឡើងវិញលើការអនុវត្តច្បាប់ទៅតាមមុខងារ រួមទាំងការពង្រឹងភាពម្ចាស់ការនិងការទទួលខុសត្រូវរបស់អង្គភាពនិងមន្ត្រី ការពង្រឹងយន្តការផ្តល់ព័ត៌មាននិងទិន្នន័យច្បាស់លាស់ ព្រមទាំងការជំរុញឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធរៀបចំកិច្ចប្រជុំប្រចាំត្រីមាសឬប្រចាំឆ្នាំ
- **ការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ** ដោយផ្តោតលើវិធានការតាមមុខចំណូលសំខាន់ៗរួមមាន ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ចំណូលពីសហគ្រាសសាធារណៈភាគហ៊ុនរបស់រដ្ឋនិងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ចំណូលពីសេវាសាធារណៈ ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម និងចំណូលមិនមែនសារពើពន្ធដទៃទៀត
- **ការបន្តអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងជំរុញការប្រើប្រាស់ NRMIS និង SARMIS** រួមទាំងការជំរុញឱ្យប្រើប្រាស់មុខងារ e-Payment
- **ការជំរុញការធ្វើសន្ទានកម្មប្រព័ន្ធ NRMIS និងប្រព័ន្ធ SARMIS** ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាពិសេសប្រព័ន្ធ FMIS និងប្រព័ន្ធនៃក្រសួង-ស្ថាប័នផ្សេងទៀត និង
- **ការពង្រឹងសមត្ថភាពតាមមូលដ្ឋាន** តាមរយៈការបណ្តុះបណ្តាល និងផ្សព្វផ្សាយ។

*(សម្គាល់៖ វិធានការគោលនយោបាយនិងសកម្មភាពគាំទ្រដែលបាននិងកំពុងអនុវត្តក្នុងឆ្នាំ២០២៤ មានលម្អិតក្នុងឧបសម្ព័ន្ធទី៥ នៃឯកសារនេះ។)*

ក្នុងន័យនេះ ក្នុងអំឡុងពេលដែល **យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ត្រូវបានរៀបចំសម្រិតសម្រាំងយ៉ាងមធ្យ័ត រដ្ឋបាលសារពើពន្ធនិងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ បានខិតខំបន្តអនុវត្តការងារកែទម្រង់មុតស្រួចប្រកបដោយស្មារតីបុរេសកម្មខ្ពស់ ដែលឆ្លុះបញ្ចាំងពីការផ្សារភ្ជាប់មិនដកឃ្លានិងមិនឱ្យដាច់នូវនិរន្តរភាពការងារកែទម្រង់ បន្ទាប់ពីការបិទបញ្ចប់ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលដំណាក់កាលទី២ ឈានចូលការចាប់ផ្ដើមដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលដំណាក់កាលទី៣ ជាបន្តបន្ទាប់។

# ជំពូកទី៣
# ក្របខ័ណ្ឌរួមនៃ
# យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា

## ៣.១. ចក្ខុវិស័យ

**យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** មានចក្ខុវិស័យចូលរួមប្រែក្លាយ ប្រព័ន្ធចំណូលរដ្ឋឱ្យកាន់តែទំនើប មានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយសុភបរមា ដែលអាចឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍនិងការវិវឌ្ឍនៃរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចកម្ពុជា។ ក្នុងន័យនេះ **យុទ្ធសាស្ត្រកៀរគរចំណូល** នឹងក្លាយជាឧបករណ៍គោលនយោបាយមួយយ៉ាងសំខាន់ក្នុងការកៀរគរចំណូលរដ្ឋប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពខ្ពស់ តាមរយៈការដាក់ចេញនូវគោលបំណងនិងគោលដៅ ព្រមទាំងវិធានការមុតស្រួចនានាសម្រាប់អនុវត្តក្នុងរយៈពេល ៥ឆ្នាំ នៃអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

## ៣.២. គោលបំណង និងគោលដៅ

**យុទ្ធសាស្ត្រកៀរគរចំណូលនេះ** មាន**គោលបំណង** ពង្រឹងការប្រមូលចំណូលឱ្យកាន់តែប្រសើរ តាមរយៈការបន្តធ្វើទំនើបកម្មរដ្ឋបាល និងគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ដោយថ្លឹងថ្លែង បន្តរក្សាឱ្យបាននូវចលនការ និងសម្ទុះនៃសេដ្ឋកិច្ច ផ្តល់នូវភាពត្រឹមត្រូវ តម្លាភាព និងភាពយុត្តិធម៌ដល់អ្នកជាប់ពន្ធ ដោយផ្តោតលើចំណូលដែលជាសក្តានុពល និងមិនបង្កឱ្យមានវិការភាពសេដ្ឋកិច្ច (economic distortion)។ ស្របនឹងគោលបំណងខាងលើ យុទ្ធសាស្ត្រនេះមាន **គោលដៅចំនួន ៣** ដែលមានចរិតសុទិដ្ឋិនិយមប្រកបដោយភាពច្បាស់លាស់ និងការប្តេជ្ញាខ្ពស់របស់រាជរដ្ឋាភិបាល ដែលក្នុងនោះ រួមមាន៖

(១). រក្សា និងជំរុញចំណូលចរន្តឱ្យបានក្នុងរង្វង់ ១៦% នៃ ផ.ស.ស នៅពេលកំណើនសេដ្ឋកិច្ចត្រឡប់មកកាន់គន្លងសក្តានុពលវិញ ពោលគឺ មានកំណើនពិន្ទុភាគរយជាមធ្យមប្រចាំឆ្នាំប្រមាណ ០,៤៣ ឬ កំណើនមធ្យមប្រចាំឆ្នាំ ១២,៥% (២០២៥-២០២៨) ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងត្រូវកើនឡើងដល់ក្នុងរង្វង់ ១៤,០% នៃ ផ.ស.ស.

(២). ធានាឱ្យបាននូវភាពច្បាស់លាស់ និងភាពត្រឹមត្រូវនៃប្រព័ន្ធពន្ធ និងភាពអាចព្យាករបាននៃការផ្លាស់ប្តូរ និង

(៣). បន្តពង្រីកវិសាលភាព និងពង្រឹងគុណភាពប្រព័ន្ធចំណូលមិនមែនសារពើពន្ធ។

### ៣.៣. អភិក្រមនៃការរៀបចំយុទ្ធសាស្ត្រ

១៣. យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយប្រកាន់ខ្ជាប់នូវ **អភិក្រម** ចំនួន ៥ គឺ ៖

(១). ជានាកំណើនសេដ្ឋកិច្ច បង្កើតបរិយាកាសអំណោយផលដល់សកម្មភាពសេដ្ឋកិច្ច និងជំរុញសកម្មភាពពាណិជ្ជកម្ម

(២). មិនបង្កើតប្រភេទពន្ធថ្មី និងមិនដំឡើងអត្រាពន្ធ-អាករ លើកលែងតែ អាករពិសេស លើទំនិញ និងសេវា ដែលប៉ះពាល់ដល់សុខភាពរបស់ប្រជាជន សង្គម និងបរិស្ថាន បន្តការអនុវត្តគោលនយោបាយលើកទឹកចិត្តមានស្រាប់ ដែលចំគោលដៅ និងមានវិចារណកម្ម និងធានាយន្តការប្រមូលពន្ធមិនឱ្យត្រួតគ្នា

(៣). ពង្រឹងយន្តការឆ្លើយតបជាមួយអ្នកជាប់ពន្ធ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា និងការពង្រឹងក្រមប្រតិបត្តិមន្ត្រីប្រមូលចំណូល

(៤). រៀបចំវិធានការ ដែលមានលក្ខណៈយុទ្ធសាស្ត្រមុតស្រួច និងមានចំនួនតិច ដែលមានចរិតបង្កើតចំណូល ប៉ុន្តែមិនបង្កឱ្យមានវិការភាពសេដ្ឋកិច្ច (economic distortion) និងធានាបាននូវសមធម៌ និងយុត្តិធម៌ក្នុងការបង់ពន្ធ និង

(៥). ជំរុញការចូលរួមពីវិស័យឯកជន ដើម្បីធានាឱ្យបាននូវទស្សនរួម ភាពគ្រប់ជ្រុងជ្រោយនៃវិធានការ និងភាពជាក់ស្តែងនិយម។

## ជំពូកទី៤
## ការធ្វើទំនើបភាវូបនីយកម្ម រដ្ឋបាលសារពើពន្ធ

### ៤.១. ការធ្វើទំនើបភាវូបនីយកម្ម នៃអគ្គនាយកដ្ឋានពន្ធដារ

នៅក្នុងអំឡុង នៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ អ.ព.ដ. បានសម្រេចនូវសមិទ្ធផលជាច្រើន ក្នុងការបន្តធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ ដើម្បីផ្តល់សេវាប្រកបដោយគុណភាពជូនដល់អ្នកជាប់ពន្ធ ក្នុងគោលដៅបង្កើនអនុលោមភាពសារពើពន្ធដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុកអ្នកជាប់ពន្ធ តាមរយៈការដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីសហគ្រាស ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមប្រព័ន្ធអនឡាញ (e-Filling) ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (e-Commerce Tax System) ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ (Tax on Income - ToI e-Filling) ប្រព័ន្ធគ្រប់គ្រងបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ (e-Payment) កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (Tax Prefilling App) និងកម្មវិធីទូរស័ព្ទដៃផ្សេងទៀតជាដើម។

ការធ្វើបរិវត្តកម្មឌីជីថល (Digital transformation) ក្នុងការកែទម្រង់ស្ថាប័នបានផ្តល់នូវកាលានុវត្តភាពថ្មី និងបានពង្រឹងសមត្ថភាពដល់រដ្ឋបាលសារពើពន្ធ ក្នុងការគ្រប់គ្រងកិច្ចការនៃការប្រមូលចំណូលសារពើពន្ធ និងការផ្តល់សេវាដល់អ្នកជាប់ពន្ធរបស់ខ្លួនកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ជាងមុន ព្រមទាំងបានឆ្លើយតបទៅនឹងការវិវឌ្ឍនៃសង្គម-សេដ្ឋកិច្ចកម្ពុជា និងនិន្នាការតំបន់ និងសកល។ អនុលោមតាម

ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ការកសាងរដ្ឋាភិបាលឌីជីថល ការកសាងពលរដ្ឋឌីជីថល និងការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល ជាកិច្ចការអាទិភាពនៃបរិវត្តកម្មឌីជីថល។ ផ្សារភ្ជាប់ជាមួយកិច្ចការនេះ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** នឹងបន្តធ្វើទំនើបកាវូបនីយកម្ម អ.ព.ដ. ឱ្យឈានឆ្ពោះទៅមុខមួយកម្រិតទៀត សំដៅចាប់យក និងធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធជំនាន់ ២ បូក (Tax administration 2 Plus) និងឈានទៅដល់រដ្ឋបាលសារពើពន្ធជំនាន់ ៣.០ (Tax Administration 3.0) នាពេលខាងមុខដែលជាការលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ បង្កើនអនុលោមភាព និងកាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធក្នុងគោលដៅរក្សាបាននូវចីរភាពនៃការគ្រប់គ្រងការប្រមូលចំណូលសារពើពន្ធ។ ដើម្បីជំរុញការចាប់យក និងការធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធជំនាន់ ២ បូក រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយមានការចូលរួមពីក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដទៃទៀត នឹងគិតគូរលើកិច្ចការមួយចំនួនដោយត្រូវមានការបញ្ចូលនូវមុខងារវិភាគទិន្នន័យកម្រិតខ្ពស់ (Advanced Data Analytics) ការផ្តល់ថ្នាលសេវាពន្ធបែបឌីជីថលកាន់តែមានលក្ខណៈបុគ្គល (Personalized Digital Platforms) និងការធ្វើសមាហរណកម្មតភ្ជាប់ទិន្នន័យអ្នកជាប់ពន្ធរវាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្រោមថ្នាលឌីជីថលតែមួយ។ បន្ថែមពីនេះ ការពង្រឹងសមត្ថភាពមន្ត្រីផ្តល់សេវា និងការធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគាំទ្រដល់ប្រតិបត្តិការឌីជីថល និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីសេវាអ្នកជាប់ពន្ធតាមរយៈប្រព័ន្ធឌីជីថល គឺជាគន្លឹះសំខាន់ដើម្បីអភិវឌ្ឍមូលធនមនុស្សឌីជីថល ទាំងមន្ត្រីផ្តល់សេវា និងអ្នកជាប់ពន្ធ។ ការធ្វើទំនើបកាវូបនីយកម្ម អ.ព.ដ. មានគោលបំណង **បន្តពង្រឹងគុណភាព និងផលិតភាពនៃសេវាអ្នកជាប់ពន្ធឱ្យកាន់តែប្រសើរ និងមានភាពឆ្លើយតបទៅនឹងរបត់សង្គម-សេដ្ឋកិច្ច និងគណនេយ្យភាពមន្ត្រីផ្តល់សេវា ដើម្បីគាំទ្រដល់ភាពប្រកួតប្រជែងនៃធុរកិច្ចទាំងក្នុងស្រុក និងក្នុងតំបន់។** ក្នុងន័យនេះ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** នឹងបន្តធ្វើទំនើបកាវូបនីយកម្ម អ.ព.ដ. ដោយផ្តោតសំខាន់លើ ១)-ក្របខ័ណ្ឌអភិបាលកិច្ច និងស្ថាប័ន ២)-មុខងារស្នូល និង ៣)-មុខងារគាំទ្រ។

### ក. ក្របខ័ណ្ឌអភិបាលកិច្ច និងស្ថាប័ន

ក្របខ័ណ្ឌអភិបាលកិច្ច និងស្ថាប័ននៃ អ.ព.ដ. ផ្តោតសំខាន់លើការបង្កើនសមត្ថភាព និងក្រមប្រតិបត្តិវិជ្ជាជីវៈរបស់មន្ត្រី ជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាចាំបាច់ ពិសេសបច្ចេកវិទ្យាឌីជីថល ការបង្កើនប្រសិទ្ធភាពស្ថាប័នក្នុងការគ្រប់គ្រង និងការវិភាគហានិភ័យក្នុងការប្រមូលចំណូលសារពើពន្ធ និងការត្រៀមខ្លួនឆ្ពោះទៅបរិវត្តកម្មរដ្ឋបាលសារពើពន្ធជំនាន់ ២ បូក ក្នុងបរិបទនៃយុគសម័យបច្ចេកវិទ្យាឌីជីថល តាមរយៈការកសាង និងពង្រឹងធនធានមនុស្សឌីជីថល ការផ្សារភ្ជាប់ និងប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការផ្តល់សេវាអ្នកជាប់ពន្ធក្នុងជីវភាពរស់នៅរបស់ប្រជាជន (Taxpayer touchpoints) ក៏ដូចជាអ្នកជាប់ពន្ធ និងយុទ្ធនាការជំរុញ និងលើកទឹកចិត្តអ្នកជាប់ពន្ធឱ្យមកចុះបញ្ជីពន្ធដារ ដើម្បីផ្តល់ការថែរក្សា និងគាំពារអ្នកជាប់ពន្ធ។ ដើម្បីសម្រេចឱ្យបានគោលបំណងនៃការកែទម្រង់ និងទំនើបកាវូបនីយកម្មក្របខ័ណ្ឌអភិបាលកិច្ច និងស្ថាប័ន ចំណុចគន្លឹះ ដែលត្រូវដោះស្រាយ រួមមាន៖

- អសង្គតិភាពនៃការអនុវត្តការងារមួយចំនួនរវាងមន្ត្រី និងមន្ត្រីនៅបន្តកើតមាន
- ហានិភ័យមូលធនមនុស្ស (Human capital risk) ដែលប៉ះពាល់ដល់ការគ្រប់គ្រងពន្ធអាចបណ្តាលឱ្យបាត់បង់ទំនុកចិត្តរបស់អ្នកជាប់ពន្ធទៅលើមន្ត្រីអនុវត្ត
- សមត្ថភាពក្នុងការពន្យល់បកស្រាយអំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានាដោយមន្ត្រីផ្តល់សេវាមួយចំនួន មិនទាន់មានសង្គតិភាព និងភាពច្បាស់លាស់ពេញលេញ និង
- សមត្ថភាពមន្ត្រីមួយចំនួននៅមានកម្រិត ជាពិសេស មន្ត្រីនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ មិនទាន់អាចគ្រប់គ្រង និងចាត់ចែងលើការងារដែលមានភាពស៊ីជម្រៅ។

**ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- ➢ បន្តពង្រឹងសមត្ថភាពមន្ត្រីពន្ធក្នុងការគ្រប់គ្រង និងវិភាគពីហានិភ័យតាមប្រភេទពន្ធ និងវិស័យសេដ្ឋកិច្ចសំខាន់ៗ ដើម្បីដាក់ចេញនូវវិធានការបង្ការពល់ភាពអសកម្មនានាពេលបំពេញប្រតិបត្តិការប្រមូលពន្ធ ដើម្បីធានានូវតម្លាភាព និងយុត្តិធម៌ជូនអ្នកបង់ពន្ធ
- ➢ អភិវឌ្ឍថ្នាល E-learning ដើម្បីអាចឱ្យមន្ត្រីអាចបង្កើនជំនាញតាមប្រព័ន្ធឌីជីថលសម្រាប់ពង្រឹងជំនាញ និងសមត្ថភាពរបស់មន្ត្រី
- ➢ បណ្តុះបណ្តាលសមត្ថភាព និងជំនាញរបស់មន្ត្រី និងការវាយតម្លៃសូចនាករសមិទ្ធកម្មគន្លឹះផ្អែកលើតួនាទី និងការទទួលខុសត្រូវ ដើម្បីធានាថាសមត្ថភាពរបស់មន្ត្រីត្រូវបានពង្រឹង និងអាចផ្គូរផ្គងជំនាញបុគ្គលិក (Match staff skills) ទៅនឹងតម្រូវការអ្នកជាប់ពន្ធ និង
- ➢ ពង្រឹងការអនុវត្តនិយាមប្រតិបត្តិ (SOP) របស់អង្គភាពក្រោមឱវាទ អ.ព.ដ. ដោយមានការចូលរួមត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាព ពីអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្នុងការធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាពពេញលេញ។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- ➢ ពង្រឹងអភិបាលកិច្ច និងស្ថាប័ន តាមរយៈការវិភាគមុខងារ និងកែសម្រួលរចនាសម្ព័ន្ធ។

## ខ. មុខងារស្នូល

មុខងារប្រតិបត្តិការស្នូលតាមឧត្តមានុវត្តន៍អន្តរជាតិ ត្រូវមានលក្ខណៈពិសេស ចំនួន ៣ គឺ ១)-ការធ្វើឱ្យកាន់តែប្រសើរឡើងនូវដំណើរការការងារ និងការគ្រប់គ្រងការផ្លាស់ប្តូរស្ថាប័ន មុននឹងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ២)-ការធ្វើសមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានលើមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រដែលមានស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡាលើមុខងារប្រតិបត្តិការទាំងអស់ និង ៣)-ការផ្លាស់ប្តូរទៅជារដ្ឋបាលសារពើពន្ធ ដែលផ្តោតលើអ្នកជាប់ពន្ធ (Customer-oriented tax administration) តាមរយៈការពង្រឹងគុណភាពក្នុងការផ្តល់សេវា។ ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ កន្លងមក បានឆ្លុះបញ្ចាំងឱ្យឃើញថាកម្ពុជា សម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ស្របនឹងគោលបំណង នៃការកែទម្រង់មុខងារប្រតិបត្តិការស្នូល នៃ អ.ព.ដ. ដែលមានលក្ខណៈឆ្លើយតបទៅនឹងបរិបទសង្គម-សេដ្ឋកិច្ច។ ជាមួយគ្នានេះ វិស័យឯកជនក៏បានកោតសរសើរ និងពេញចិត្តខ្ពស់ចំពោះការកែទម្រង់

របស់រដ្ឋបាលពន្ធដារ ដោយបានដាក់ឱ្យអនុវត្តប្រព័ន្ធអេឡិចត្រូនិក ក្នុងការផ្តល់សេវាអ្នកជាប់ពន្ធ ដែលបាន កាត់បន្ថយពេល និងបន្ទុកអនុលោមភាពផ្សេងជាច្រើនផងដែរ។

យ៉ាងណាមិញ រាជរដ្ឋាភិបាលនៅតែបន្តពង្រឹងប្រសិទ្ធភាពបន្ថែមក្នុងការកែទម្រង់ និងការកែលម្អ មុខងារប្រតិបត្តិការស្នូល នៃ អ.ព.ដ. ដើម្បីឱ្យគុណភាពសេវាអ្នកជាប់ពន្ធកាន់តែមានភាពល្អប្រសើរ កាត់បន្ថយ បន្ទុកអ្នកជាប់ពន្ធ ពង្រឹងនូវភាពប្រកួតប្រជែងក្នុងធុរកិច្ចប្រកបដោយយុត្តិធម៌ ព្រមទាំងចូលរួមចំណែកក្នុង ការអភិវឌ្ឍវិស័យក្រៅប្រព័ន្ធ។ ក្នុងន័យនេះ មុខងារស្នូលនៃអ.ព.ដ. នៅក្នុង **យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ផ្តោតសំខាន់លើការបន្តបង្កើនគុណភាព និងប្រសិទ្ធភាព សេវាអ្នកជាប់ពន្ធ ការបង្កើនអនុលោមភាពដោយស្ម័គ្រចិត្ត ការពង្រឹងទំនុកចិត្តរវាង អ.ព.ដ. និងអ្នកជាប់ពន្ធ ការជំរុញ និងលើកទឹកចិត្ត អ្នកជាប់ពន្ធ ឱ្យមកចុះបញ្ជីពន្ធដារ និងគាំពារអ្នកជាប់ពន្ធដែលកំពុងនៅក្នុង ប្រព័ន្ធ។ ដើម្បីសម្រេចបាននូវគោលបំណងនៃការកែទម្រង់ និងកែលម្អមុខងារប្រតិបត្តិការស្នូលឱ្យកាន់តែ មានប្រសិទ្ធភាព អ.ព.ដ. ត្រូវបន្តដោះស្រាយបញ្ហាមួយចំនួន ដូចខាងក្រោម៖

- ភាពយឺតយ៉ាវក្នុងការបិទបញ្ចប់សវនកម្មពន្ធដារ ការដោះស្រាយវិវាទពន្ធដារ និងដំណើរការបង្វិល សងអាករលើតម្លៃបន្ថែម នៅបន្តកើតមាន ដោយសារ ១)-ការបកស្រាយច្បាប់ និងបទប្បញ្ញត្តិមួយ ចំនួននៅមិនទាន់មានសង្គតិភាព និងភាពច្បាស់លាស់ពេញលេញ និង ២)- កិច្ចសហប្រតិបត្តិការ ពីសំណាក់អ្នកជាប់ពន្ធមួយចំនួននៅមានកម្រិត ដោយពុំបានផ្តល់ ឬយឺតយ៉ាវក្នុងការផ្តល់ឯកសារ ពាក់ព័ន្ធ ពុំចូលខ្លួនមកបំភ្លឺ ឬពិគ្រោះក្នុងករណីសវនកម្ម ឬស៊ើបអង្កេតបទល្មើសពន្ធដារ ពុំ ដោះស្រាយបំណុលពន្ធ ឬ ពុំចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានា ជាដើម
- សេដ្ឋកិច្ចក្រៅប្រព័ន្ធមានទំហំធំ និងសហគ្រាសមិនទាន់ចុះបញ្ជីមានចំនួនច្រើន ដែលធ្វើឱ្យ ប្រសិទ្ធភាពនៃការដាក់ចេញនូវវិធានការគាំទ្រការអភិវឌ្ឍសហគ្រាសទាំងនោះ មានកម្រិត ព្រមទាំងអាចធ្វើឱ្យមានហានិភ័យ ក្នុងការគ្រប់គ្រងចំណូលសារពើពន្ធសម្រាប់រយៈពេលមធ្យម និងវែងខាងមុខ
- ការឈរឈ្មោះជំនួសឱ្យក្រុមហ៊ុន ឬការប្រើប្រាស់ព័ត៌មានមិនពិតក្នុងការចុះបញ្ជី ការបង្កើត សហគ្រាសសិប្បនិម្មិត ដើម្បីគេចវេះពន្ធ និងការក្លែងបន្លំពន្ធដារជាលក្ខណៈប្រព័ន្ធ នៅបន្តកើតមាន
- ទំនុកចិត្តលើយុត្តិធម៌ក្នុងការបង់ពន្ធ ជាពិសេសក្នុងចំណោមសហគ្រាសធុនតូច និង មធ្យម និង ម្ចាស់អចលនទ្រព្យមួយចំនួនធំ នៅមានកម្រិត និង
- ភាពមានកម្រិតនៃការគ្រប់គ្រងហានិភ័យ (Risk-based management)។

**ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការ ដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- ➢ បន្តលើកកម្ពស់សេវាអ្នកជាប់ពន្ធ ជាពិសេសឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល ដោយបន្តធ្វើទំនើប ភាវូបនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសមាហរណកម្មប្រព័ន្ធមុខងារស្នូល កាន់តែ ប្រទាក់ក្រឡាជាងមុន រួមមានការចុះបញ្ជីពន្ធដារ (E-registration) ការដាក់លិខិតប្រកាស ពន្ធ (E-filing) និងការបង់ប្រាក់ពន្ធ (E-payment)

- បង្កើនប្រសិទ្ធភាពសវនកម្មពន្ធ និងកាត់បន្ថយការធ្វើសវនកម្មត្រួតគ្នា និងច្រើនលើកច្រើនសា តាមរយៈការអនុវត្តសៀវភៅណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ (SOP on Auditing) ដើម្បីធានាអនុលោមភាពពន្ធដារ និងគុណភាពសេវាអ្នកជាប់ពន្ធ។ល។
- បង្កើនប្រសិទ្ធភាពនៃការដោះស្រាយបណ្តឹងតវ៉ាប្រកបដោយទំនុកចិត្តរវាងមន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីការដោះស្រាយបណ្តឹងតវ៉ា
- បង្កើនប្រសិទ្ធភាព និងយន្តការនៃការស៊ើបអង្កេតបទល្មើសពន្ធដារ តាមរយៈការអនុវត្តសៀវភៅណែនាំ ស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌពីពន្ធដារ និងបែបបទនិងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌស្តីពីពន្ធដារ (SOP on Investigation) ដើម្បីធានាឱ្យមាននូវតម្លាភាព និងធានានូវការប្រកួតប្រជែងស្មើភាពគ្នា និងបង្កើតឱ្យមានភាពជឿទុកចិត្តពីសាធារណជន
- បន្តពង្រឹងការគ្រប់គ្រងបំណុលពន្ធ សំដៅកាត់បន្ថយជាអតិបរមានូវបំណុលបច្ចុប្បន្ន និងចៀសវាងការកើនឡើងបំណុលពន្ធនាពេលអនាគត
- ជំរុញ និងលើកទឹកចិត្ត អ្នកជាប់ពន្ធឱ្យមកចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ជាពិសេសសហគ្រាសធុនតូចតូច និងមធ្យម
- ធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់សហគ្រាសស្ថិតក្រោមរបបស្វ័យប្រកាស តាមរយៈការវិភាគ និងចាត់ថ្នាក់នូវទំហំផលរបរ និងទ្រព្យសកម្ម ប្រកបដោយតម្លាភាព និងយុត្តិធម៌
- ពង្រឹងយន្តការនៃការអនុវត្តប្រព័ន្ធបង្វិលសងអាករលើតម្លៃបន្ថែម ដើម្បីលើកកម្ពស់ និងធានានូវប្រសិទ្ធភាព ក្នុងការស្នើសុំជាតុចូលអាករលើតម្លៃបន្ថែមលើការកាត់បន្ថយរយៈពេល និងចៀសវាងការយោងឥណទានអាករលើតម្លៃបន្ថែមលើសលប់ក្នុងរយៈពេលយូរ និង
- ពង្រឹងគុណភាពឯកសារវិភាគហានិភ័យទូទៅរបស់រដ្ឋបាលសារពើពន្ធ ដោយត្រូវកំណត់នូវវិធីសាស្ត្រឱ្យសមស្របទៅនឹងឧត្តមានុវត្តន៍អន្តរជាតិ ដែលជួយដល់ការលើកកម្ពស់ប្រសិទ្ធភាពមុខងារស្នូល ព្រមទាំងដំណើរការដោយស្វ័យប្រវត្តិក្នុងការគ្រប់គ្រង និងប្រមូលពន្ធឱ្យមានប្រសិទ្ធភាព តម្លាភាព ចំគោលដៅ និងទាន់ពេល។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- សិក្សារៀបចំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ដើម្បីត្រៀមអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល
- អនុវត្តសាកល្បងនូវប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក (E-invoicing system) ដោយ ១)-សិក្សាស្វែងយល់ពីភាពជាដៃគូជាមួយវិស័យឯកជន ដើម្បីអនុវត្តប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក ដែលសម្រួលដល់ការរាយការណ៍ និងសុពលភាពប្រតិបត្តិការទាន់ពេល ២)-រៀបចំលិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំគ្រប់ជ្រុងជ្រោយ ដើម្បីដាក់ឱ្យដំណើរការសាកល្បងនូវវិក្កយបត្រអេឡិចត្រូនិក (E-invoicing) និង
- សិក្សាអំពីលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តប្រព័ន្ធ Self-service ជាមគ្គុទេសក៍សម្រាប់អ្នកជាប់ពន្ធ ដើម្បីអាចផ្តល់លទ្ធភាពដល់អ្នកជាប់ពន្ធ ដែលបានចុះបញ្ជីក្នុងប្រព័ន្ធពន្ធដារ អាចដឹងពី

ប្រភេទពន្ធ-អាករដែលខ្លួនត្រូវបង់ តាមដានទិន្នន័យបំណុលពន្ធ ដឹងពីស្ថានភាព នៃការចុះធ្វើសវនកម្ម និងទិន្នន័យផ្សេងៗទៀត ដើម្បីចូលរួមក្នុងការបង្កើនចំណេះដឹងលើកាតព្វកិច្ចពន្ធ និងអាចទទួលដំណឹងពាក់ព័ន្ធផ្សេងៗពី អ.ព.ដ.។

## គ. មុខងារគាំទ្រ

ការចាប់យកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល បានចូលរួមក្នុងការជំរុញឱ្យរាជរដ្ឋាភិបាលធ្វើការផ្លាស់ប្តូររបៀបនៃការផ្តល់សេវា និងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ បានកាន់តែល្អប្រសើរ និងសាមញ្ញជាងមុន តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានក្នុងការប្រើប្រាស់ និងការទទួលយកនូវបរិការណ៍ឌីជីថលនានា មានដូចជា ការរៀបចំថ្នាលចែករំលែកទិន្នន័យតាមឌីជីថល និងការប្រើប្រាស់ទិន្នន័យផ្សេងៗ ដោយមានការចូលរួមពីតួអង្គពាក់ព័ន្ធទាំងអស់ ក្នុងន័យពន្លឿនការចាប់យក និងការទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល។ ទន្ទឹមនេះ ការដាក់ឱ្យដំណើរការនូវថ្នាលផ្លាស់ប្តូរទិន្នន័យ (CamDX) គឺជាវឌ្ឍនភាពមួយក្នុងដំណើរឆ្ពោះទៅរកការចាប់យក និងធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល ទាំងការចុះបញ្ជីរួម និងជាកញ្ចប់តែមួយ (Single portal) ការស្នើសុំអាជ្ញាបណ្ណ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រជំនាញតាមវិស័យ ផ្អែកតាមសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន សហគ្រាស ដែលមានវិសាលភាព គ្របដណ្តប់លើគ្រប់ក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធគន្លឹះនានា ជាពិសេសគឺវិស័យឯកជន។

ក្នុងបរិការណ៍នៃកំណើនធុរកិច្ចពហុសាសន៍ (Multi-national businesses) និងពាណិជ្ជកម្មអន្តរជាតិ (International trade) ដែលកាន់តែជឿនលឿន និងមានភាពស្មុគស្មាញ សហគ្រាសធុនតូច និងមធ្យម និងអ្នកជាប់ពន្ធរូបវន្តបុគ្គល អាចមានលទ្ធភាពកាន់តែច្រើនឡើងៗ ក្នុងការបង្កើនប្រាក់ចំណូលពីក្រៅប្រទេស។ ក្នុងន័យនេះ ការធ្វើសមាហរណកម្មនៃដំណើរការកំណត់អត្តសញ្ញាណកម្ម និងការរាយការណ៍របស់អ្នកជាប់ពន្ធទៅក្នុងកម្មវិធី (Application) ដែលប្រើនៅក្នុងថ្នាលពាណិជ្ជកម្មអនឡាញ នឹងត្រូវជំរុញដើម្បីគាំទ្រដល់អនុលោមភាពពន្ធ កាត់បន្ថយបន្ទុកដល់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ និងទប់ស្កាត់ការក្លែងបន្លំពន្ធ រួមជាមួយនឹងការអភិវឌ្ឍអត្តសញ្ញាណឌីជីថល (Digital identity) របស់អ្នកជាប់ពន្ធ។

ក្នុងន័យនេះ ដើម្បីគាំទ្រដល់ប្រសិទ្ធភាពនៃការធ្វើទំនើបភាវូនីយកម្មក្របខ័ណ្ឌអភិបាលកិច្ច និងស្ថាប័ន និងមុខងារស្នូលរបស់ អ.ព.ដ. មុខងារគាំទ្រនៃ **យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ផ្តោតលើទិសដៅការងារសំខាន់ៗ ដូចជា ១)-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការផ្តល់សេវា និងការប្រាស្រ័យទាក់ទងជាមួយអ្នកជាប់ពន្ធ ២)-ការបង្កើនប្រសិទ្ធភាពក្នុងការផ្ទេរផ្ទង់ និងចែករំលែកព័ត៌មាន និងទិន្នន័យរវាងក្រសួង-ស្ថាប័នរដ្ឋ និងដៃគូពាក់ព័ន្ធ និង ៣)-ការរៀបចំក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងការចែករំលែក និងប្រើប្រាស់ទិន្នន័យ។ យ៉ាងណាមិញ អ.ព.ដ. នៅមានបញ្ហាប្រឈម ឬសេសសល់មួយចំនួនត្រូវបន្តដោះស្រាយ រួមមាន៖

- ចំណេះដឹង និងការយល់ដឹងលើច្បាប់និងលិខិតបទដ្ឋានគតិយុត្ត របស់អ្នកជាប់ពន្ធនៅមានកម្រិត ជាពិសេសអ្នកជាប់ពន្ធតូច និងមធ្យម
- កង្វះខាតការបញ្ជ្រាបចំណេះដឹងលើច្បាប់ និងបទដ្ឋានគតិយុត្ត ស្តីពីពន្ធដារនៅតាមគ្រឹះស្ថានអប់រំ ដើម្បីលើកកម្ពស់វប្បធម៌បង់ពន្ធ

- ការវិវឌ្ឍនៃបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល ក្នុងធុរកិច្ចពហុសាសន៍ និងពាណិជ្ជកម្មអន្តរជាតិ ដែលធ្វើឱ្យកាន់តែស្មុគស្មាញដល់រដ្ឋបាលសារពើពន្ធ ក្នុងការគ្រប់គ្រងការប្រមូលចំណូលប្រកបដោយតម្លាភាព និងអស់សក្ដានុពល និង
- កង្វះសង្គតិភាពក្នុងការកំណត់អត្តសញ្ញាណកម្មរបស់អ្នកជាប់ពន្ធ និងភាពមានកម្រិតនៃការផ្ទេរផ្តង និងចែករំលែកព័ត៌មាន និងទិន្នន័យ រវាងស្ថាប័នរដ្ឋ និងដៃគូពាក់ព័ន្ធសម្រាប់ផ្ទៀងផ្ទាត់ប្រតិបត្តិការ និងវាយតម្លៃហានិភ័យនៃអនុលោមភាពអ្នកជាប់ពន្ធ ដែលធ្វើឱ្យការគ្រប់គ្រងការប្រមូលចំណូលមានភាពពិបាក មិនអស់សក្ដានុពល និងប្រឈមនឹងហានិភ័យខ្ពស់ក្នុងការបាត់បង់ចំណូល។

**ដើម្បីដោះស្រាយបញ្ហាខាងលើ និងជំរុញការចាប់យកបរិវត្តកម្មរដ្ឋបាលសារពើពន្ធឌីជីថល ដូចបានដាក់ចេញខាងលើ យុទ្ធសាស្ត្រនេះការដាក់ចេញនូវវិធានការគាំទ្រមួយចំនួន ដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- សហការជាមួយបណ្ដាគ្រឹះស្ថានសិក្សា ដោយអនុវត្តកម្មវិធីបណ្ដុះបណ្ដាល ស្ដីពីវប្បធម៌ពន្ធដារក្នុងកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា និងបង្កើនមាតិកាវីដេអូណែនាំទៅកាន់អ្នកជាប់ពន្ធតាមរយៈបណ្ដាញសង្គមនានា ឬគេហទំព័ររបស់ អ.ព.ដ. ដោយណែនាំអំពីនីតិវិធី ផ្សេងៗរួមមានដូចជា វិធីសាស្ត្រនៃការបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធអនឡាញ និងការស្នើសុំវិញ្ញាបនបត្រអ្នកជាប់ពន្ធ ជាដើម
- ពង្រឹងសង្គតិភាព នៃអត្តសញ្ញាណកម្មអ្នកជាប់ពន្ធរវាង អ.ព.ដ. និង អ.គ.រ. និងស្វ័យប្រវត្តិកម្មក្នុងការផ្ទេរផ្ដង និងផ្ទៀងផ្ទាត់ទិន្នន័យ រវាងអគ្គនាយកដ្ឋានទាំងពីរ ក្នុងកម្មវត្ថុពង្រឹងអនុលោមភាពពន្ធលើពាណិជ្ជកម្មឆ្លងកាត់ច្រកព្រំដែន ដើម្បីចៀសសវាងការគេចវេះ និងក្លែងបន្លំពន្ធ និង
- បន្តរៀបចំជាទៀងទាត់នូវការសិក្សាលើកម្រិតនៃការពេញចិត្តអ្នកជាប់ពន្ធ (Satisfaction survey) លើសេវាអ្នកជាប់ពន្ធ ដើម្បីកែលម្អសេវាកម្មអ្នកជាប់ពន្ធ។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- សិក្សាសមិទ្ធិលទ្ធភាពក្នុងការកសាង និងអភិវឌ្ឍអត្តសញ្ញាណឌីជីថលរបស់អ្នកជាប់ពន្ធ ដែលមានការចូលរួម និងអាចចែករំលែកក្នុងចំណោមអន្តរស្ថាប័ននៃរាជរដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធនានា សំដៅកាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធក្នុងការរាយការណ៍ និងបំពេញបែបបទនីតិវិធីរដ្ឋបាលនានា ព្រមទាំងអាចកាត់បន្ថយបន្ទុកការងារដល់រដ្ឋបាលសារពើពន្ធក្នុងការផ្ទៀងផ្ទាត់ព័ត៌មានអ្នកជាប់ពន្ធ
- សិក្សាសមិទ្ធិលទ្ធភាពរៀបចំក្របខ័ណ្ឌថ្នាលព័ត៌មានឌីជីថល (Framework for digital platforms) សម្រាប់ប្រមូល និងផ្ទៀងផ្ទាត់ព័ត៌មានពាក់ព័ន្ធនឹងប្រាក់ចំណូលរូបវន្តបុគ្គល និងក្រុមហ៊ុន ការផ្ដល់សេវាស្នាក់នៅ ការធ្វើដំណើរ និងសេវាផ្សេងទៀត និងប្រតិបត្តិការពាណិជ្ជកម្មឆ្លងដែន (Cross-border exchange of tax information) ដោយមានកិច្ចសហការរវាងរដ្ឋាភិបាល និងរដ្ឋាភិបាលនៃប្រទេសដៃគូ តាមរយៈថ្នាលឌីជីថលរួម (Single portal digital platform)

ដែលអាចរាយការណ៍ផ្ទាល់ទៅរដ្ឋបាលពន្ធ និងផ្ទៀងផ្ទាត់ដោយស្វ័យប្រវត្តិលើកាតព្វកិច្ចបង់ពន្ធ និងការស្នើសុំការលើកលែងពន្ធ និង

- ➢ រៀបចំនូវក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីគ្រប់គ្រងការចែករំលែក និងប្រើប្រាស់ព័ត៌មាន និងទិន្នន័យពាក់ព័ន្ធរវាងរដ្ឋបាលសារពើពន្ធ និងអន្តរក្រសួង-ស្ថាប័ន ដើម្បីគាំទ្រដល់ការធ្វើសង្គតិភាពអត្តសញ្ញាណនៃអ្នកជាប់ពន្ធ ការអភិវឌ្ឍអត្តសញ្ញាណឌីជីថល និងការរៀបចំក្របខ័ណ្ឌថ្នាលព័ត៌មានឌីជីថលសម្រាប់ប្រមូល និងផ្ទៀងផ្ទាត់ព័ត៌មានពាក់ព័ន្ធរបស់អ្នកជាប់ពន្ធ ដោយត្រូវធានានូវសុវត្ថិភាពទិន្នន័យ ការពារ និងប្រយុទ្ធប្រឆាំងនឹងការជ្រៀតចូលក្នុងប្រព័ន្ធពីសំណាក់ជនខាងក្រៅ ដោយគ្មានការអនុញ្ញាត ការបំពានទិន្នន័យក្នុងប្រព័ន្ធ និងការប្រើប្រាស់ទិន្នន័យអ្នកជាប់ពន្ធដោយខុសច្បាប់។

### ៤.២. ការធ្វើទំនើបកាវូបនីយកម្ម នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

រាជរដ្ឋាភិបាលបាននិងកំពុងបន្តអនុវត្តវិធានការដែលនៅសេសសល់ ក៏ដូចជាដាក់ចេញនូវទិសដៅសម្រាប់អនុវត្តក្នុងជំហានបន្ទាប់ ក្នុងកិច្ចការកែទម្រង់រដ្ឋបាលគយ។ ទន្ទឹមនឹងការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ និងទិសដៅរយៈពេល ៥ ឆ្នាំខាងមុខ ការធ្វើទំនើបកាវូបនីយកម្មគយ មានគោលបំណង **ពង្រឹងប្រសិទ្ធភាពរដ្ឋបាលគយ និងធ្វើស្វ័យប្រវត្តិកម្ម និងសមាហរណកម្មប្រព័ន្ធ និងនីតិវិធីគយ ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជំរុញកិច្ចសម្រួលពាណិជ្ជកម្ម ពង្រឹងភាពប្រកួតប្រជែងកម្ពុជា និងបង្កើនអត្ថប្រយោជន៍ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី** ។ ក្នុងន័យនេះ **យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** នឹងបន្តធ្វើទំនើបកាវូបនីយកម្មរដ្ឋបាលគយ និងរដ្ឋាករកម្ពុជា ដោយផ្តោតសំខាន់លើ ១)-កិច្ចសម្រួលពាណិជ្ជកម្ម ២)-ការពង្រឹងអភិបាលកិច្ច និងស្ថាប័ន និង ៣)-មុខងារគាំទ្រ ។

#### ក. កិច្ចសម្រួលពាណិជ្ជកម្ម

ការបន្តធ្វើឱ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្ម នឹងជួយកាត់បន្ថយបន្ទុកចំណាយពេលនិងភាពស្មុគស្មាញដល់ក្រុមហ៊ុន/ធុរជន ក្នុងការបំពេញនីតិវិធីគយសម្រាប់ពាណិជ្ជកម្មអន្តរជាតិពាក់ព័ន្ធការនាំចេញ-នាំចូល និងឆ្លងកាត់ ព្រមទាំងជួយជំរុញសកម្មភាពសេដ្ឋកិច្ចតាមរយៈ ការធ្វើសាមញ្ញកម្ម សុខដុមនីយកម្ម ស្តង់ដានីយកម្ម (standardization) និងទំនើបកម្មនីតិវិធី និងកិច្ចប្រតិបត្តិការគយ។ ផ្អែកតាមការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ អ.គ.រ. បានខិតខំប្រឹងប្រែង និងបានរួមចំណែកកាត់បន្ថយបន្ទុកចំណាយពេល និងភាពស្មុគស្មាញ បានច្រើនដល់ធុរជន លើការពន្លឿនសកម្មភាពពាណិជ្ជកម្មក្នុងការនាំចេញ-នាំចូលទំនិញឆ្លងកាត់ព្រំដែន។

ដើម្បីសម្រេចបាននូវគោលបំណងនៃការជំរុញកិច្ចសម្រួលពាណិជ្ជកម្ម អ.គ.រ. បានកសាងនូវសមិទ្ធផលសំខាន់ៗរួមមាន ការកែលម្អវិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យជ្រើសរើសសូចនាករហានិភ័យក្នុងការកំណត់មុខសញ្ញាទំនិញនាំចេញនាំចូល និងឆ្លងកាត់ ការធ្វើវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងសម្គាល់ដើមកំណើតទំនិញ ការដាក់ឱ្យអនុវត្តកិច្ចដំណើរការលិខិតអនុញ្ញាតគយតាមប្រព័ន្ធបញ្ជរតែមួយជាតិ និងបានពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ឈានដល់ដំណាក់កាលទី៣ ការដាក់ពាក្យស្នើសុំ

ការអនុញ្ញាតផ្សេងៗតាមប្រព័ន្ធអេឡិចត្រូនិក ការកសាង និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់នូវមុខងារថ្មីៗ នៃប្រព័ន្ធស្វ័យប្រវត្តិកម្មគយ ការធ្វើសមាហរណកម្មមុខងារប្រតិវេទន៍គយសង្ខេប និងប្រព័ន្ធគ្រប់គ្រងហានិភ័យគយទៅក្នុងប្រព័ន្ធអាស៊ីគូដា ការដាក់ឱ្យអនុវត្តសាកល្បងនូវមុខងារបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-Arrival Processing) ការដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស (GTAS) ការដាក់ឱ្យអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (AEO) និងការអនុវត្តវិធានការលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាស ធុនតូចនិងមធ្យម (SMEs) ជាដើម។ លើសពីនេះ អ.គ.រ. បានតភ្ជាប់ប្រព័ន្ធបញ្ជរតែមួយជាតិ ទៅនឹងប្រព័ន្ធបញ្ជរតែមួយរបស់អាស៊ាន (ASW) និងបានចូលរួមអនុវត្តប្រព័ន្ធឆ្លងកាត់គយអាស៊ាន (ACTS)។

ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់យ៉ាងណាក្តី ដើម្បីបន្តលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជាបន្ថែមទៀត អ.គ.រ. នឹងបន្តដោះស្រាយបញ្ហាមួយចំនួន ដូចខាងក្រោម៖

- គម្រោងបញ្ជរតែមួយជាតិ ត្រូវបានដាក់ឱ្យអនុវត្ត ប៉ុន្តែនៅពុំទាន់ពេញលេញនៅឡើយ ដោយសារក្រសួង-ស្ថាប័នមួយចំនួន ពុំទាន់ផ្តល់ឯកសារពាក់ព័ន្ធសម្រាប់ការសិក្សានីតិវិធី, ពុំទាន់ទទួលយកវំហូរនីតិវិធីដែលបានរៀបចំ និងពុំទាន់មានបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់អនុវត្តជាដើម
- នីតិវិធីក្នុងការស្នើសុំវិញ្ញាបនបត្រសមាជិកក្រុមធុរជនល្អបំផុតនៅមានភាពស្មុគស្មាញ និងពឹងផ្អែកលើការប្រើប្រាស់ឯកសាររឹងក្នុងការស្នើសុំ[1] ហើយគិតទល់បច្ចុប្បន្ននេះ ក្រុមហ៊ុនដែលត្រូវបានទទួលស្គាល់ជាធុរជនល្អបំផុត នៅមានចំនួនតិចតួច ខណៈដែលកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (Authorized Economic Operator - AEO) ទើបតែត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ ២០២៣
- មុខងារបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-Arrival Processing) មិនទាន់ត្រូវបានដាក់ឱ្យអនុវត្តពេញលេញទាំងសម្រាប់ការដឹកជញ្ជូនតាមប្រៃសណីយ៍ តាមផ្លូវអាកាស និងតាមផ្លូវទឹក
- ប្រព័ន្ធអាស៊ីគូដានៅមិនទាន់គ្របដណ្តប់នីតិវិធីគយពាក់ព័ន្ធទាំងស្រុងនៅឡើយ ដូចជា ទំនិញឆ្លងកាត់ និងការគ្រប់គ្រងមណ្ឌលសន្និធិគយ ជាដើម
- វិសាលភាពនៃការប្រើប្រាស់មុខងារទូទាត់ប្រាក់តាមមធ្យោបាយអេឡិចត្រូនិក (e-payment) មិនទាន់មានភាពទូលំទូលាយនៅឡើយ ពោលគឺធុរជន/ដើងសារគយភាគច្រើន នៅតែបន្តប្រើបង្កាន់ដៃបង់ពន្ធក្នុងទម្រង់ក្រដាស
- អនុលោមភាពនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយនៅមានកម្រិតនៅឡើយ និង
- ដំណើរការស្នើសុំបង្វិលសងនូវប្រាក់ពន្ធ និងអាករគយ នៅអនុវត្តជាទម្រង់ក្រដាស។

**ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

[1] តម្រូវការឯកសាររឹង៖ បញ្ជីលក្ខខណ្ឌ និងឯកសារតម្រូវ, ពាក្យស្នើសុំ, លិខិតបញ្ជាក់និងធានាអះអាង, លិខិតសុំតែងតាំងនិងផ្ទេរសិទ្ធិជូនបុគ្គលិកទំនាក់ទំនងរបស់ក្រុមហ៊ុន, និងបញ្ជីរាយនាមបុគ្គលិកទទួលបានសិទ្ធិពីប្រធានក្រុមហ៊ុន

- បន្តជំរុញការអនុវត្តវិធានការកែទម្រង់គន្លឹះ និងមុតស្រួចផ្នែកកិច្ចសម្រួលពាណិជ្ជកម្ម ក្រោមដែនសមត្ថកិច្ចគយ ដែលបានដាក់ចេញ ក្នុងវេទិការាជរដ្ឋាភិបាលផ្នែកឯកជនលើកទី ១៩ នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២៣
- បន្តជំរុញក្រសួង-ស្ថាប័នពាក់ព័ន្ធ ចូលរួមអនុវត្តប្រព័ន្ធបញ្ចរតែមួយជាតិ ឱ្យបានពេញលេញ និងជំរុញបញ្ចប់មុខងារពាក់ព័ន្ធដែលនៅសេសសល់ រួមទាំងពង្រឹងការតាមដាន និងវាយតម្លៃការអនុវត្តគម្រោង
- ជំរុញការអនុវត្តយន្តការផ្តល់ការលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាសធុនតូច និងមធ្យម
- ផ្តល់សេវាធ្វើការបន្ថែមម៉ោងរបស់មន្ត្រីគយនៅពេលយប់នៅតាមផៃស្ងួតដោយរៀបចំកំណត់ប្រាក់ម៉ោងឱ្យបានសមរម្យ ដើម្បីពន្លឿនការនាំចេញ និង
- សិក្សាលទ្ធភាពក្នុងការអភិវឌ្ឍមុខងារជំនួសឱ្យហត្ថលេខាឌីជីថលសម្រាប់នីតិវិធីគយ ដើម្បីផ្តល់បន្ថែមនូវសុវត្ថិភាព និងភាពងាយស្រួល ក្នុងការផ្ទៀងផ្ទាត់ប្រតិបត្តិការ
- ជំរុញការអនុវត្តពេញលេញនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-Arrival Processing) តាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីបង្កើនប្រសិទ្ធភាពនៃការងារគ្រប់គ្រងហានិភ័យគយ កាត់បន្ថយពេលឆ្លងកាត់ព្រំដែន និងចំណាយប្រតិបត្តិការផ្សេងៗ
- ជំរុញបង្កើនចំនួន និងសម្រួលនីតិវិធីដល់ការស្នើសុំវិញ្ញាបនបត្រសមាជិកក្រុមធុរជនល្អបំផុត (Best Traders) និងប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (AEO) ក៏ដូចជាកាត់បន្ថយតម្រូវការឯកសាររឹងក្នុងការស្នើសុំ
- ជំរុញឱ្យមានការប្រើប្រាស់មុខងារទូទាត់ប្រាក់តាមមធ្យោបាយអេឡិចត្រូនិក (E-payment) ឱ្យបានជាអតិបរមា និងបន្តពង្រីកវិសាលភាពនៃគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ដើម្បីអនុវត្តមុខងារនៃប្រព័ន្ធនេះ
- ពិនិត្យលទ្ធភាពក្នុងការកែសម្រួលតម្លៃឯកតា និងរយៈពេលនៃការផ្គត់ផ្គង់សេវាគយ (Service fee) ឱ្យស្របតាមតាមការវិវឌ្ឍនៃសេដ្ឋកិច្ច-សង្គមកម្ពុជា និងឧត្តមានុវត្តន៍អន្តរជាតិ និងក្នុងតំបន់
- ធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីបង្វិលសងវិញនូវប្រាក់ពន្ធ-អាករគយតាមប្រព័ន្ធអេឡិចត្រូនិក (E-refund) ឱ្យមានស្វ័យប្រវត្តិកម្ម និងឌីជីថលូបនីយកម្ម
- បន្តចូលរួមជំរុញការអនុវត្តគោលការណ៍អធិការកិច្ចតែមួយ និងទីលានត្រួតពិនិត្យគយរួមគ្នាជាមួយ ភាគីប្រទេសវៀតណាម និងថៃ នៅច្រកព្រំដែនអន្តរជាតិបាវិត និងប៉ោយប៉ែត និង
- ធ្វើវិសិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យគយ តាមរយៈការបំពាក់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) និងបច្ចេកវិទ្យាទំនើបផ្សេងទៀត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យអនុលោមភាពគយ និងពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល ។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- ធ្វើវិសិដ្ឋកម្មប្រព័ន្ធអាស៊ីគូដា និងជំរុញការប្រើប្រាស់ប្រព័ន្ធនេះឱ្យទៅជាប្រព័ន្ធស្នូល តាមរយៈការធ្វើសន្ទានកម្មជាមួយប្រព័ន្ធអេឡិចត្រូនិកពាក់ព័ន្ធ និង

➢ សិក្សា និងរៀបចំយន្តការគ្រប់គ្រងថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-commerce platform) ដើម្បីប្រមូលពន្ធ-អាករគយ លើទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន ឱ្យកាន់តែមានប្រសិទ្ធភាព។

## ខ. ការពង្រឹងអភិបាលកិច្ច និងស្ថាប័ន

ការពង្រឹងអភិបាលកិច្ច និងស្ថាប័ន គឺជាភារកិច្ចគន្លឹះរបស់ អ.គ.រ. ក្នុងការលើកកម្ពស់អនុលោមភាព និងធានាបាននូវប្រសិទ្ធភាពនៃការប្រមូលចំណូលផង និងការអនុវត្តរបបពាណិជ្ជកម្មអន្តរជាតិផង។ យន្តការនៃការតាមដាន និងវាយតម្លៃរដ្ឋបាលគយ ការធានាបាននូវតម្លាភាពនិងគណនេយ្យភាព សុចរិតភាព និងការគោរពវិន័យ ការពង្រឹងអនុលោមភាពនិងការអនុវត្តច្បាប់ ការវិភាគមុខងារ និងកែសម្រួលរចនាសម្ព័ន្ធ គឺជាការងារស្នូលក្នុងការកែលម្អអភិបាលកិច្ចនិងស្ថាប័ន និងចូលរួមសម្រួលពាណិជ្ជកម្មនៅដើមទី។

តាមរយៈការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ នាពេលកន្លងមក បានបង្ហាញថា អភិបាលកិច្ចរបស់រដ្ឋបាលគយមានភាពល្អប្រសើរឡើងច្រើន ដោយ អ.គ.រ. បានបញ្ចប់ការរៀបចំ និងផ្សព្វផ្សាយណែនាំការអនុវត្តយុទ្ធសាស្ត្រគយស្តីពីអនុលោមភាព និងការអនុវត្តច្បាប់ឆ្នាំ ២០២០-២០២៣ បានបញ្ចប់ការរៀបចំ និងផ្សព្វផ្សាយណែនាំយុទ្ធសាស្ត្រកែទម្រង់ និងទំនើបកម្មគយឆ្នាំ ២០២៤-២០២៨ និងបានជំរុញការអនុវត្តកម្រិតផ្តន្ទាទោស ដោយបញ្ជូនរាល់បទល្មើសគយដែលពុំអាចសម្រុះសម្រួលដោះស្រាយដោយរដ្ឋបាលគយទៅកាន់តុលាការ។

ទោះបីជាសម្រេចបាននូវសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់នាពេលកន្លងមកក៏ដោយក៏ អ.គ.រ. នៅប្រឈមនឹងបញ្ហាមួយចំនួនដែលត្រូវដោះស្រាយ ដូចខាងក្រោម៖

- ភាពមានកម្រិតនៃយន្តការវាយតម្លៃប្រសិទ្ធភាព និងការអនុវត្តការងាររបស់មន្ត្រីគយ និងសូចនាករគន្លឹះក្នុងការតាមដានប្រសិទ្ធភាពការងាររបស់បណ្តាការិយាល័យគយ និងរង្វាក់តាមច្រកព្រំដែន និង
- ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគាំទ្រការងារជំរុញការអនុវត្តច្បាប់ នៅមានកម្រិត។

**ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួន ដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥***

➢ កំណត់សូចនាករគន្លឹះជាក់លាក់ សម្រាប់តាមដាន និងវាយតម្លៃប្រសិទ្ធភាព នៃសកម្មភាពអនុវត្តច្បាប់ និងការអនុវត្តការងាររបស់មន្ត្រីគយ ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃរដ្ឋបាលគយ និង

➢ កំណត់ និងអនុវត្តវិធានការរដ្ឋបាលលើមន្ត្រីគយដែលបំពានក្រមប្រតិបត្តិវិជ្ជាជីវៈ ច្បាប់ និងបទ-ប្បញ្ញត្តិការងារផ្ទៃក្នុងពាក់ព័ន្ធ។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨***

➢ បន្តជំរុញការកែលម្អប្រព័ន្ធតាមដាន និងវាយតម្លៃ ប្រសិទ្ធភាពការងាររបស់មន្ត្រីគយ និង

➢ ពង្រឹងអភិបាលកិច្ច និងស្ថាប័ន តាមរយៈការវិភាគមុខងារ និងកែសម្រួលរចនាសម្ព័ន្ធ។

### គ. មុខងារគាំទ្រ

មុខងារគាំទ្រ គឺសម្រាប់គាំទ្រដល់មុខងារប្រតិបត្តិការស្នូល ដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការផ្តល់សេវាតាមរយៈប្រព័ន្ធអេឡិចត្រូនិកដល់អ្នកជាប់ពន្ធ ក៏ដូចជាសមត្ថភាពក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន។ មុខងារគាំទ្រផ្តោតសំខាន់លើ ការជំរុញការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ អ.គ.រ. និងពង្រឹងការគ្រប់គ្រងជាយុទ្ធសាស្ត្រក្នុងគោលបំណង ១)-បង្ការ និងបង្ក្រាបបទល្មើសគយ និងពង្រឹងការងារសវនកម្មគយ ២)-បន្តអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ សម្រាប់គាំទ្រដល់ការអភិវឌ្ឍស្ថាប័ន និងពង្រឹងការគ្រប់គ្រង ក៏ដូចជាកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃរចនាសម្ព័ន្ធថ្មី និង ៣)-បង្កើតបរិយាកាសពាណិជ្ជកម្មឌីជីថលពេញលេញ ដែលមានមូលដ្ឋានទិន្នន័យរឹងមាំផ្អែកលើឯកសារអេឡិចត្រូនិក និងពង្រឹងសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធ ដើម្បីសម្រួលដល់កិច្ចការពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់។

អ.គ.រ. បានអនុវត្តវិធានការនៃការគ្រប់គ្រងបែបយុទ្ធសាស្ត្រ ដោយមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ស្របទៅនឹងការវិវឌ្ឍនៃបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងសម្រេចបាននូវលទ្ធផលសំខាន់ៗរួមមាន ការបង្កើនចំនួន និងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីសវនកម្មគយជាបន្តបន្ទាប់ ក៏ដូចជាការពង្រីកបន្ថែមនូវអង្គភាពសវនកម្មគយ ការតាមដាន និងវាយតម្លៃប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបបទល្មើសគយតាមបណ្តាអង្គភាពគយ និងរដ្ឋាករពាក់ព័ន្ធជាប្រចាំ និងបានបញ្ចប់ការរៀបចំ និងផ្សព្វផ្សាយណែនាំការអនុវត្តយុទ្ធសាស្ត្របច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ២០២០-២០២៤។ ទន្ទឹមនឹងសមិទ្ធផលសម្រេចបាន អ.គ.រ. នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តដោះស្រាយ ដូចខាងក្រោម៖

- ចំនួនសវនកម្មក្រោយពេលបញ្ចេញទំនិញដែលបានចុះអនុវត្តនៅមានកម្រិតទាប ធៀបនឹងចំនួនដែលបានគ្រោងទុក
- ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ អ.គ.រ. នៅមានកម្រិត និងមិនទាន់ត្រូវបានធ្វើសន្ទានកម្មពេញលេញ ដែលមិនទាន់អាចឆ្លើយតបបានគ្រប់គ្រាន់នៅឡើយ ជាមួយនឹងការវិវឌ្ឍនៃបច្ចេកវិទ្យាថ្មី និងការកើនឡើងនៃពាណិជ្ជកម្មអន្តរជាតិ ក៏ដូចជាប៉ះពាល់ដល់ការពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពការងារ
- សមត្ថភាពមន្ត្រីជំនាញបច្ចេកទេសនៅមានកម្រិត (រួមទាំងផ្នែកបច្ចេកវិទ្យាគមនាគមន៍) នៅមិនទាន់មានចំនួនសមស្របតាមទំហំការងារ និងមិនទាន់អាចឆ្លើយតបបានទៅនឹងគ្រប់ទម្រង់នៃបទល្មើសគយ ជាពិសេសក្នុងរូបភាពថ្មីៗ និងកាន់តែស្មុគស្មាញ
- យន្តការផ្លាស់ប្តូរព័ត៌មាន ទិន្នន័យ និងកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនៅមានភាព-ស្មុគស្មាញ និងមិនទាន់ឆ្លើយតបទៅនឹងតម្រូវការបានពេញលេញនៅឡើយ
- ការដាក់ស្នើបណ្តឹងតវ៉ារបស់ធុរជនដែលទទួលរងនូវទោសទណ្ឌ ឬការឃាត់ទុកទំនិញ ឬវត្ថុផ្សេងៗ ធ្វើឡើងជាទម្រង់លាយលក្ខណ៍អក្សរ និងតម្រូវឱ្យផ្ញើទៅកាន់ អ.គ.រ. ហើយការឆ្លើយតបនឹងបណ្តឹងតវ៉ាទាំងនោះ នៅមានកម្រិត និង

- អ.គ.រ. មិនទាន់មានមន្ទីរពិសោធន៍សម្រាប់ត្រួតពិនិត្យគុណភាពទំនិញ ដែលអាចពន្លឿនដល់ការធ្វើបែបបទបញ្ចេញទំនិញពីគយ និងធានាបានពេញលេញដល់សុខុមាលភាពអ្នកប្រើប្រាស់។

**ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥***

- បន្តជំរុញការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ឱ្យស្របតាមផែនការ ព្រមទាំងបង្កើនចំនួនមន្ត្រីនិងអង្គភាពសវនកម្មគយ ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែង
- ពង្រឹងប្រសិទ្ធភាពអនុលោមភាពលើមុខទំនិញជាសក្តានុពលនៃការប្រមូលចំណូល ដូចជាគ្រឿងអេឡិចត្រូនិក និងទំនិញយុទ្ធសាស្ត្រផ្សេងទៀត
- បន្តតាមដាន និងវាយតម្លៃការងារបង្ការ និងបង្ក្រាបបទល្មើសគយ និងពង្រឹងបន្ថែមសមត្ថភាពជំនាញរបស់មន្ត្រី ដើម្បីឆ្លើយតបឱ្យបានជាអតិបរមាទៅនឹងបទល្មើសគយដែលកើតឡើងក្នុងរូបភាពថ្មីៗ និងកាន់តែស្មុគស្មាញ
- សម្រួលយន្តការក្នុងការចែករំលែកព័ត៌មានជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រទេសជាដៃគូពាណិជ្ជកម្មឱ្យមានភាពងាយស្រួល និងឆាប់រហ័ស ក៏ដូចជាពង្រឹងការឆ្លើយតបទៅនឹងតម្រូវការព័ត៌មានដែលបានស្នើសុំ ឱ្យមានប្រសិទ្ធភាព
- រៀបចំយន្តការតាមដាន និងវាយតម្លៃការអនុវត្តវិធានការជំរុញការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ អ.គ.រ. និងផែនការអភិវឌ្ឍន៍ស្ថាប័ន
- បន្តជំរុញការបណ្តុះបណ្តាលអំពីនីតិវិធី ការបំពេញបែបបទគយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគយ និងការផ្តល់អាជ្ញាបណ្ណជើងសាគយ និង
- បង្កើតយន្តការ (hotline) ឆ្លើយតបបញ្ហាពាក់ព័ន្ធការងារគយ និងភាពមិនប្រក្រតីផ្សេងៗ។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨***

- ពង្រឹងសង្គតិភាពនៃលេខអត្តសញ្ញាណកម្មសារពើពន្ធ (VAT TIN) រវាង អ.គ.រ. និង អ.ព.ដ. ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការចែករំលែកព័ត៌មាន និងយន្តការតាមដានទំនិញនាំចូល និងទំនិញលក់ចេញក្នុងស្រុក
- បន្តពង្រឹងសមត្ថភាព និងបង្កើនចំនួនមន្ត្រីជំនាញបច្ចេកទេសផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែង និងការវិវឌ្ឍនៃបច្ចេកវិទ្យាថ្មី
- កសាងយន្តការនិរន្តរភាព និងចីរភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដូចជាពង្រឹងសុវត្ថិភាពមជ្ឈមណ្ឌលផ្ទុកទិន្នន័យរួម និងរៀបចំផែនការសង្គ្រោះប្រព័ន្ធក្នុងករណីមានគ្រោះអាសន្ន
- បន្តជំរុញធ្វើសន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ អ.គ.រ. (ASYCUDA e-Customs Pre-Arrival Processing។ល។) ឱ្យកាន់តែទូលាយ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ
- ធ្វើសាមញ្ញកម្មនីតិវិធី ក្នុងការដាក់បណ្តឹងតវ៉ារបស់ធុរជន និងពង្រឹងយន្តការក្នុងការឆ្លើយតបឱ្យមានភាពគ្រប់ជ្រុងជ្រោយ និងអព្យាក្រឹត និង

➢ ជំរុញបង្កើតមន្ទីរពិសោធន៍គយ សម្រាប់ត្រួតពិនិត្យគុណភាពទំនិញ ដើម្បីពន្លឿនដល់ការធ្វើបែបបទទំនិញពីគយ និងចូលរួមចំណែកដល់ការការពារសុខភាពអ្នកប្រើប្រាស់ និងពង្រឹងការងារបង្ការ និងបង្ក្រាបមុខទំនិញហាមឃាត់ដែលប៉ះពាល់សុខភាព។

# ជំពូកទី៥
# ការធ្វើទំនើបកម្ម និងវិចារណកម្មគោលនយោបាយពន្ធ

ការធ្វើវិចារណកម្មគោលនយោបាយពន្ធ គឺដើម្បីចូលរួមចំណែកក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការកាត់បន្ថយកម្មវិបាកលើសេដ្ឋកិច្ច និងការលើកកម្ពស់ការវិនិយោគ និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា ព្រមទាំងបង្កើនការប្រមូលចំណូលដែលនៅមានសក្តានុពល និងលើកកម្ពស់សមធម៌នៃការបង់ពន្ធ។ យុទ្ធសាស្ត្រកៀរគរចំណូល របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា នឹងដាក់ចេញនូវវិធានការគោលនយោបាយពន្ធរយៈពេលខ្លី និងមធ្យម ដើម្បីរៀបចំកែសម្រួលគោលនយោបាយពន្ធ ព្រមទាំងដាក់ចេញនូវវិធានការគន្លឹះបន្ថែម ក្នុងការដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតមានទៅតាមប្រភេទពន្ធ មានជាអាទិ៍ ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល អាករពិសេស អាករលើតម្លៃបន្ថែម ពន្ធពាក់ព័ន្ធនឹងអចលនទ្រព្យ របបលើកទឹកចិត្តពន្ធក្រោមច្បាប់ស្តីពីវិនិយោគ ការអភិវឌ្ឍសហគ្រាសធុន តូច និងមធ្យម និងពិនិត្យលើប្រភេទពន្ធពីរថ្មីទៀត គឺពន្ធលើសេវាកម្មឌីជីថល និងពន្ធលើការបំភាយកាបូន។

## ៥.១ ពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូល ត្រូវបានអនុវត្តលើអ្នកជាប់ពន្ធនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស និងអ្នកជាប់ពន្ធអនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា។ យោងតាមច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបានបែងចែកជា ៣ ប្រភេទ៖ អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ ផ្អែកតាមផលរបរប្រចាំឆ្នាំក្នុងវិស័យនីមួយៗ និង ទ្រង់ទ្រាយគតិយុត្តរបស់សហគ្រាស ។ល។ ជាមួយគ្នានេះ ពន្ធលើប្រាក់ចំណូល កំណត់យកអត្រាកំណើនតាមថ្នាក់ចំពោះរូបវន្តបុគ្គល និងក្រុមហ៊ុនកម្មសិទ្ធិ (០% ដល់ ២០%) អត្រាថេរ ២០% សម្រាប់នីតិបុគ្គល និងអត្រាថេរ ៣០% សម្រាប់ចំណូលជាប់ពន្ធពាក់ព័ន្ធនឹងធនធានធម្មជាតិ ដូចជាអាជីវកម្មរ៉ែ ព្រៃឈើ មាស និងប្រេងកាត ជាដើម។ ចាប់តាំងពី ការអនុវត្តរបបពន្ធស្វ័យប្រកាសនៅក្នុងឆ្នាំ ២០១៦ មក ការប្រមូលពន្ធលើប្រាក់ចំណូលបានកើនឡើងគួរឱ្យកត់សម្គាល់ ដោយចំណែកនៃពន្ធលើប្រាក់ចំណូលធៀបនឹងចំណូលពន្ធសរុប បានកើនឡើងពី ១៨,៣% នៅក្នុងឆ្នាំ ២០១៧ ដល់ ២៤,៩% នៅក្នុងឆ្នាំ ២០២២[2] ។

ជានិន្នាការក្នុងតំបន់ និងសកល អត្រាពន្ធលើប្រាក់ចំណូល មាននិន្នាការធ្លាក់ចុះជាបន្តបន្ទាប់ ក្នុងគោលបំណងដើម្បីធានានូវឧត្តមភាពនៃការប្រកួតប្រជែងរបស់ប្រទេសនីមួយៗ ក្នុងការទាក់ទាញការវិនិយោគពីបរទេស តាមរយៈការបន្ធូរបន្ថយអត្រាពន្ធលើប្រាក់ចំណូល ដើម្បីគាំទ្រ និងលើកកម្ពស់ការធ្វើអាជីវកម្ម នៅក្នុងអំឡុងពេលនៃការស្តារសេដ្ឋកិច្ចឡើងវិញបន្ទាប់ពីរងនូវផលប៉ះទង្គិចពីវិបត្តិបណ្តាលមកពីការរីករាលដាលនៃ

[2] ការគណនារបស់ក្រុមការងារនៃអគ្គនាយកដ្ឋានគោលនយោបាយ

ជំងឺកូវីដ-១៩។ ជាមួយគ្នានេះដែរ ការប្រកួតប្រជែងក្នុងការទាក់ទាញការវិនិយោគ តាមរយៈ ការបន្ធូរបន្ថយអត្រាពន្ធលើប្រាក់ចំណូលឱ្យកាន់តែទាបទៅៗ (race to the bottom) និងការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ចឌីជីថល និងសកលភាវូបនីយកម្ម បានផ្តល់បរិយាកាសអំណោយផលដល់សហគ្រាសពហុជាតិសាសន៍ក្នុងការបង្វែរផ្ទេរប្រាក់ចំណូលឆ្លងដែន (cross-border profit shifting) ដើម្បីបង្កើនប្រាក់ចំណេញតាមរយៈការគេចវេះពន្ធ និងបង់ពន្ធក្នុងប្រទេសដែលមានបន្ទុកពន្ធទាប។ ការណ៍នេះ បាននិងកំពុងដាក់សម្ពាធខ្លាំងទៅលើប្រព័ន្ធពន្ធលើប្រាក់ចំណូលប្រពៃណីនៃប្រទេសនីមួយៗ ក្នុងការប្រមូលពន្ធលើប្រាក់ចំណូល និងជំរុញឱ្យអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) សហការជាមួយនឹងក្រុមប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់ធំទាំង២០ (G-20) បង្កើតនូវគម្រោង Base Erosion Profit Shifting Project (ហៅកាត់ថា BEPS Project) ហើយបានដាក់ឱ្យអនុវត្តវិធីសាស្ត្រពីរសសរស្តម្ភ (2-Pillar Solution) ដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតចេញពីកំណើនសកម្មភាពឌីជីថលូបនីយកម្មនៃសេដ្ឋកិច្ច ដែលក្នុងនោះមានសសរស្តម្ភទី ២ (Pillar Two) សំដៅទៅលើគំនិតផ្តួចផ្តើមជាសកលក្នុងការផ្តោតលើការកំណត់វិធាននៃការអនុវត្តពន្ធលើប្រាក់ចំណូល ហៅថា "Global Anti-Base Erosion (GloBE) Rules" ដែលកំណត់ពន្ធអប្បបរមាជាសកល (Global Minimum Tax) នៃពន្ធលើប្រាក់ចំណូលក្នុងអត្រាប្រសិទ្ធភាពពន្ធ (effective tax rate) ១៥% សម្រាប់សហគ្រាសពហុជាតិសាសន៍ ដែលមានប្រាក់ចំណូលសរុបយ៉ាងតិច ៧៥០ លានអឺរ៉ូ។ ជាក់ស្តែង ប្រទេសថៃគ្រោងនឹងអនុវត្តពន្ធអប្បបរមាជាសកលនេះ ចាប់ដើមឆ្នាំ២០២៥ នេះតទៅ។

ហេតុដូចនេះ ការអនុវត្តវិធានការនេះ រួមផ្សំជាមួយនឹងនិន្នាការបន្តធ្លាក់ចុះនៃអត្រាពន្ធលើប្រាក់ចំណូលក្នុងតំបន់ និងសកល អាចផ្តល់ឱកាសឱ្យកម្ពុជាប្រមូលពន្ធលើប្រាក់ចំណូលបន្ថែមពីសហគ្រាសបុត្រសម្ព័ន្ធរបស់សហគ្រាសពហុជាតិនៅកម្ពុជា ប៉ុន្តែក៏អាចជះឥទ្ធិពលលើឧត្តមភាពនៃការប្រកួតប្រជែងក្នុងការទាក់ទាញការវិនិយោគពីបរទេសមកកម្ពុជាជាពិសេសវិនិយោគពីសហគ្រាសពហុជាតិសាសន៍ ដែលមានប្រាក់ចំណូលសរុបយ៉ាងតិច ៧៥០ លានអឺរ៉ូ ខណៈដែលប្រទេសក្នុងតំបន់ និងសកល ក៏កំពុងប្រកួតប្រជែងក្នុងការទាក់ទាញវិនិយោគ ទាំងវិនិយោគក្នុងស្រុក និងវិនិយោគក្រៅស្រុក។ ការណ៍នេះ តម្រូវឱ្យមានការពិនិត្យឡើងវិញនូវអត្រាពន្ធលើប្រាក់ចំណូលជាក់លាក់ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន និងការសិក្សាពីបច្ច័យនៃគំនិតផ្តួចផ្តើមនេះ លើការប្រមូលចំណូលពន្ធលើប្រាក់ចំណូល និងការអនុវត្តរបបលើកទឹកចិត្តពន្ធក្រោមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- សិក្សាពីបច្ច័យនៃការអនុវត្ត Inclusive Framework on Base Erosion Profit Shifting Project លើការប្រមូលចំណូលពន្ធលើប្រាក់ចំណូល និងការអនុវត្តរបបលើកទឹកចិត្តពន្ធក្រោមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង
- ពិនិត្យ និងពង្រឹងយន្តការអនុវត្តវិធានបង្វែរថ្លៃ (Transfer Pricing Rules) ជាពិសេសចំពោះសហគ្រាសបុត្រសម្ព័ន្ធ និងអ្នកជាប់ពន្ធនិវាសនជនដែលកំពុងទទួលបានការលើកទឹកចិត្តពន្ធ។

*វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖*

- ពិនិត្យមើលឡើងវិញនូវអត្រាពន្ធលើប្រាក់ចំណូល និងរបបលើកទឹកចិត្តពន្ធ ក្នុងបរិបទនៃការអនុវត្តអត្រាពន្ធអប្បបរមាជាសកលនៃពន្ធលើប្រាក់ចំណូល ដើម្បីធានាឧត្តមភាពនៃការប្រកួតប្រជែងក្នុងការទាក់ទាញការវិនិយោគពីបរទេសមកកម្ពុជា និងរក្សាឱ្យបាននូវចំណូលពន្ធលើប្រាក់ចំណូល។

## ៥.២ ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល

នាពេលបច្ចុប្បន្ន ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល មិនត្រូវបានអនុវត្តពេញលេញនៅឡើយ ដែលអ្នកជាប់ពន្ធរូបវន្តបុគ្គលមិនទាន់ត្រូវបានតម្រូវឱ្យដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធប្រចាំឆ្នាំ ។ យ៉ាងណាមិញ កម្ពុជាបាននិងកំពុងអនុវត្តពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល រួមមាន៖ ១)-ពន្ធលើប្រាក់បៀវត្ស ក្នុងអត្រាកំណើនតាមថ្នាក់ ២)-ពន្ធកាត់ទុក (អត្ថប្រយោជន៍បន្ថែម ចំណូលពីការបំពេញសេវាបច្ចេកទេស ភាគលាភ ការប្រាក់ សួយសារ ចំណូលពីការជួល និងប្រាក់ចំណូលផ្សេងៗ) ក្នុងអត្រាថេរផ្សេងៗគ្នាទៅតាមប្រភេទចំណូលជាប់ពន្ធ និង ៣)-ពន្ធលើចំណេញមូលធន ក្នុងអត្រាថេរ (២០ ភាគរយ) ដែលត្រូវរាជរដ្ឋាភិបាលពន្យារពេលក្នុងការអនុវត្ត ដែលការអនុវត្តនេះ មិនទាន់អាចធានាបាននូវការប្រមូលចំណូលពន្ធប្រកបដោយប្រសិទ្ធភាព និងការលើកកម្ពស់សមធម៌នៃការបង់ពន្ធ ដោយសារកង្វះខាតនៃប្រព័ន្ធពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គលដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ ក្របខ័ណ្ឌគោលនយោបាយសម្រាប់ត្រៀមអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពីខែមីនា ឆ្នាំ២០២៣។ ក្នុងនោះ ក្របខ័ណ្ឌគោលនយោបាយនេះ មានចក្ខុវិស័យ "ប្រែក្លាយប្រព័ន្ធពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ឱ្យមានលក្ខណៈទំនើប គ្រប់ជ្រុងជ្រោយ និងឆ្លើយតបនឹងដំណាក់កាល នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ក្នុងបរិការណ៍នៃការប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មសកល"។ ក្នុងការសម្រេចបានចក្ខុវិស័យនេះ ក្របខ័ណ្ឌគោលនយោបាយនេះ បានកំណត់គោលបំណងក្នុង "ការកសាងប្រព័ន្ធពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ដើម្បីចូលរួមកៀរគរចំណូលក្នុងស្រុកប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាប្រកបដោយប្រសិទ្ធភាព" ព្រមទាំងកំណត់នូវអភិក្រមនៃការអភិវឌ្ឍជាដំណាក់កាល ដោយផ្តោតលើបីដំណាក់កាល គឺ៖ ការត្រៀមលក្ខណៈអនុវត្ត ការធ្វើសុខដុមនីយកម្ម និងការអនុវត្តពេញលេញ។

ដើម្បីឱ្យការអនុវត្តក្របខ័ណ្ឌគោលនយោបាយសម្រាប់ត្រៀមអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គលប្រកប ដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការដោះស្រាយនូវបញ្ហាប្រឈមខាងលើ យុទ្ធសាស្ត្រនេះនឹងជំរុញការអនុវត្តវិធានការទាំងអស់នៃក្របខ័ណ្ឌគោលនយោបាយនេះ ស្របតាមផែនការសកម្មភាពសម្រាប់អនុវត្តក្របខ័ណ្ឌគោលនយោបាយសម្រាប់ត្រៀមអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល។

## ៥.៣ អាករពិសេស

ច្បាប់ស្តីពីសារពើពន្ធ ដែលបានអនុម័តដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ ២០២៣ បានកំណត់នូវអាករពិសេស ដែលត្រូវអនុវត្តលើទំនិញ ឬសេវាកម្មមួយចំនួនដែលមានលក្ខណៈប្រណីត ឬមិនមែនជាតម្រូវការចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃ ឬប៉ះពាល់ដល់សុខភាព សង្គម និង បរិស្ថាន ដែលត្រូវបាននាំចូល ផលិត ឬ

ចែកចាយ ឬផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងទិដ្ឋភាពចំណូល អាករពិសេសជាប្រភពចំណូលជាតិមួយដ៏សំខាន់ ដោយបានចូលរួមចំណែកយ៉ាងធំក្នុងមូលដ្ឋានចំណូលសារពើពន្ធកម្ពុជា។ ជាក់ស្តែង ចំណូលអាករពិសេសបានចូលរួមចំណែកជាមធ្យមប្រមាណជា ២៣%[3] នៃចំណូលសារពើពន្ធសរុប ក្នុងរយៈពេល ៥ ឆ្នាំ ចុងក្រោយនេះ (២០១៨-២០២២) ដែលក្នុងនោះចំណូលអាករពិសេសប្រមាណជាង ៨០% បានពីទំនិញនាំចូល ខណៈដែលការប្រមូលអាករពិសេសក្នុងស្រុករួមចំណែកកាន់តែធំជាងមុន ដោយសារផលិតកម្ម និងសេវាកម្មក្នុងស្រុកមានការកើនឡើងជាលំដាប់។

យ៉ាងណាមិញ ការអនុវត្តគោលនយោបាយអាករពិសេសរបស់កម្ពុជានាពេលបច្ចុប្បន្ន បាននិងកំពុងជួបនូវបញ្ហាប្រឈមមួយចំនួន ដែលនៅមិនទាន់ឆ្លើយតបបានពេញលេញទៅនឹងគោលបំណងនៃការអនុវត្តគោលនយោបាយអាករពិសេស និងការវិវឌ្ឍនៃរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច ដោយសារប្រភេទមុខទំនិញ និងសេវាកម្មដែលជាប់អាករពិសេស មិនទាន់ត្រូវបានធ្វើវិចារណកម្មឱ្យបានគ្រប់ជ្រុងជ្រោយ ប្រព័ន្ធគណនាអាករពិសេស មិនទាន់អាចធានាបាននូវប្រសិទ្ធភាពនៃការប្រមូលអាករពិសេសលើទំនិញ និងសេវាកម្ម ដែលមានតម្លៃទាប ការកំណត់មូលដ្ឋានគិតអាករពិសេសខុសគ្នារវាងទំនិញនាំចូល និងទំនិញផលិតក្នុងស្រុក ដែលមិនទាន់អាចធានាបាននូវភាពស្មើគ្នានៃចំណាយសារពើពន្ធ អត្រាអាករពិសេសនៅកម្ពុជាមានកម្រិតទាបជាងអត្រាអាករពិសេសនៃបណ្តាប្រទេសក្នុងតំបន់ ការផ្លាស់ប្តូរអត្រាអាករពិសេសញឹកញាប់ និងការមិនកំណត់ពេលចូលជាធរមានច្បាស់លាស់ ដែលធ្វើឱ្យប៉ះពាល់ដល់ការរៀបចំផែនការអាជីវកម្មរបស់វិស័យឯកជនដែលជាអ្នកជាប់ពន្ធ បញ្ហាអភិបាលកិច្ច និងអនុលោមភាព ជាដើម។

ក្នុងការឆ្លើយតបនឹងបញ្ហាប្រឈមនេះ គោលការណ៍ណែនាំស្តីពីការកែទម្រង់អាករពិសេស ២០២៤-២០២៨ ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីរួមចំណែកក្នុងការកាត់បន្ថយការប្រើប្រាស់ទំនិញ និងសេវាកម្ម ដែលប៉ះពាល់ដល់សុខភាពរបស់ប្រជាជន សង្គម និងបរិស្ថាន ព្រមទាំងចូលរួមប្រមូលចំណូលជាតិ និងធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ស្របទៅតាមទិសដៅអាទិភាពរបស់រាជរដ្ឋាភិបាល។ ក្នុងនោះគោលការណ៍ណែនាំស្តីពីការកែទម្រង់អាករពិសេសនេះ មានចក្ខុវិស័យ "កសាងប្រព័ន្ធអាករពិសេសគ្រប់ជ្រុងជ្រោយ ដែលរួមចំណែកលើកកម្ពស់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងបរិស្ថានប្រកបដោយចីរភាព" ព្រមទាំងកំណត់គោលដៅចំនួន ៣ រួមមាន៖ ១)-ធានាបាននូវសមធម៌នៃការអនុវត្តអាករពិសេសលើទំនិញ និងសេវាក្នុងស្រុក និងនាំចូល ២)- កាត់បន្ថយផលប៉ះពាល់អវិជ្ជមាន និងហានិភ័យផ្នែកសុខភាព សង្គម និងបរិស្ថាន និង ៣)- ធានានូវភាពអាចទស្សន៍ទាយបាននៃការផ្លាស់ប្តូរអាករពិសេសសម្រាប់ទីផ្សារ និងវិស័យឯកជន។ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ យុទ្ធសាស្ត្រនេះនឹងជំរុញការអនុវត្តវិធានការ ស្របតាមផែនការសកម្មភាពសម្រាប់អនុវត្តគោលការណ៍ណែនាំស្តីពីការកែទម្រង់អាករពិសេស។

### ៥.៤. អាករលើតម្លៃបន្ថែម

ប្រទេសកម្ពុជា បន្តអនុវត្តអាករលើតម្លៃបន្ថែមក្នុងអត្រា ១០% លើការផ្គត់ផ្គង់ជាប់អាករលើទំនិញ និងសេវា ដែលបានកំណត់ដោយច្បាប់ស្តីពីសារពើពន្ធ ដែលតម្លៃជាប់អាករ គឺជាថ្លៃទំនិញ ឬសេវាដែលអ្នកលក់យកពីអ្នកទិញ រួមបញ្ចូលអាករគ្រប់ប្រភេទ លើកលែងអាករលើតម្លៃបន្ថែម ឬតម្លៃគិតពន្ធគយ រួមបញ្ចូល

[3] ការគណនារបស់ក្រុមការងារនៃអគ្គនាយកដ្ឋានគោលនយោបាយ

ទាំងពន្ធគយ និងអាករនានានៅពេលនាំចូល ចំពោះទំនិញនាំចូល។ ទោះបីជាសេដ្ឋកិច្ចកម្ពុជាទទួលរងនូវផលប៉ះទង្គិចពីវិបត្តិកូវីដ-១៩ និងវិបត្តិសម្ពាធអតិផរណាដែលបង្កឡើងដោយសង្គ្រាមនៅអ៊ុយក្រែន អត្រាអាករលើតម្លៃបន្ថែម មិនមានការកែសម្រួលនោះទេ ខណៈដែលបណ្តាប្រទេសក្នុងតំបន់ ដូចជា ប្រទេសថៃ និងវៀតណាម បានកាត់បន្ថយនូវអត្រាអាករតម្លៃបន្ថែម ដើម្បីសម្រួលបន្ទុកប្រជាពលរដ្ឋ និងជំរុញសកម្មភាពសេដ្ឋកិច្ច លើកលែងតែប្រទេសសិង្ហបុរី ដែលបានដំឡើងអត្រាពន្ធលើទំនិញ និងសេវា ពី ៧%ទៅ ៨% ក្នុងឆ្នាំ ២០២៣ និង ៩% ក្នុងឆ្នាំ២០២៤ និងប្រទេសឥណ្ឌូនេស៊ី ដែលបានដំឡើងអត្រាពន្ធ ពី ១០% ទៅ ១១% នៅដើមឆ្នាំ២០២២ និងគ្រោងនឹងដំឡើងទៅ ១២% នៅដើមឆ្នាំ២០២៥។ យ៉ាងណាមិញ កម្ពុជាបានអនុវត្តការលើកលែងអាករលើការផ្គត់ផ្គង់សេវា និងទំនិញមួយចំនួនក្នុងវិស័យសំខាន់មួយចំនួនដូចជា សេវាអប់រំ សេវាសុខាភិបាល ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទឹកស្អាត សេវាប្រមូលសំរាម និងកាកសំណល់រឹង និងរាវ សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ សេវាធានារ៉ាប់រង សេវាប្រៃសណីយ៍សាធារណៈ សេវាដឹកជញ្ជូនរបស់រដ្ឋ ។ល។ ទន្ទឹមនេះ ដើម្បីសម្រាលបន្ទុកជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ខណៈដែលថ្លៃទំនិញជាទូទៅ ជាពិសេសចំពោះម្ហូបអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋមានការឡើងថ្លៃ នាពេលកន្លងមករាជរដ្ឋាភិបាល បានដាក់អាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋលើមុខទំនិញដែលជាអាហារមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាល ក៏បានអនុវត្តអាករលើតម្លៃបន្ថែមតាមអត្រាសូន្យលើការផ្គត់ផ្គង់វត្ថុធាតុដើមផលិតផលកម្មដែលផលិតក្នុងស្រុក ដើម្បីលើកកម្ពស់ផលិតកម្មក្នុងស្រុក។

ស្របគ្នានេះ ការអនុវត្តអាករលើតម្លៃបន្ថែមនៅកម្ពុជា នៅតែមានបញ្ហាប្រឈមមួយចំនួន ដែលទាមទារឱ្យមានការពិនិត្យឡើងវិញ រួមមាន៖ ១)-ការបង្វិលសងអាករលើតម្លៃបន្ថែម មិនទាន់បានឆ្លើយតបតាមការស្នើសុំ និងមានភាពយឺតយ៉ាវ បើទោះបីជារយៈពេលនៃការបង្វិលសងត្រូវបានកាត់បន្ថយ ដែលការណ៍នេះ ផ្តល់ផលប៉ះពាល់ដល់រំហូរសាច់ប្រាក់ និងស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសស្នើសុំបង្វិលសង ២)-ការអនុវត្តអាករលើតម្លៃបន្ថែមលើការផ្គង់ផ្គង់ទំនិញ និងសេវាលើថ្នាលឌីជីថលមិនទាន់បានពេញលេញ និង ៣)-កង្វះយន្តការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ និងអនុវត្តអាករលើតម្លៃបន្ថែមតាមអត្រាសូន្យ។

**ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- ពិនិត្យលទ្ធភាពក្នុងការកែសម្រួលការអនុវត្តអត្រាសូន្យសម្រាប់ការទិញនូវវត្ថុធាតុដើម ដែលផលិតក្នុងស្រុក ដើម្បីសម្រួលបន្ទុករដ្ឋបាលក្នុងការបង្វិលសងអាករលើតម្លៃបន្ថែមទៅកាន់សហគ្រាសផ្គត់ផ្គង់ក្នុងស្រុក តាមរយៈការបង្កើនប្រសិទ្ធភាពនៃយន្តការបង្វិលសងអាករលើតម្លៃបន្ថែម ។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- សិក្សា និងរៀបចំយន្តការដែលកំណត់ជាកាតព្វកិច្ច ចំពោះការប្រមូលអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញ និងសេវាលើថ្នាលឌីជីថល ដោយអ្នកផ្គត់ផ្គង់និវាសនជន និងអ្នកផ្គត់ផ្គង់អនិវាសនជន ដោយធានាភាពមិនត្រួតគ្នានៃការប្រមូលពន្ធ និង

- ពិនិត្យឡើងវិញនូវការលើកលែងអាករលើតម្លៃបន្ថែម ក្នុងវិស័យម្ហូបអាហារមួយចំនួន។

### ៥.៥. ពន្ធពាក់ព័ន្ធនឹងអចលនទ្រព្យ

ការអនុវត្តពន្ធពាក់ព័ន្ធនឹងអចលនទ្រព្យ (រួមមាន ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យ) មានគោលបំណងធានានូវសមធម៌ ប្រមូលចំណូលសម្រាប់អភិវឌ្ឍមូលដ្ឋាននៅថ្នាក់ក្រោមជាតិ បង្ការសកម្មភាពបរិកប្បកម្មអចលនទ្រព្យ និងបង្កើនប្រសិទ្ធភាពលើការប្រើប្រាស់អចលនទ្រព្យដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ ក្នុងនោះ វិសាលភាពនៃការអនុវត្តពន្ធពាក់ព័ន្ធនឹងអចលនទ្រព្យ គ្របដណ្តប់លើពន្ធចំនួនបីប្រភេទគឺ៖ ១)-ពន្ធលើអចលនទ្រព្យ ត្រូវបានអនុវត្តលើអចលនទ្រព្យ ដែលស្ថិតនៅក្នុងរាជធានី និងទីក្រុងនានាតាមបណ្តាខេត្ត ដែលមានតម្លៃលើសពី ១០០ លានរៀល ក្នុងអត្រា ០,១% ដោយមូលដ្ឋានគិតពន្ធត្រូវបានកំណត់យក ៨០% នៃតម្លៃដីធ្លី និងអាគារដែលកំណត់ដោយ គណៈកម្មាធិការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ ២)-ពន្ធលើដីធ្លីមិនបានប្រើប្រាស់មានអត្រា ២% ដែលត្រូវអនុវត្តលើដីមានសំណង់ ឬគ្មានសំណង់ដែលស្ថិតនៅក្រៅទីតាំងភូមិសាស្ត្រដែលជាកម្មវត្ថុនៃពន្ធលើអចលនទ្រព្យ និងត្រូវអនុញ្ញាតឱ្យកាត់ចេញពីមូលដ្ឋានគិតពន្ធចំនួន៥ ហិកតា សម្រាប់ដីមួយកន្លែង និង ៣)-ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យមានអត្រា ៤% ដែលអនុវត្តលើការផ្ទេរកម្មសិទ្ធិ និងការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន ដែលមូលដ្ឋានគិតពន្ធជាតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ និងការដាក់ភាគហ៊ុន ឬជាតម្លៃកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្នុងទិដ្ឋភាពចំណូល ចំណូលពីពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ចូលរួមចំណែកប្រមាណ ៤,៣% នៃចំណូលពន្ធសរុប ដែលភាគច្រើននៃចំណូលនេះប្រមាណ ៨២% បានមកពីពន្ធប្រថាប់ត្រា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យសំណង់ និងអចលនទ្រព្យ កំពុងជួបបញ្ហាប្រឈមមួយចំនួន ដែលរងឥទ្ធិពលពីស្លាកស្នាម (Scarring effects) វិបត្តិកូវីដ-១៩ និងការអូសបន្លាយនៃសង្គ្រាមនៅអ៊ុយក្រែន ដូចជា ការបន្តរឹងស្ងួតនៃលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ ការផ្គត់ផ្គង់សំណង់ និងអចលនទ្រព្យលើសតម្រូវការជាក់ស្តែង ភាពមានកម្រិតនៃការគ្រប់គ្រង និងការអនុវត្តច្បាប់បទប្បញ្ញត្តិនានា កង្វះការប្រមូលផ្តុំ និងការចែករំលែកទិន្នន័យអចលនទ្រព្យរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ការណ៍នេះ បានជំរុញឱ្យការប្រមូលចំណូលពន្ធសរុបទាំងបីខាងលើមានកំណើនអវិជ្ជមានប្រមាណ -៩,៦% ដោយធ្លាក់ចុះពី ១ ០៧៨ ប៊ីលានរៀលក្នុងឆ្នាំ២០១៩ មកត្រឹម ៩៧៤ ប៊ីលានរៀលក្នុងឆ្នាំ ២០២២។ ទោះជាយ៉ាងនេះក្តី ការអនុវត្តពន្ធពាក់ព័ន្ធនឹងអចលនទ្រព្យ ជាពិសេសពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅមានបញ្ហាប្រឈមមួយចំនួន ដែលបានបន្សល់ទុកតាំងពីមុនការធ្លាក់ចុះនៃវិស័យនេះ និងតម្រូវឱ្យមានដំណោះស្រាយជាក់លាក់ មានដូចជា៖ ១)-ការអនុវត្តពន្ធលើអចលនទ្រព្យនៅមិនទាន់គ្របដណ្តប់គ្រប់ទីប្រជុំជនដែលមានសក្តានុពល ២)-ចំណូលពីពន្ធលើអចលនទ្រព្យនៅមានកម្រិតទាប ដែលទាមទារឱ្យមានការពិនិត្យឡើងវិញលើអត្រាពន្ធ ៣)-កង្វះមូលដ្ឋានទិន្នន័យប្រមូលផ្តុំដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ៤)-បញ្ហាអនុលោមភាពនៃការបង់ពន្ធដីធ្លីមិនបានប្រើប្រាស់ និង ៥)-កង្វះយន្តការទទួលមតិយោបល់ពីអ្នកជាប់ពន្ធ និងសាធារណជន។

**ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- សិក្សា និងពិនិត្យលទ្ធភាពក្នុងការរៀបចំប្រព័ន្ធទិន្នន័យប្រមូលផ្ដុំ ដែលអាចធ្វើសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងអចលនទ្រព្យផ្សេងទៀតសម្រាប់ការអនុវត្តពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬកាន់កាប់អចលនទ្រព្យ និង
- រៀបចំយន្តការទទួលមតិយោបល់ពីអ្នកជាប់ពន្ធ និងសាធារណជនពាក់ព័ន្ធនឹងការអនុវត្តពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធប្រថាប់ត្រា ដើម្បីធានាឱ្យបាននូវការអនុវត្តប្រកបដោយសុក្រឹតភាព សមធម៌ និងយុត្តិធម៌។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- ពិនិត្យលទ្ធភាពក្នុងការពង្រីកវិសាលភាពនៃការប្រមូលពន្ធលើអចលនទ្រព្យ នៅតាមទីប្រជុំជននៃខេត្តដែលមានសក្ដានុពល និង
- បន្តធ្វើបច្ចុប្បន្នភាពថ្លៃអចលនទ្រព្យសម្រាប់ជាមូលដ្ឋានគិតពន្ធប្រថាប់ត្រារៀងរាល់ ៥ ឆ្នាំម្ដង។

### ៥.៦. ការគ្រប់គ្រងចំណាយសារពើពន្ធ

រាជរដ្ឋាភិបាលបានផ្តល់សម្បទានពន្ធឱ្យវិនិយោគិន និងសហគ្រាសគាំទ្រក្នុងវិស័យអាទិភាពផ្សេងៗ តាមរយៈការលើកលែងទឹកប្រាក់ពន្ធ-អាករ និងការអនុគ្រោះអត្រាពន្ធ-អាករ ដើម្បីចាប់យកនូវកាលានុវត្តភាពថ្មីៗសម្រាប់ជំរុញសម្ពុះឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ ឱ្យរីកលូតលាស់នៅកម្ពុជាបានកាន់តែច្រើន សំដៅលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ និងជំរុញសកម្មភាពវិនិយោគក្នុងស្រុក។ ការណ៍នេះបានចូលរួមចំណែកយ៉ាងសំខាន់ដល់កិច្ចអភិវឌ្ឍសង្គមជាតិប្រកបដោយចីរភាព ព្រមទាំងផ្សារភ្ជាប់ជាមួយនឹងចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ពោលគឺការធ្វើពិពិធកម្មនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកខ្លាំងទៅលើវិស័យកសិកម្ម មកជាសេដ្ឋកិច្ចដែលពឹងផ្អែកកាន់តែខ្លាំងលើវិស័យឧស្សាហកម្ម។ បច្ចុប្បន្ន គោលការណ៍លើកទឹកចិត្តពន្ធ-អាករនានារបស់រាជរដ្ឋាភិបាលរួមមាន៖ ១)-ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ២)-គោលការណ៍លើកទឹកចិត្តពន្ធ-អាករលើការនាំចូលសម្រាប់ឧស្សាហកម្មផ្ដុំ និងដំឡើងយានយន្តថ្មីក្នុងស្រុក តាមរយៈលិខិតលេខ ៣៤៦ សជណ.ហជ និងលិខិតលេខ ១៩០៦ សជណ.ហជ (ត្រូវបានបញ្ចូលទៅក្នុងមាត្រា ១៧ នៃអនុក្រឹត្យលេខ ១៣៩ ស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា) ៣)-ការចាត់ទុកអាករជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញមួយចំនួនដូចជា ការនាំចូលនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មសម្រាប់បម្រើខ្សែច្រវាក់ផលិតកម្មរបស់គម្រោងវិនិយោគ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ព្រមទាំងការនាំចូល និងផ្គត់ផ្គង់ទំនិញមួយចំនួន ដូចជា ជីគ្រប់ប្រភេទ ពូជដំណាំគ្រប់ប្រភេទ បសុឱសថ គ្រឿងយន្ត និងឧបករណ៍កសិកម្មគ្រប់ប្រភេទ ជាដើម និង ៤)-គោលការណ៍លើកទឹកចិត្តផ្សេងទៀត។

យ៉ាងណាមិញ ការដាក់ឱ្យអនុវត្តវិធានការលើកទឹកចិត្តពន្ធ-អាករ ព្រមទាំងការពង្រីកវិសាលភាពនៃការលើកលែង ឬ ការបន្ធូរបន្ថយការបង់ប្រាក់ពន្ធ បានបង្កឱ្យទំហំចំណាយសារពើពន្ធបានកើនឡើងខ្លាំងជាបន្តបន្ទាប់ ស្របពេលដែលការប្រមូលចំណូលចរន្តមាននិន្នាការថមថយ។ ការណ៍នេះបានជំរុញឱ្យមានការយក

ចិត្តទុកដាក់ខ្ពស់ លើការរៀបចំក្របខ័ណ្ឌគោលនយោបាយរួមមួយស្តីពីការគ្រប់គ្រងចំណាយសារពើពន្ធ និងការរៀបចំប្រព័ន្ធគ្រប់គ្រងចំណាយសារពើពន្ធ ដែលនឹងផ្តោតសំខាន់លើការពិនិត្យលើលទ្ធភាព និងការកែសម្រួល ឡើងវិញនូវគោលការណ៍លើកទឹកចិត្តពាក់ព័ន្ធ ព្រមទាំងដាក់ចេញនូវវិធានការមុតស្រួច ដែលមានវិសាលភាពគ្របដណ្តប់លើគ្រប់ទិដ្ឋភាព ទាំងទិដ្ឋភាពហិរញ្ញវត្ថុសាធារណៈ និងកម្មវិបាកនានាមកលើសង្គម-សេដ្ឋកិច្ច តាមរយៈការកំណត់លក្ខណៈវិនិច្ឆ័យ និងនិយមន័យចំណាយសារពើពន្ធ ការកត់ត្រា ផ្ទៀងផ្ទាត់ និងគ្រប់គ្រងទិន្នន័យ ការលើកកម្ពស់គុណភាពនិងជំរុញយន្តការចែករំលែកទិន្នន័យ ការអភិវឌ្ឍសមត្ថភាពក្នុងការវិភាគចំណាយសារពើពន្ធ និងធ្វើការវាយតម្លៃឡើងវិញនូវចំណូលដែលបានបាត់បង់ និងការរៀបចំនូវយន្តការតម្រង់ទិស និងកែលម្អការគ្រប់គ្រងចំណាយសារពើពន្ធ ជាដើម ដើម្បីធានានូវចីរភាពនៃចំណូលសារពើពន្ធក្នុងរយៈពេលមធ្យម និងវែង ព្រមទាំងពង្រឹងការគ្រប់គ្រងប្រព័ន្ធពន្ធ (Tax System) នៅកម្ពុជាប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- រៀបចំយន្តការគ្រប់គ្រង និងចែករំលែកទិន្នន័យចំណាយសារពើពន្ធរួមមួយ សម្រាប់ជាមូលដ្ឋានក្នុងការវិភាគចំណាយសារពើពន្ធ
- សិក្សា និងវិភាគចំណាយសារពើពន្ធ ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្តរបបលើកទឹកចិត្តពន្ធ និង
- ធ្វើការវាយតម្លៃប្រសិទ្ធភាព និងគុណប្រយោជន៍ លើគោលការណ៍លើកទឹកចិត្តដល់ឧស្សាហកម្មផ្គុំ និងដំឡើងយានយន្ត ដើម្បីរៀបចំយុទ្ធសាស្ត្រជំរុញការវិនិយោគ ក្នុងវិស័យផ្គុំ និងដំឡើងយានយន្ត និងឧស្សាហកម្មគាំទ្រ។

***វិធានការការរយៈពេលមធ្យម ២០២៦-២០២៨៖***

- ធ្វើការវាយតម្លៃប្រសិទ្ធភាព និងគុណប្រយោជន៍ លើការអនុវត្តរបបលើកទឹកចិត្តពន្ធនៅក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងការលើកទឹកចិត្តពន្ធផ្សេងៗតាមការចាំបាច់ ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តរបបលើកទឹកចិត្តពន្ធ
- ធ្វើការវាយតម្លៃប្រសិទ្ធភាព និងគុណប្រយោជន៍ លើការលើកលែងអាករលើតម្លៃបន្ថែម និងការដាក់អាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ដោយថ្លឹងថ្លែងរវាងប្រសិទ្ធភាពសេដ្ឋកិច្ច ចំណូល និងសមធម៌នៃការបង់ពន្ធ និង
- សិក្សាលទ្ធភាពក្នុងការផ្លាស់ប្តូរ ពីការផ្តល់ការលើកទឹកចិត្តលើប្រាក់ចំណូល (Profit-based incentives) ទៅជាការលើកទឹកចិត្តលើការចំណាយ (Cost-based incentives) ក្នុងការទាក់ទាញវិនិយោគ និងធានាប្រសិទ្ធភាពនៃរបបលើកទឹកចិត្តពន្ធ។

### ៥.៧. ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម

សហគ្រាសធុនតូច និងមធ្យម នៅតែជាកម្លាំងចលករដ៏ខ្លាំងមួយក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា និងបង្កើតការងារសម្រាប់ប្រជាជន សម្រាប់រយៈពេលមធ្យមខាងមុខ។ កន្លងមកនេះ រាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយជាកញ្ចប់ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍសហគ្រាសធុនតូច និង

មធ្យម ពង្រឹងភាពប្រកួតប្រជែង និងបង្កើនសមត្ថភាពផលិតកម្ម លើវិស័យអាទិភាពចំនួន ៦ សម្រាប់ការលើកទឹកចិត្តផ្នែកពន្ធដារ និង ៨ សម្រាប់ការលើកទឹកចិត្តផ្នែកគយ ដែលរួមមាន៖ ការលើកទឹកចិត្តផ្នែកពន្ធដារ (ការលើកលែងពន្ធលើប្រាក់ចំណូលចំនួន ៣ ឆ្នាំ ឬ ៥ ឆ្នាំ ការលើកលែងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមាក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល និងការលើកទឹកចិត្តចំណាយដែលអាចកាត់កង) ការលើកទឹកចិត្តផ្នែកគយ (លើកលែងពន្ធគយលើសម្ភារបរិក្ខារផលិតកម្ម/ដំឡើងនិងប្រើប្រាស់ និង/ឬសម្ភារសាងសង់ និង/ឬធាតុចូលផលិតកម្ម) និងការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ ដើម្បីលើកទឹកចិត្តដល់វិស័យកសិកម្ម សហគ្រាសធុនតូច និងមធ្យម និងការថែរក្សាបរិស្ថាន។ បន្ថែមលើនេះ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ បានចង្អុលបង្ហាញឱ្យមានការគិតគូរលើការលើកស្ទួយសហគ្រាសធុនមីក្រូ ដែលជាកម្មវត្ថុក្នុងការធ្វើបច្ចុប្បន្នភាពនៃគោលនយោបាយលើកទឹកចិត្តពន្ធជាកញ្ចប់។

ទោះបីជាមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីគោលនយោបាយជាកញ្ចប់នេះក៏ដោយ ក៏ការស្នើសុំ និងការអនុម័តលើការលើកទឹកចិត្តផ្នែកពន្ធដារ និងគយ សម្រាប់សហគ្រាសធុនតូច និងមធ្យមនៅមានកម្រិតទាបនៅឡើយ ដោយសារបញ្ហាប្រឈមមួយចំនួនដូចជា៖ សហគ្រាសធុនតូច និងមធ្យមមួយចំនួនពុំទាន់បានចុះបញ្ជី ភាពមិនទាន់គ្រប់ជ្រុងជ្រោយនៃការកំណត់និយមន័យ និងវិស័យអាទិភាព រយៈពេលខ្លីនៃការលើកទឹកចិត្តផ្នែកពន្ធដារ ភាពមានកម្រិតនៃការកាន់បញ្ជីគណនេយ្យរបស់សហគ្រាស អសង្គតិភាពនៃការបកស្រាយលើធាតុចូលផលិតកម្មដែលត្រូវលើកទឹកចិត្ត សហគ្រាសធុនតូច និងមធ្យមភាគច្រើនជាសហគ្រាសបម្រើតម្រូវការក្នុងស្រុក ដែលមិនទទួលបានការលើកទឹកចិត្តលើធាតុចូលផលិតកម្ម ភាគច្រើននៃធាតុចូលផលិតកម្ម និងសម្ភារបរិក្ខារផលិតកម្មក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម មានអត្រាពន្ធគយទាបរួចហើយ ដែលធ្វើឱ្យសហគ្រាសធុនតូច និងមធ្យមមិនសូវមានការចាប់អារម្មណ៍ក្នុងការស្នើសុំការលើកទឹកចិត្តបន្ថែម និងភាពមានកម្រិតរបស់សហគ្រាសធុនតូច និងមធ្យមក្នុងការស្វែងយល់អំពីនីតិវិធីនៃការស្នើសុំការលើកទឹកចិត្ត ជាដើម។

**ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- ពិនិត្យ និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តអនុក្រឹត្យលេខ ៥០, ៥១, និង ១២៤ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ និងផ្នែកគយសម្រាប់សហគ្រាសធុនតូច និងមធ្យម និងកែសម្រួលការអនុវត្តយន្តការលើកទឹកចិត្តពន្ធ សម្រាប់ការលើកកម្ពស់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ដើម្បីបំពេញតម្រូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យស្របតាមគោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងករណីចាំបាច់
- សិក្សា និងកំណត់ឡើងវិញនូវនិយមន័យ និងវិស័យអាទិភាពនៃសហគ្រាសធុនតូច និងមធ្យមឱ្យស្របទៅតាមឧត្តមានុវត្តន៍អន្តរជាតិ និង
- ផ្សព្វផ្សាយ និងជំរុញការផ្តល់ការលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម ដើម្បីលើកកម្ពស់ផលិតកម្មក្នុងស្រុក និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- បន្តផ្សព្វផ្សាយ និងជំរុញការផ្ដល់ការលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម ដើម្បីលើកកម្ពស់ផលិតកម្មក្នុងស្រុក និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

### ៥.៨. ពន្ធក្នុងវិស័យល្បែងពាណិជ្ជកម្ម

ពន្ធ-អាករនៅក្នុងវិស័យល្បែងពាណិជ្ជកម្ម ត្រូវបានអនុវត្តតាមប្រកាសលេខ ១០៨០ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីវិធាន និងនីតិវិធីសម្រាប់អនុវត្តកាតព្វកិច្ចសារពើពន្ធចំពោះសហគ្រាសប្រកបអាជីវកម្មល្បែងពាណិជ្ជកម្ម ដោយបានកំណត់រាល់កាតព្វកិច្ចពន្ធលើគ្រប់សកម្មភាពទាំងឡាយក្នុងវិស័យល្បែងពាណិជ្ជកម្ម។ ក្នុងការអនុវត្តពន្ធលើប្រាក់ចំណូល ផលរបរនៃពន្ធលើប្រាក់ចំណូល គឺជាចំណូលសរុបពីល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ (ចំណូលសរុបពីការចាក់ភ្នាល់ដុលដែលបានទទួល ឬត្រូវទទួលពីសកម្មភាពល្បែងពាណិជ្ជកម្មនីមួយៗ ដកចេញនូវប្រាក់ឈ្នះទាំងឡាយណាដែលបានទូទាត់ដល់ភ្ញៀវល្បែង) និងចំណូលផ្សេងៗទៀតក្រៅពីចំណូលសរុបពីល្បែងពាណិជ្ជកម្ម លើកលែងតែអាករលើតម្លៃបន្ថែម។ យ៉ាងណាមិញ ការអនុវត្តពន្ធលើប្រាក់ចំណូលនៅក្នុងវិស័យនេះ នៅមានបញ្ហាប្រឈមមួយចំនួន ១)- ការបែងចែករវាងប្រាក់ចំណូលពីសកម្មភាពល្បែងពាណិជ្ជកម្ម និងសកម្មភាពមិនមែនល្បែងពាណិជ្ជកម្មដទៃទៀតដែលជ្រកក្រោមអាជីវកម្មល្បែងពាណិជ្ជកម្ម នៅមិនទាន់មានភាពច្បាស់លាស់ (Complexities in distinguishing between gambling and non-gambling income for tax purposes) ២)- ការរាយការណ៍មិនគ្រប់ជ្រុងជ្រោយនៃប្រាក់ចំណូលមិនមែនល្បែងពាណិជ្ជកម្ម (Under reporting of non-gambling revenues) ដែលជាសកម្មភាពអាជីវកម្មមិនមែនល្បែងពាណិជ្ជកម្មតូចៗជាច្រើនទៀត ដែលបាននិងកំពុងមានដំណើរការជ្រកក្រោមអាជីវកម្មល្បែងពាណិជ្ជកម្ម។

**ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥***

- ពង្រឹងយន្តការអនុវត្តពន្ធលើប្រាក់ចំណូល និងពន្ធ-អាករផ្សេងទៀត លើអាជីវកម្មល្បែងពាណិជ្ជកម្ម ទាំងសកម្មភាពល្បែងពាណិជ្ជកម្ម និងសកម្មភាពដទៃទៀតដែលជ្រកក្រោមអាជីវកម្មល្បែងពាណិជ្ជ-កម្ម។

### ៥.៩. ពន្ធលើសេវាកម្មឌីជីថល

ជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យាក្នុងតំបន់ និងសកលលោក សេដ្ឋកិច្ចឌីជីថលកម្ពុជា បាន និងកំពុងតែមានសម្ទុះ និងរីកចម្រើនកាន់តែខ្លាំងឡើង ព្រមទាំងបានបង្កើតជាសកម្មភាពធុរកិច្ចថ្មីៗជាច្រើនតាមប្រព័ន្ធអេឡិចត្រូនិក។ តាមការប៉ាន់ស្មានរបស់ក្រសួងពាណិជ្ជកម្ម តម្លៃទីផ្សារនៃពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកដែលរួមបញ្ចូលទាំងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងស្រុក និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងដែន (Cross-border e-commerce) មានទំហំ ១,២៨ ប៊ីលានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៣ ១,៥០ ប៊ីលានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៤ និង ១,៧៨ ប៊ីលានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៥។ ការណ៍នេះ ទាមទារឱ្យមានការគិតគូរលើការអនុវត្តពន្ធលើសេវាកម្មឌីជីថលដែលជាពន្ធលើប្រាក់ចំណូលសរុប

ដែលទទួលបានពីសេវាកម្មឌីជីថលផ្សេងៗ មានជាអាទិ៍ ការផ្សព្វផ្សាយពាណិជ្ជកម្មឌីជីថល ការផ្តល់សេវាអន្តរការីឌីជីថល ដូចជាប្រតិបត្តិការទីផ្សារអនឡាញ និងការលក់ទិន្នន័យដែលប្រមូលពីអ្នកប្រើប្រាស់[4]។ ការអនុវត្តពន្ធលើសេវាកម្មឌីជីថល ត្រូវបានគិតគូរជាពិសេសលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងដែន ដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅកម្ពុជា និងផ្គត់ផ្គង់ពីក្រៅព្រះរាជាណាចក្រកម្ពុជាដល់និវាសនជនជា សហគ្រាសក្នុងរបបស្វ័យប្រកាស ឬ/និងរូបវន្តបុគ្គលនៅកម្ពុជា សំដៅពង្រីកមូលដ្ឋានគិតពន្ធ ដែលនឹងប្រមូលចំណូលពន្ធបន្ថែមលើផលចំណេញរបស់ក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ និងសេវាកម្មឌីជីថលពីបរទេស ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។

**ក្នុងន័យនេះ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការ ដូចខាងក្រោម៖**

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- សិក្សាសមិទ្ធិលទ្ធភាពក្នុងការអនុវត្តពន្ធសេវាកម្មឌីជីថល ការកំណត់អត្រាពន្ធ ការវិភាគចំណេញខាត (Costs and Benefits) និងនីតិវិធីរដ្ឋបាលនៃការអនុវត្តពន្ធនេះ។

## ៥.១០. ពន្ធលើការបំភាយកាបូន

ការបំភាយឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាសជាកត្តាចម្បងនៃការប្រែប្រួលអាកាសធាតុ ដែលបង្កបញ្ហាដល់សុខភាពសាធារណៈ ធ្វើឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងប៉ះពាល់ដល់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។ កាបូនជាប្រភេទឧស្ម័នផ្ទះកញ្ចក់ចម្បង ដែលកើតចេញពីសកម្មភាពរបស់មនុស្ស។ ជាឧត្តមានុវត្តន៍ ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ជាពិសេសការបំភាយឧស្ម័នកាបូន មានយន្តការមួយចំនួន ដែលត្រូវបាននិងកំពុងអនុវត្តនៅលើសកលលោក ដូចជា ការកំណត់ពន្ធលើការបំភាយកាបូន (Carbon tax) ការជួញដូរការបំភាយកាបូន ការដាក់ពន្ធលើប្រេងឥន្ធនៈ ការប្រើប្រាស់ឥណទានកាបូន និងការលុបបំបាត់ការឧបត្ថម្ភធនលើឥន្ធនៈហ្វូស៊ីល។ល។ ការកំណត់ពន្ធលើការបំភាយកាបូន ជានិន្នាការសកលដែលប្រទេសនានាបាន និងកំពុងអនុវត្ត ក្នុងគោលដៅកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ តាមរយៈយន្តការហិរញ្ញវត្ថុ។ នាពេលបច្ចុប្បន្ន នៅទូទាំងពិភពលោកមានប្រទេសប្រហែល ២៧ កំពុងអនុវត្តការយកពន្ធលើការបំភាយកាបូន ហើយមានប្រទេសជាច្រើនទៀតគ្រោងនឹងអនុវត្តនាពេលអនាគត។

ការកំណត់ពន្ធលើការបំភាយកាបូន មិនត្រឹមតែចូលរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ក៏បានបង្កើនចំណូលរដ្ឋផងដែរ។ ជាទូទៅ ពន្ធលើការបំភាយកាបូន ត្រូវបានអនុវត្តផ្ទាល់ទៅលើកម្រិតនៃការបំភាយកាបូនទៅតាមសកម្មភាព ឬវិស័យនានាដែលរួមចំណែកក្នុងការបំភាយឧស្ម័នផ្ទះកញ្ចក់។ ការកំណត់អត្រាពន្ធលើការបំភាយកាបូនមានកម្រិតខុសៗគ្នាទៅតាមប្រទេសនីមួយៗ។ ជាក់ស្តែងក្នុងចំណោមប្រទេសដែលកំពុងអនុវត្តពន្ធនេះក្នុងឆ្នាំ ២០២៣ ប្រទេសអ៊ុយរ៉ូហ្គាយមានអត្រាពន្ធខ្ពស់ជាងគេ ហូតដល់ ១៥៦ ដុល្លារអាម៉េរិក/t$CO_2$e ខណៈដែលប្រទេសប៉ូឡូញមានអត្រាទាបជាងគេគឺតិចជាង ១ ដុល្លារអាម៉េរិក/t$CO_2$e។

[4] គេហទំព័រ Bloomberg Tax ស្តីពី ការយល់ដឹងសង្ខេបអំពីពន្ធលើសេវាកម្មឌីជីថល -OECD, ២០២៣

ជាទិសដៅយុទ្ធសាស្ត្រ រាជរដ្ឋាភិបាលនឹងបន្សីប្រភេទពន្ធនេះ ទៅក្នុងគោលនយោបាយសារពើពន្ធជារួម។ ដោយសារពន្ធលើការបំភាយកាបូនគឺជាគំនិតផ្តួចផ្តើមថ្មីមួយសម្រាប់កម្ពុជា ក្នុងការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដែលត្រូវមានការគិតគូរដោយប្រុងប្រយ័ត្ន និងត្រូវធ្វើការសិក្សាបន្ថែមទៀត ដើម្បីកំណត់វិធីសាស្ត្រ និង ក្របខ័ណ្ឌពេលសមស្របសម្រាប់ការអនុវត្ត។

**ក្នុងន័យនេះ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការ ដូចខាងក្រោម៖**

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- សិក្សាសមិទ្ធិលទ្ធភាពក្នុងការអនុវត្តពន្ធលើការបំភាយកាបូន ដើម្បីវាយតម្លៃភាពរួចរាល់ (Readiness Assessment) នៃការអនុវត្តពន្ធលើការបំភាយកាបូន ដែលរួមមាន ការវិភាគបន្ទុកពន្ធ ការវិភាគមូលដ្ឋានគិតពន្ធ និងអត្រាពន្ធ ក្របខ័ណ្ឌពេលដែលត្រូវអនុវត្ត ព្រមទាំងសមត្ថភាពស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលសារពើពន្ធ។

## ជំពូកទី៦
## ការពង្រឹងរដ្ឋបាល និងគោលនយោបាយចំណូលមិនមែនសារពើពន្ធ

ចំណូលមិនមែនសារពើពន្ធ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រីកលម្ហចំណូលថវិកាជាតិ និងឆ្លើយតបតម្រូវការអភិវឌ្ឍរបស់ជាតិ។ បណ្តាប្រទេសជាច្រើននៅអាស៊ីប៉ាស៊ីហ្វិក បាននិងកំពុងពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ទៅតាមសក្តានុពលចំណូលរបស់ប្រទេសនីមួយៗ។ កន្លងមក រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់លើការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តយុទ្ធសាស្ត្រកៀរចំណូលទាំងពីរដំណាក់កាល។ សមិទ្ធផលធំៗដែលសម្រេចបានក្នុងការពង្រឹងការគ្រប់គ្រង គឺការដាក់ចេញនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាជាបន្តបន្ទាប់ រួមមានការរៀបចំនិងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាដែលសម្រួលដល់ការគ្រប់គ្រងនិងការបង់ចំណូល ព្រមទាំងការរៀបចំផែនការគោលបម្រើចក្ខុវិស័យរយៈពេលវែង សម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាសម្រាប់ការកែទម្រង់ការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ។

ទោះជាយ៉ាងនេះក្តី លទ្ធផលនៃការអនុវត្តវិធានការដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រកៀរគរចំណូលកន្លងមក នៅមានលទ្ធភាពបង្កើនថែមទៀត ដោយចំណូលមិនមែនសារពើពន្ធដែលប្រមូលបាន នៅមានទំហំតូច ប្រែប្រួលខ្លាំងពិបាកប៉ាន់ប្រមាណ និងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិនៃជំងឺកូវីដ-១៩។ ជាក់ស្តែង ចំណូលមិនមែនសារពើពន្ធ មានទំហំប្រមាណ ២,៤% នៃ ផ.ស.ស (ឆ្នាំគោល ២០១៤) នៅឆ្នាំ ២០១៩ ប៉ុន្តែ ចំណូលនេះបានធ្លាក់ចុះនៅអំឡុងឆ្នាំ ២០២០ និងឆ្នាំ ២០២១។ នៅឆ្នាំ២០២៣ ចំណូលមិនមែនសារពើពន្ធមានទំហំត្រឹមប្រមាណ ១,៥% នៃ ផ.ស.ស ប៉ុណ្ណោះ។

ការពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅមានបញ្ហាប្រឈមច្រើន ដែលទាមទារនូវការចាត់វិធានការដោះស្រាយដោយឡែកទៅតាមគោលដៅនីមួយៗ និងដោះស្រាយជាប្រព័ន្ធលើផ្នែកគតិយុត្ត ធនធានមនុស្សនិងសមត្ថភាពស្ថាប័ន និងទំនើបកម្ម។ ផ្អែកលើការអនុវត្ត

កន្លងមក បញ្ហាប្រឈមធំៗដែលបានជួបប្រទះមានដូចជា ១)-ការប្តេជ្ញាចិត្ត និងភាពម៉ឺងម៉ាត់ក្នុងកិច្ចសហការប្រទាក់ក្រឡាវាងអន្តរក្រសួង នៅមានកម្រិត ២)-កង្វះប្រព័ន្ធដែលមានប្រសិទ្ធភាព សម្រាប់តាមដាន ពិនិត្យវឌ្ឍនភាព និងវាយតម្លៃការអនុវត្ត ៣)-យន្តការទំនាក់ទំនងមិនទាន់ច្បាស់លាស់ ព្រមទាំងសមត្ថភាពនិងការទទួលខុសត្រូវ នៅមានកម្រិត ៤)-ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅមិនទាន់បានកែលម្អគ្រប់គ្រាន់ ទន្ទឹមនឹងការអនុវត្តនៅខ្វះចន្លោះ និង ៥)-ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រង នៅមានកម្រិត ដោយត្រូវធ្វើទំនើបកម្មបន្ថែម និងពង្រីកវិសាលភាពទាំងការប្រើប្រាស់និងការកសាងប្រព័ន្ធ។

ជំហានបន្ទាប់ សម្រាប់យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា រាជរដ្ឋាភិបាល នឹងបន្តពង្រឹងរដ្ឋបាល និងគោលនយោបាយចំណូលមិនមែនសារពើពន្ធ ដោយផ្តោតលើការបន្តអនុវត្តវិធានការចាំបាច់នានាដែលនៅសេសសល់ពីយុទ្ធសាស្ត្រមុន ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងជំរុញដោះស្រាយបញ្ហាប្រឈមនានាខាងលើ។ ទន្ទឹមនេះ **យុទ្ធសាស្ត្រកៀរគរចំណូលនៃរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ត្រូវបានរៀបចំដោយជំរុញការអនុវត្តវិធានការគន្លឹះ ដែលមានក្នុងផែនការគោលពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ជាពិសេសការពង្រឹងការប្រមូលចំណូលឱ្យអស់សក្តានុពលនៃប្រភពចំណូលមានស្រាប់ និងសក្តានុពលចំណូលថ្មីដែលមិនទាន់មានយន្តការប្រមូល។

ជារួម ការពង្រឹងប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព នៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ផ្តោតលើគោលដៅចម្បងៗដូចតទៅ ១)-ការពង្រឹងអភិបាលកិច្ច និងស្ថាប័ននៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ២)-ការពង្រឹងមុខងារស្នូលក្នុងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និង ៣)-ពង្រឹងមុខងារគាំទ្រដោយធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធឱ្យឆ្លើយតបនឹងតម្រូវការមុខងារស្នូល។

ជាមួយគ្នានេះ គោលនយោបាយចំណូលមិនមែនសារពើពន្ធ នឹងពិនិត្យថ្លឹងថ្លែងរវាងទិដ្ឋភាពចំណូល ទិដ្ឋភាពផលប៉ះពាល់ និងការពេញចិត្តពីសាធារណៈជន។ ក្នុងន័យនេះ គោលនយោបាយចំណូលមិនមែនសារពើពន្ធត្រូវឈរលើគោលការណ៍សំខាន់ចំនួន ៣ គឺ ១)-លើកកម្ពស់គុណភាពសេវាបម្រើសេចក្តីត្រូវការប្រកបដោយការជឿទុកចិត្តនិងការពេញចិត្តរបស់សាធារណៈជន ២)-ប្រសិទ្ធភាពចំណាយលើប្រតិបត្តិការប្រមូលចំណូល និង ៣)-ចៀសវាងផលប៉ះពាល់ជាអវិជ្ជមានដល់គោលនយោបាយទាក់ទាញវិនិយោគផ្ទាល់ពីបរទេស (FDI) ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម (SME) និងមិនបង្កការរាំងស្ទះដល់កំណើនសេដ្ឋកិច្ច។

## ៦.១ ការពង្រឹងអភិបាលកិច្ច និងស្ថាប័ននៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

ការពង្រឹងអភិបាលកិច្ច និងស្ថាប័នផ្នែកចំណូលមិនមែនសារពើពន្ធ ក្នុងដំណាក់កាលទី៣ ២០២៤-២០២៨ ត្រូវបានតម្រង់ទិសទៅរកការបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងតាមរយៈការពង្រឹងសមត្ថភាពមនុស្សនិងស្ថាប័ន ក្នុងនោះមានការវិភាគមុខងារនិងការកែទម្រង់រចនាសម្ព័ន្ធ ការពង្រឹងយន្តការស្ថាប័ននិងធនធានមនុស្ស ការពង្រឹងកិច្ចសហការនិងការទទួលខុសត្រូវ និងការអនុវត្តយន្តការលើកទឹកចិត្តឱ្យចំគោលដៅ ព្រមទាំងការពង្រឹងការអនុវត្តច្បាប់។ ដោយសារចំណូលមិនមែនសារពើពន្ធ មានច្រើនប្រភេទ

នៅរាយប៉ាយ និងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង-ស្ថាប័នផ្សេងគ្នា អភិបាលកិច្ចល្អ ទាមទារនូវការកែទម្រង់ប្រព័ន្ធគ្រប់គ្រងប្រកបដោយនវានុវត្តន៍និងមានប្រសិទ្ធភាពខ្ពស់។ ដូច្នេះ ការពង្រឹងអភិបាលកិច្ច គឺជាការកែទម្រង់គន្លឹះ ឆ្ពោះទៅការពង្រឹងសង្គតិភាព និងសុខដុមនីយកម្ម រវាងមុខងារស្នូល និងមុខងារគាំទ្រ ដែលបង្កើតបាននូវសេហថាមពល ដើម្បីឱ្យការប្រមូលចំណូលមិនមែនសារពើពន្ធ កាន់តែមានភាពល្អប្រសើរ និងអស់សក្ដានុពល។ ក្នុងន័យនេះ ការពង្រឹងអភិបាលកិច្ចរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ នឹងត្រូវធ្វើឡើងដោយឈរលើគោលការណ៍សំខាន់ៗ ៣ រួមមាន៖ ១)-ការពង្រឹងសមត្ថភាព និងការចូលរួមអនុវត្តពេញលេញ ២)-ការពង្រឹងមុខងារ និងការកែទម្រង់ស្ថាប័ន ៣)-គណនេយ្យភាពនិងតម្លាភាព។

**កន្លងមក ការអនុវត្តនៅមានបញ្ហាប្រឈម និងផលលំបាកមួយចំនួន ជាអាទិ៍៖**

- កិច្ចសហការរវាងក្រសួង-ស្ថាប័នអនុវត្តនៅមានកម្រិត ជាពិសេសលើកិច្ចសហការការងារដែលមានលក្ខណៈប្រទាក់ក្រឡារវាងអន្តរក្រសួង-ស្ថាប័ន ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តលើការចាត់ចែងប្រភេទចំណូលមិនមែនសារពើពន្ធ
- ការផ្ដល់របាយការណ៍វឌ្ឍនភាព នៅមានភាពយឺតយ៉ាវ និងកិច្ចសហការនៅមានកម្រិតក្នុងការផ្ដល់ទិន្នន័យ និងឯកសារគតិយុត្ត សម្រាប់យន្តការតាមដាន និងត្រួតពិនិត្យ
- មន្ត្រីអនុវត្ត នៅមិនទាន់មានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការបំពេញតួនាទីលើការងារទទួលបន្ទុក
- ការពង្រឹងស្ថាប័ននៅមានកម្រិត ដែលទាមទារនូវការបន្តកែទម្រង់ តាមរយៈការវិភាគមុខងារ ការពង្រឹងរចនាសម្ព័ន្ធ និងការរៀបចំយន្តការស្ថាប័ន
- នីតិវិធីនៃការអនុវត្តការងារពាក់ព័ន្ធនឹងការប្រមូលចំណូល និងការបង់ចំណូល ទាមទារនូវការពិនិត្យឡើងវិញ និងពង្រឹងបន្ថែមឱ្យកាន់តែមានភាពច្បាស់លាស់ និងតម្លាភាព និង
- សមត្ថភាពរៀបចំផែនការចំណូល និងការគ្រោងចំណូល នៅមានកម្រិត។

៧៦. **ក្នុងន័យនេះ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- ជំរុញឱ្យក្រសួង-ស្ថាប័ន និង អង្គភាពពាក់ព័ន្ធ រៀបចំកិច្ចប្រជុំប្រចាំត្រីមាស/ឆ្នាំ ដើម្បីធ្វើការពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការដែលបានដាក់ចេញ
- ពង្រឹងយន្តការផ្ដល់ព័ត៌មាន ទិន្នន័យ និងរបាយការណ៍វឌ្ឍនភាពឱ្យបានទាន់ពេល
- ពង្រឹងការគ្រប់គ្រង និងពិនិត្យឡើងវិញ លើការអនុវត្តច្បាប់ពាក់ព័ន្ធនានា ទៅតាមមុខងារមន្ត្រីអនុវត្តផ្ទាល់
- ពង្រឹងការទទួលខុសត្រូវរបស់មន្ត្រីទទួលបន្ទុកឱ្យបានខ្ជាប់ខ្ជួន តាមរយៈការចងក្រងនូវច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តនានា
- អនុវត្តការវិភាគមុខងារតាមក្រសួង-ស្ថាប័ន ដោយផ្ដោតលើការកែទម្រង់និងការពង្រឹងរចនាសម្ព័ន្ធពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការប្រមូលចំណូលមិនមែនសារពើពន្ធ និង
- បែងចែក និងរៀបចំការទទួលខុសត្រូវឱ្យបានច្បាស់រវាងក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- បន្តការពង្រឹងស្ថាប័ន ដោយពង្រឹងការអនុវត្តមុខងារនិងរចនាសម្ព័ន្ធដែលបានកែទម្រង់ ព្រមទាំងពង្រឹងយន្តការស្ថាប័ននិងធនធានមនុស្ស
- ពង្រឹងចំណេះដឹងមន្ត្រីនិងក្រមប្រតិបត្តិវិជ្ជាជីវៈ ដោយរួមបញ្ចូលជាមួយនឹងការជំរុញការប្រើប្រាស់បច្ចេកវិទ្យា
- ពង្រឹងការទទួលខុសត្រូវរបស់អង្គភាពទទួលបន្ទុក តាមរយៈការរៀបចំផែនការគ្រប់គ្រង ឬ ថ្លឹងថ្លែងរវាងចំណាយនិងចំណូលឱ្យមានប្រសិទ្ធភាព លើការងារពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ
- ពង្រឹងការគ្រោង និងព្យាករណ៍ចំណូល នៅតាមក្រសួង-ស្ថាប័ន និងគិតតាមមុខចំណូលនីមួយៗ
- ពង្រឹងបន្ថែមនូវប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ពិសេសលើការងារផ្តល់សេវាសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ និង
- សិក្សាវាយតម្លៃអំពីចំណូលមិនមែនសារពើពន្ធ ដើម្បីតម្រង់ទិសគោលនយោបាយចំណូលមិនមែនសារពើពន្ធ។

### ៦.២. ការពង្រឹងមុខងារស្នូលក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ

ការពង្រឹងមុខងារប្រតិបត្តិការស្នូលក្នុងការប្រមូលចំណូលមិនមែនសារពើរពន្ធ គឺជាអាទិភាពគន្លឹះនៃ **យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា**។ មុខងារស្នូល ត្រូវបានផ្តោតលើការអនុវត្តល្អ ឬដំណើរការការងារល្អ, គ្រប់គ្រងបានគ្រប់មុខចំណូល និងអនុវត្ត ការប្រមូលដោយតម្លាភាព គណនេយ្យភាព និងសមធម៌ ផ្អែកលើគោលការណ៍ច្បាប់និងគតិយុត្ត។ ការពង្រឹងមុខងារប្រតិបត្តិការស្នូល គឺជាការបង្កើនគុណភាព និងប្រសិទ្ធភាព តាមរយៈការព្យាករនិងគ្រោងចំណូលមានភាព-សុក្រឹតជាងមុន ការអនុវត្តការប្រមូលចំណូលសកម្មជាងមុន ការបង់ ឬបង្វែរចំណូលចូលថវិកាជាតិបានលឿនជាងមុន ការចំណាយលើប្រតិបត្តិការប្រមូលចំណូលតិចជាងមុន ការកត់ត្រាតាមដាន និងរៀបចំរបាយការណ៍ល្អប្រសើរជាងមុន។ ទន្ទឹមនេះ ការពង្រឹងការអនុវត្ត នឹងផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការពន្លឿនការអនុវត្តវិធានការដែលនៅសេសសល់ និងពិនិត្យលើសក្តានុពលចំណូលមិនមែនសារពើពន្ធគ្រប់ទម្រង់ដែលកំពុងកប់/លាក់ខ្លួន ដើម្បីកសាងមូលដ្ឋាននៃការប្រមូលចំណូលមិនមែនសារពើពន្ធមួយដែលមានលក្ខណៈច្បាស់លាស់ និងអាចប៉ាន់ប្រមាណបាន។ បន្ថែមលើនេះ ការសិក្សាលើប្រភពចំណូលថ្មី និងការរៀបចំកំណត់យន្តការប្រមូល ត្រូវធ្វើជាប្រចាំ។

៧៨. ក្នុងន័យនេះ ការពង្រឹងមុខងារស្នូល នឹងត្រូវដោះស្រាយបញ្ហាប្រឈម ដោយការពង្រឹងការអនុវត្តតាមប្រភេទចំណូលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដោយផ្តោតអាទិភាពទៅលើ៖ ១)-ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ២)-ចំណូលពីសហគ្រាសសាធារណៈ ៣)-ចំណូលពីសេវាសាធារណៈ ៤)-ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម និង ៥)-ចំណូលមិនមែនសារពើពន្ធដទៃទៀត។ ជាមួយគ្នានេះ យុទ្ធសាស្ត្រកៀរគរចំណូល នឹងពិនិត្យឡើងវិញអំពីប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងពង្រឹងការគ្រប់គ្រងនិងការប្រមូលពីមុខសញ្ញាចំណូលថ្មីៗ ក្នុងផ្នែកសំខាន់ៗ ដូចជា៖ ការលក់កាបូនឥណទានកាបូន ធនធានធម្មជាតិ (រ៉ែ) និងសក្តានុពលចំណូលថ្មី ជាដើម។

### ក. ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ

ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ គឺជាចំណូលពីការលក់ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ ចំណូលពីសម្បទានសេវាសាធារណៈ ចំណូលពីធនធានធម្មជាតិ និងចំណូលផ្សេងៗទៀត ដែលមានចែងក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ មានជាអាទិ៍ ចំណូលពីការលក់ ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋជាចលនទ្រព្យ និងអចលនទ្រព្យ ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋដែលជាថ្លៃឈ្នួល ភាគចំណែករបស់រដ្ឋ និងការបែងចែកផលចំណេញ ដូចមានចែងក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងនៃការជួលទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យ និង/អចលនទ្រព្យ ចំណូលពីសម្បទានសេវាសាធារណៈ រួមមានចំណូលពីគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងចំណូលពីសម្បទានគ្រប់គ្រងសេវាសាធារណៈ ចំណូលពីធនធានធម្មជាតិ សម្បទានរ៉ែ ចំណូលពីប្រេងកាត សម្បទានដីសេដ្ឋកិច្ច ផលព្រៃឈើ អនុផលព្រៃឈើ ផលពីនេសាទ ធនធានកម្រ និងធនធានធម្មជាតិដទៃទៀត តាមរយៈលិខិតបទដ្ឋានគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ក្នុងទម្រង់ជាកម្រៃសួយសារ ឬការបង់ថ្លៃឈ្នួល ឬបុព្វលាភ ឬភាគចំណែករបស់រដ្ឋ ឬការបែងចែកផល ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន និងចំណូលផ្សេងៗទៀត ដែលមានចែងក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ។

កន្លងមក ការអនុវត្ត នៅមានបញ្ហាប្រឈម និងផលលំបាកមួយចំនួន រួមមាន៖

- ភាពចន្លោះប្រហោងក្នុងការត្រួតពិនិត្យ តាមដាន ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- ការគ្រប់គ្រងចំណូល ពុំទាន់មានគណនេយ្យភាពគ្រប់គ្រាន់និងការប្រមូលមិនទាន់អស់លទ្ធភាព
- ការកត់ចំណូលតាមអនុគណនី ពុំមានលម្អិតតាមមុខសញ្ញាចំណូលតូចៗ ដែលបង្កការលំបាកជាពិសេសសម្រាប់ការតាមដាន វិភាគនិងវាយតម្លៃ
- ការពុំទាន់បង្កើតជាស្តង់ដារួម ឬ គោលការណ៍ណែនាំពាក់ព័ន្ធនឹងការធ្វើផែនការ និងព្យាករចំណូល
- ការជួលទីតាំងទ្រព្យសម្បត្តិរដ្ឋមួយចំនួន ជាពិសេសការជួលកោះត្រូវបានទុកចោល ដោយពុំបានអនុវត្តតាមគម្រោង
- គម្រោងរបស់ក្រុមហ៊ុនមួយចំនួន ដែលទទួលបានសិទ្ធិពីរដ្ឋ បានដំណើរការយឺតយ៉ាវ ឬ មិនដំណើរការសោះ ដូចជា ក្រុមហ៊ុនអនុវត្តសម្បទានដីសេដ្ឋកិច្ច ក្រុមហ៊ុនធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មធនធានរ៉ែ ឧស្ម័ន និងប្រេងកាត ជាដើម
- ការខ្វះខាតក្នុងការផ្តល់កិច្ចសហការពីក្រសួង-ស្ថាប័នពាក់ព័ន្ធ លើការផ្តល់ឯកសារ របាយការណ៍ និងព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅក្រោមការកាន់កាប់របស់ខ្លួន
- ការខ្វះខាតមន្ត្រីបំពេញការងារនៅថ្នាក់ក្រោមជាតិ ដែលពិបាកក្នុងការបំពេញមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងទទួលមុខងារបន្ថែមពីថ្នាក់ជាតិ និង
- កង្វះមន្ត្រីបច្ចេកទេស ដែលមានជំនាញច្បាស់លាស់ក្នុងវិស័យរ៉ែ។

**ក្នុងន័យនេះ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- បង្កើត និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ ដើម្បីពង្រឹងគណនេយ្យភាព តាមរយៈការរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយនូវលិខិតបទដ្ឋានគតិយុត្តនានា ក្នុងវិស័យសំខាន់ៗ
- ពង្រឹងការយកចិត្តទុកដាក់ក្នុងការប្រមូលជាតុចូល និងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមរបស់វិស័យឯកជន តាមរយៈវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន
- ពង្រឹងការទទួលខុសត្រូវ និងកំណត់មុខងារច្បាស់លាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនាមជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ
- រៀបចំឱ្យបាននូវការកត់ត្រាលម្អិតតាមមុខសញ្ញាចំណូលតូចៗ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ពង្រឹងប្រសិទ្ធភាពយន្តការអន្តរស្ថាប័នប្រទាក់ក្រឡាគ្នារវាងក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយ ក.ស.ហ.វ. ក្នុងការគ្រប់គ្រង និងការកៀរគរចំណូល
- គ្រប់គ្រង និងប្រមូលចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋឱ្យបានពេញលេញ និងប្រកបដោយគណនេយ្យភាព ដោយផ្អែកលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ដោះស្រាយ និងជម្រះករណីមិនប្រក្រតីពីការប្រមូលចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ដោយជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានាឱ្យបានម៉ឺងម៉ាត់
- ជំរុញការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ និងចុះបញ្ជីដីរដ្ឋឱ្យបានពេញលេញ ទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ជំរុញការរៀបចំផែនការនៃការតឹងទារបំណុលមិនមែនសារពើពន្ធ ផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និង
- ធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

*វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖*

- បន្តរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ សម្រាប់អនុវត្តច្បាប់ស្តីពីការ-គ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- ពង្រឹងការគ្រប់គ្រង ដោយពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងពង្រឹងយន្តការត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីធានាបាននូវការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព និងស្ថិរភាពនៃធនធានធម្មជាតិ
- បន្តរៀបចំឱ្យបាននូវការកត់ត្រាលម្អិតតាមមុខសញ្ញាចំណូលតូចៗ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- បន្តធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល
- ពន្លឿនក្រសួង-ស្ថាប័នក្នុងការបំពេញឱ្យបានប្រតិបត្តិការជាប្រក្រតីតាមការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន លើរាល់ប្រតិបត្តិការទាក់ទងនឹងការប្រមូលចំណូលពីទ្រព្យសម្បត្តិរដ្ឋ
- ពិនិត្យ និងជំរុញក្រុមហ៊ុនដែលទទួលបានសិទ្ធិពីរដ្ឋ សម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មធនធានរ៉ែ ឧស្ម័ន និងប្រេងកាត ជាដើម ឱ្យបន្តដំណើរការអនុវត្តតាមកិច្ចសន្យា ឬចាត់វិធានការសមស្របណាមួយចំពោះករណីមិនមានអនុលោមភាព

- បន្តសិក្សាលទ្ធភាពកែសម្រួលកម្រៃសេវា និងអត្រាសួយសារពាក់ព័ន្ធនឹងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងការកែសម្រួលកិច្ចសន្យាជីសម្បទានឱ្យស្របតាមទិដ្ឋភាពសេដ្ឋកិច្ច និងតម្លៃសេដ្ឋកិច្ច
- ជំរុញយន្តការតាមដាន និងវាយតម្លៃ លើការអនុវត្តរបស់ក្រុមហ៊ុនឯកជនដែលទទួលបានសិទ្ធិពីរដ្ឋ ក្នុងការសិក្សាស្វែងរក និងធ្វើអាជីវកម្មធនធានរ៉ែឧស្ម័ន និងប្រេងកាត ឱ្យស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និង
- ជំរុញការបង្កើតបរិយាកាសទាក់ទាញធុរកិច្ច និងការវិនិយោគ ដល់វិស័យឯកជន ក្នុងការធ្វើអាជីវកម្មលើទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានអនុញ្ញាត ដើម្បីបង្កើនចំណូលបន្ថែម។

### ខ. ចំណូលពីសហគ្រាសសាធារណៈ

ក្នុងន័យពង្រឹងការគ្រប់គ្រងចំណូលនិងសម្រួលការរៀបចំវិធានការក្នុងផ្នែកនេះ ដែលរួមមានចំណូលពីសហគ្រាសសាធារណៈ ភាគហ៊ុនរបស់រដ្ឋ និងចំណូលពីអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត។ ចំណូលប្រភេទនេះបានមកពី ភាគលាភឬអតិរេកសាច់ប្រាក់ ភាគលើសនៃទុនទំនេរ ការបង់សាច់ប្រាក់ និងសមមូលសាច់ប្រាក់ ក្រោយពីសហគ្រាសនិងអង្គភាព ត្រូវបានរំលាយ។ កន្លងមក ទោះបីជាមានច្បាប់ និងបទដ្ឋានគតិយុត្តមួយចំនួន សម្រាប់គ្រប់គ្រងចំណូលប្រភេទនេះក៏ដោយ ក៏ការអនុវត្តនៅមានកម្រិត ដែលធ្វើឱ្យការប្រមូលចំណូលនិងការបង់ចំណូលនៅខ្វះចន្លោះ មិនទាន់គ្រប់ជ្រុងជ្រោយ។

ក្នុងប្រភេទចំណូលនេះ បញ្ហាប្រឈមនៅសេសសល់ និងផលលំបាកក្នុងការអនុវត្ត មានដូចជា៖

- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងការធ្វើអាជីវកម្មរបស់សហគ្រាសសាធារណៈ ពុំឆ្លើយតបទៅនឹងការវិវឌ្ឍនៃសង្គម-សេដ្ឋកិច្ចជាក់ស្តែងនៅឡើយ ដោយសារកត្តាអាយុកាលនៃលិខិតបទដ្ឋានគតិយុត្ត
- ពុំទាន់មានយន្តការ សមស្របលើការគ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃលើភាគហ៊ុនរបស់រដ្ឋទាំងនៅសហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះ និង
- សហគ្រាសសាធារណៈមួយចំនួន ទទួលបានគោលការណ៍លើកទឹកចិត្ត ដោយពុំបង់ភាគលាភប្រចាំឆ្នាំ និងមួយចំនួនទៀតមានការខាតបង់ក្នុងអាជីវកម្ម។

**ក្នុងន័យនេះ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

**វិធានការរយៈពេលខ្លី ២០២៤-២០២៥៖**

- ពង្រឹងឱ្យបានពេញលេញ លើការគ្រប់គ្រង និងការកត់ត្រាចំណូលពី សហគ្រាសសាធារណៈ ភាគហ៊ុនរបស់រដ្ឋ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដែលត្រូវបង់ភាគលាភ ឬអតិរេកសាច់ប្រាក់ ភាគលើសនៃទុនទំនេរ និងការបង់សាច់ប្រាក់ ឬសមមូលជាសាច់ប្រាក់ជាចំណែករបស់រដ្ឋ និង
- ពន្លឿនការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង សហគ្រាសសាធារណៈ និងភាគហ៊ុនរបស់រដ្ឋ ដោយឆ្លុះបញ្ចាំងគ្រប់ជ្រុងជ្រោយលើទិដ្ឋភាពចំណូល និងពង្រឹងការអនុវត្តច្បាប់។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- បន្តជំរុញការបង់ និងការកត់ត្រាចំណូលពី សហគ្រាសសាធារណៈ ជាពិសេស សហគ្រាសសាធារណៈដែលទទួលបានការលើកលែងការបង់ភាគលាភ

- ពិនិត្យលទ្ធភាពបង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃ សហគ្រាសសាធារណៈ និងភាគហ៊ុនរបស់រដ្ឋ និងសាកល្បងសិក្សាវាយតម្លៃអំពីប្រសិទ្ធភាព ភាពចាំបាច់នៃគោលនយោបាយ និងកម្មវិបាកនៃសហគ្រាសសាធារណៈ
- ត្រូវសិក្សា ពិនិត្យ និងធ្វើការកែសម្រួលបទប្បញ្ញត្តិ/លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសហគ្រាសសាធារណៈ ដោយដាក់ចេញឱ្យស្របតាមខ្លឹមសារនៃច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ និង
- ពង្រឹងការគ្រប់គ្រង និងប្រមូលចំណូល ស្របតាមច្បាប់ថ្មី។

### គ. ចំណូលពីសេវាសាធារណៈ

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ចំណូលពីសេវាសាធារណៈ ជាចំណូលដែលប្រមូលបានមកពីការបង់កម្រៃនៃការប្រើប្រាស់សេវាសាធារណៈដោយរូបវន្តបុគ្គល ឬនីតិបុគ្គលសម្រាប់សេវាបង់ថ្លៃរបស់រដ្ឋ។ ការផ្តល់សេវាសាធារណៈ និងការប្រមូលចំណូលពីសេវាសាធារណៈ ត្រូវបានអនុវត្តដោយក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលដៅបម្រើផលប្រយោជន៍ទូទៅ។ កម្រៃសេវាសាធារណៈ ជាកម្មវត្ថុ ដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលពាក់ព័ន្ធ។ ចំណូលពីសេវាសាធារណៈ មានប្រភេទច្រើន នៅរាយប៉ាយតាមគ្រប់វិស័យ ក្នុងនោះមានប្រភេទចំណូលធំៗដូចជា ផលទុនអាកាសចរណ៍ស៊ីវិល ចំណូលពីវិស័យទេសចរណ៍ រួមទាំងចំណូលពីទិដ្ឋាការនិងលិខិតឆ្លងដែន និង ផលទុនពីប្រៃសណីយ៍និងទូរគមនាគមន៍ ជាដើម។ ចំណូលពីសេវាសាធារណៈមានទំហំធំដល់ប្រមាណ ៧០% នៃចំណូលមិនមែនសារពើពន្ធ (ទិន្នន័យឆ្នាំ២០២៣) និងមានសក្តានុពលខ្ពស់ ដែលត្រូវពង្រឹងការប្រមូលស្របតាមនិន្នាការសេដ្ឋកិច្ចនិងសង្គម ក្នុងកាលៈទេសៈនៃការស្តារនិងជំរុញកំណើនសេដ្ឋកិច្ច។ ការគ្រប់គ្រងចំណូលទាំងនេះ ទាមទារនូវការយកចិត្តទុកដាក់ជាពិសេស ក្នុងន័យថ្លឹងថ្លែងរវាងទិដ្ឋភាពចំណូល និងទិដ្ឋភាពផលប៉ះពាល់នានា ដូចជាការប៉ះពាល់លើគោលនយោបាយលើកកម្ពស់សហគ្រាសធុនតូចនិងមធ្យម សេដ្ឋកិច្ច និងសង្គម ជាដើម ដែលក្នុងនោះការកំណត់តម្លៃសេវា និងការពង្រឹងគុណភាពសេវា គឺជាគោលដៅគន្លឹះ ។

កន្លងមក ការអនុវត្តនៅមានបញ្ហាប្រឈម និងផលលំបាកមួយចំនួន ជាអាទិ៍៖

- ក្របខ័ណ្ឌគតិយុត្តនៃការប្រមូលចំណូលពីសេវាសាធារណៈ នៅមានភាពស្មុគស្មាញ និងពុំទាន់មានសង្គតិភាពពេញលេញ ដោយសារតែគោលការណ៍ណែនាំថ្មីៗមួយចំនួន និងតម្រូវការធ្វើបច្ចុប្បន្នភាពជាប្រចាំនូវប្រកាសអន្តរក្រសួង
- ការកំណត់តម្លៃសេវាសាធារណៈ នៅពុំទាន់មានបទដ្ឋាន ឬនិយាមគោលណាមួយឡើយ
- គុណភាពសេវានៅតែជាបញ្ហាប្រឈម ដោយការផ្តល់សេវាសាធារណៈរបស់ក្រសួង-ស្ថាប័នមួយចំនួន និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅមានភាពយឺតយ៉ាវ និងស្មុគស្មាញ និង
- សេវាសាធារណៈខ្លះ ត្រូវបានបែងចែកច្រើនសមត្ថកិច្ច និងគ្រប់គ្រងជាន់គ្នា ដែលបង្កការលំបាក និងគ្មានប្រសិទ្ធភាព។

**ក្នុងន័យនេះ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖**

*វិធានការរយៈពេលខ្លី ២០២៤-២០២៥៖*

- ដាក់ចេញលិខិតបទដ្ឋានគតិយុត្តក្នុងការរៀបចំឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ចំពោះការប្រមូលចំណូលពីសេវាសាធារណៈ
- បន្តពិនិត្យ និងកែសម្រួល ថ្លៃសេវាសាធារណៈនានា ដែលប៉ះពាល់ឬអាចជះឥទ្ធិពលដល់ទេសចរណ៍ អាជីវកម្ម និងការទាក់ទាញវិនិយោគ និងឱ្យស្របតាមស្ថានភាពសេដ្ឋកិច្ចនិងសង្គម
- បន្តពង្រឹងគុណភាពសេវា និងជំរុញដំណើរការទូទាត់តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឱ្យបានពេញលេញ
- ពង្រឹង និងកសាងសមត្ថភាព តាមរយៈការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ទាំងកម្រិតថ្នាក់ដឹកនាំ និងកម្រិតបច្ចេកទេស
- ពិនិត្យអាជ្ញាបណ្ណឡើងវិញចំពោះ មុខសញ្ញាអាជ្ញាបណ្ណដែលមានគោលបំណងដូចគ្នា និងការបែងចែកសមត្ថកិច្ច
- បែងចែកសមត្ថកិច្ចគ្រប់គ្រង និងប្រមូលចំណូលពីសេវាសាធារណៈរបស់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ការផ្ទេរមុខងារពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ) និង
- សិក្សា និងពិនិត្យលទ្ធភាពរៀបចំប្រព័ន្ធបច្ចេកវិទ្យា សម្រាប់ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធអនឡាញ។

*វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖*

- រៀបចំគោលការណ៍ ពិនិត្យឡើងវិញនូវកម្រងសេវាសាធារណៈ និងថ្លៃសេវា
- រៀបចំក្រុមការងារ ដើម្បីសិក្សា និងរៀបចំវិធីសាស្ត្រ សម្រាប់កំណត់ថ្លៃសេវា ឱ្យស្ថិតក្នុងបទដ្ឋានរួម និង
- ពង្រឹងការផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យា (សេវាអនឡាញ) ជាពិសេសការផ្តល់សេវាចំពោះធុរកិច្ច។

## ឃ. ចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្ម

ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម មានដូចជា ចំណូលពីការផាកពិន័យ ចំណូលពីការផ្តន្ទាទោសពិន័យជាប្រាក់ ចំណូលពីការរឹបអូស ផលពីការពិន័យផ្សេងៗ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។ ចំណូលនេះ ជាប្រភេទចំណូលមិនទៀងទាត់ ដែលកន្លងមក នៅមានបញ្ហាប្រឈម និងផលលំបាកមួយចំនួន ជាអាទិ៍

- ចំណូលនេះមានភាពលំបាកក្នុងការព្យាករ និងធ្វើផែនការប្រមូលចំណូលឱ្យបានច្បាស់លាស់
- ពិរុទ្ធជនមួយចំនួនគ្មានលទ្ធភាពបង់ប្រាក់ពិន័យ ឬពុំព្រមបង់ប្រាក់ពិន័យតាមសេចក្តីសម្រេចរបស់តុលាការ
- ការអនុវត្តនៅមានភាពស្មុគស្មាញ ដោយការគ្រប់គ្រងចំណូលនៅរាយប៉ាយតាមក្រសួង-ស្ថាប័ន ក្រុមការងារអន្តរក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ដំណើរការនីតិវិធីតុលាការ ត្រូវការពេលយូរ នាំឱ្យទ្រព្យសម្បត្តិរឹបអូសពីបទល្មើស ទ្រុឌទ្រោម អស់តម្លៃសេដ្ឋកិច្ច និង

- យន្តការសម្រាប់ត្រួតពិនិត្យ តាមដាន និងជំរុញការបង់ប្រាក់ពិន័យតាមសេចក្តីសម្រេចស្ថាពររបស់សាលាជម្រះក្តីនៅពុំទាន់មានភាពច្បាស់លាស់។

**ក្នុងន័យនេះ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួន ដូចខាងក្រោម៖**

**វិធានការរយៈពេលខ្លី ២០២៤-២០២៥៖**

- ជំរុញការអនុម័តច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក និងរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ ឬចាត់ចែងទ្រព្យសម្បត្តិរឹបអូសពីបទល្មើសនានា និងបង់ចំណូលចូលថវិការដ្ឋ ស្របតាមនីតិវិធីជាធរមាន
- បន្តសិក្សា និងកំណត់ភាពមិនប្រក្រតីនៃការបង់ប្រាក់របស់ពិរុទ្ធជនឱ្យបានច្បាស់លាស់
- ជំរុញសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ក្នុងការចេញសេចក្តីសម្រេចស្ថាពរ ដែលពាក់ព័ន្ធនឹងបទល្មើសមានវត្ថុតាងរឹបអូសជាទ្រព្យសម្បត្តិរដ្ឋមានតម្លៃសេដ្ឋកិច្ចខ្ពស់ ឬងាយបាត់បង់តម្លៃសេដ្ឋកិច្ច
- ពង្រឹងយន្តការច្បាស់លាស់ សម្រាប់ត្រួតពិនិត្យ តាមដាន និងជំរុញការបង់ប្រាក់ពិន័យតាមសេចក្តីសម្រេចជាស្ថាពររបស់សាលាជម្រះក្តី និង
- ពិនិត្យកែសម្រួលឡើងវិញ នូវលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការបែងចែកប្រាក់រង្វាន់ ពីចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្ម ។

**វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖**

- ពង្រឹងក្របខ័ណ្ឌការងាររបស់សាលាជម្រះក្តី ក្នុងការចាត់ចែងទ្រព្យសម្បត្តិផ្សេងៗ ឱ្យក្លាយជាចំណូលចូលរដ្ឋ
- សិក្សា វាយតម្លៃ ពីប្រសិទ្ធភាពនៃវិធានការពិន័យ និងការដាក់ទណ្ឌកម្ម ពាក់ព័ន្ធនឹង ការប្រមូលចំណូល និងទប់ស្កាត់ការកើនឡើងនៃបទល្មើស និង
- សិក្សា និងពិនិត្យធ្វើបច្ចុប្បន្នភាពលើអត្រាប្រាក់ពិន័យ និងទណ្ឌកម្ម។

### ង. ចំណូលមិនមែនសារពើពន្ធដទៃទៀត

ចំណូលមិនមែនសារពើពន្ធដទៃទៀត ជាចំណូលដែលទទួលបានមកពីទ្រព្យនិទាឃាទ ទ្រព្យគ្មានម្ចាស់ ប្រទានកម្ម អច្ច័យទាន វិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ វិស័យល្បែងពាណិជ្ជកម្ម ផលហិរញ្ញវត្ថុ ផលផ្សេងៗ និងផលពិសេសដទៃទៀត មូលនិធិទៅតាមវិស័យពាក់ព័ន្ធ។ បន្ថែមលើប្រភេទចំណូលដូចមានរៀបរាប់ខាងលើ ប្រភេទចំណូលពិសេសមួយចំនួនទៀត ត្រូវបានគិតគូរ ពោលគឺ ចំណូលពីការលក់កាបូន/ឥណទានកាបូន។ ឥណទានកាបូននៅកម្ពុជា ត្រូវបានពិនិត្យឃើញថាមានសម្ទុះខ្លាំងគួរឱ្យចាប់អារម្មណ៍ ជាពិសេសប្រភេទឥណទានកាបូន ដែលអាចជាប្រភពចំណូលថ្មីមួយ សម្រាប់បង្កើនចំណូលថវិកាជាតិ។

កន្លងមក ការអនុវត្តនៅមានបញ្ហាប្រឈម និងផលលំបាកមួយចំនួន ជាអាទិ៍៖

- កង្វះនូវលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ដែលចែងលម្អិតអំពីវិធាន និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងចាត់ចែងប្រភេទចំណូលមិនមែនសារពើពន្ធខាងលើ

- ប្រភពចំណូលមិនមែនសារពើពន្ធដទៃទៀត មានភាពលំបាកក្នុងការព្យាករ និងប៉ាន់ស្មានពីការកើនឡើងនិងថយចុះ
- ប្រភពចំណូលមិនមែនសារពើពន្ធដទៃទៀត ពុំទាន់មានយន្តការគ្រប់គ្រងច្បាស់លាស់នៅឡើយ និង
- ការសិក្សាស្រាវជ្រាវស្វែងរកប្រភពចំណូលថ្មី នៅមិនទាន់អស់លទ្ធភាពនៅឡើយ។

**ក្នុងន័យនេះ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួន ដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- រៀបចំលិខិតបទដ្ឋានគតិយុត្តឱ្យបានលម្អិតក្នុងការកំណត់ និងចាត់ចែងប្រភេទចំណូលមិនមែនសារពើពន្ធដទៃទៀតដូចខាងលើ
- ពិនិត្យលទ្ធភាពប្រមូលចំណូលពីវិស័យសក្តានុពលថ្មីៗ ឬពុំទាន់មានយន្តការប្រមូលច្បាស់លាស់
- ពង្រីកការអនុវត្តយន្តការផលជាទានកាបូន និងពង្រឹងការប្រមូលចំណូល
- បន្ថែមការរៀបចំយន្តការឱ្យបានច្បាស់លាស់ក្នុងការគ្រប់គ្រង ដូចជា ចំណូលពីប្រទានកម្ម ទ្រព្យគ្មានម្ចាស់គ្រប់គ្រង អច្ច័យទាន និងចំណូលពីទ្រព្យនិទាឃាទ ជាដើម និង
- សិក្សាស្រាវជ្រាវស្វែងរកប្រភពចំណូលថ្មីឱ្យអស់លទ្ធភាព សមស្របតាមស្ថានភាពសេដ្ឋកិច្ច។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- បន្តសិក្សាអំពីប្រភពចំណូលមិនមែនសារពើពន្ធផ្សេងៗ នៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ
- បន្តពង្រឹងការយន្តការប្រមូលចំណូលពីផលជាទានកាបូនឱ្យមានប្រសិទ្ធភាព ស្របតាមតម្លៃសេដ្ឋកិច្ច និង
- រៀបចំយន្តការទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល តាមរយៈគណៈកម្មការអន្តរក្រសួង។

## ៦.៣. ការពង្រឹងមុខងារគាំទ្រការគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ

មុខងារប្រតិបត្តិការគ្រាំទ្រ ដើរតួរយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពដល់ការកៀរគរចំណូលមិនមែនសារពើពន្ធ។ មុខងារនេះផ្តោតសំខាន់លើការគ្រប់គ្រង និងប្រតិបត្តិការកៀរគរចំណូលមិនមែនសារពើពន្ធរបស់អង្គភាពនិងស្ថាប័ន ដែលមានកាតព្វកិច្ចកៀរគរចំណូលមិនមែនសារពើពន្ធជូនរដ្ឋ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ការពង្រឹងមុខងារគាំទ្រក្នុងការប្រមូលនិងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ទាមទារនូវកត្តា ២ សំខាន់គឺ ១)- ធនធានមនុស្សដែលមានសមត្ថភាព និងជំនាញវិភាគដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ២)- ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលគាំទ្រការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលកន្លងមក សម្រេចបានសមិទ្ធផល មួយចំនួនលើការដ្ឋានទំនើបកម្មប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងនោះបានកសាងប្រព័ន្ធដូចជា ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) និងបន្ថែមលើនេះ បានរៀបចំនិងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) សម្រាប់ការបង់ចំណូល។ ប្រព័ន្ធទាំងនេះ បានជួយសម្រួលច្រើនដល់ការគ្រប់គ្រងបញ្ជីសារពើភណ្ឌ ការគ្រប់គ្រងការបង់ចំណូល និងការបង់ចំណូល។

ទន្ទឹមនឹងវឌ្ឍនភាពល្អប្រសើរនេះ ក៏ក្នុងការអនុវត្តជាក់ស្តែង នៅមានបញ្ហាប្រឈម និងការលំបាកមួយចំនួនដូចខាងក្រោម៖

- ប្រព័ន្ធ NRMIS មិនទាន់មានលក្ខណៈជាប្រព័ន្ធឌីជីថល និងស្វ័យប្រវត្តិកម្មពេញលេញនៅឡើយ
- នៅមានការលំបាកមួយចំនួនក្នុងការប្រើប្រាស់ NRMIS ដោយសារៈ ពុំទាន់មាន មុខងារកត់ត្រាបំណុលនិងប្រាក់ពិន័យ មុខងាររបាយការណ៍មិនទាន់ពេញលេញនិងទូលំទូលាយ ចំណាត់ថ្នាក់លេខកូដចំណូល សង្គតិភាពជាមួយប្រភេទចំណូល និងចំណាត់ថ្នាក់សេដ្ឋកិច្ច។ បន្ថែមលើនេះ ការធ្វើសន្ទានកម្មទិន្នន័យជាមួយប្រព័ន្ធរបស់ក្រសួង-ស្ថាប័នដទៃ ពុំទាន់មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅឡើយ ដែលទាមទារនូវការយកចិត្តទុកដាក់បន្ថែម សំដៅបង្កើនល្បឿនការងារធ្វើសន្ទានកម្ម និងកសាងប្រព័ន្ធឌីជីថល Ecosystem ហិរញ្ញវត្ថុមួយ ដែលពេញលេញ និងបំពេញឱ្យគ្នាទៅវិញទៅមកតាមការចង់បាន
- ប្រព័ន្ធ SARMIS មិនទាន់ប្រើប្រាស់ទូលំទូលាយ តម្រូវឱ្យធ្វើទំនើបកម្មបន្ថែម និងបង្កើនការបណ្តុះ-បណ្តាល
- មន្ត្រីទទួលបន្ទុកមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ លើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា រួមទាំង NRMIS និង SARMIS
- ការពង្រីកការប្រើប្រាស់ប្រព័ន្ធ អាចប្រឈមនឹងបញ្ហាសមត្ថភាព និងកង្វះហេដ្ឋារចនាសម្ព័ន្ធបច្ចេក-វិទ្យាព័ត៌មាន។

**ដើម្បីសម្រេចបាននូវលទ្ធភាពកាន់តែល្អប្រសើរបន្ថែមទៀត យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួន ដូចខាងក្រោម៖**

***វិធានការរយៈពេលខ្លី ២០២៤-២០២៥៖***

- ➢ បន្តជំរុញឱ្យមានការប្រើប្រាស់ NRMIS និង SARMIS ពេញលេញក្នុងក្រសួង-ស្ថាប័នគ្រប់លំដាប់ថ្នាក់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ➢ បន្តកែសម្រួល និងធ្វើបច្ចុប្បន្នភាព NRMIS និង SARMIS ដោយបន្ថែមមុខងារឱ្យគ្រប់តាមតម្រូវការប្រើប្រាស់ទាំងសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងធ្វើទំនើបកម្ម ដើម្បីដាក់ចេញឱ្យបាននូវប្រព័ន្ធដំណើរការគ្រប់ជ្រុងជ្រោយ ប្រកបដោយលក្ខណៈឌីជីថល និងស្វ័យប្រវត្តិកម្ម
- ➢ ជំរុញការធ្វើសន្ទានកម្ម NRMIS ជាមួយ SARMIS ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុង ក.ស.ហ.វ. ជាពិសេស FMIS និងប្រព័ន្ធនៃក្រសួង-ស្ថាប័នផ្សេងទៀត
- ➢ បន្ថែមការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបំពេញការអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
- ➢ បំពេញឱ្យបាននូវការធ្វើសន្ទានកម្ម និងកាត់បន្ថយបញ្ហាប្រឈមពាក់ព័ន្ធនឹងផ្នែករឹង ផ្នែកទន់ ទិន្នន័យមនុស្ស និងដំណើរការ
- ➢ ពង្រឹងយន្តការចែករំលែកព័ត៌មាន ទិន្នន័យ និងឯកសារពាក់ព័ន្ធពីក្រសួង-ស្ថាប័ន
- ➢ ពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់គាំទ្រ និងអនុវត្តប្រព័ន្ធ NRMIS និង ប្រព័ន្ធ SARMIS

- សម្រេចឱ្យបាននូវភាពត្រឹមត្រូវនៃការកំណត់លេខកូដចំណូលមិនមែនសារពើពន្ធ និងចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកា
- ផ្តោតការយកចិត្តទុកដាក់លើការជ្រើសរើសមន្ត្រីបច្ចេកទេស និងផ្តល់ការបណ្តុះបណ្តាលនៅកន្លែងបំពេញការងារ និង/ឬ ផ្តល់ជំនួយបច្ចេកទេស និងការសម្របសម្រួលដោយផ្ទាល់ ឬតាមប្រព័ន្ធអនឡាញ
- ផ្សព្វផ្សាយ បណ្តុះបណ្តាល និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) V2 ឱ្យពេញលេញ
- ពង្រឹងសមត្ថភាពស្ថាប័នក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ជាពិសេសការអនុវត្តឱ្យបានពេញលេញនូវប្រព័ន្ធ (SARMIS) V2
- ជំរុញការអនុវត្តការបង់ចំណូលតាមប្រព័ន្ធ e-payment ឱ្យបានពេញលេញ និង
- សិក្សា និងរៀបចំបង្កើតយន្តការឌីជីថលក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យ សម្រាប់គោលដៅនៃការប្រមូលចំណូលមិនមែនសារពើពន្ធ។

***វិធានការរយៈពេលមធ្យម ២០២៦-២០២៨៖***

- ជំរុញការបញ្ចូលរាល់ប្រតិបត្តិការចំណូលមិនមែនសារពើពន្ធ នៅថ្នាក់រដ្ឋបាលកណ្តាលក្រសួង-ស្ថាប័ន និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រព័ន្ធ NRMIS និងការធ្វើសន្ទានកម្មទិន្នន័យជាមួយប្រព័ន្ធ FMIS ប្រព័ន្ធ SARMIS និងប្រព័ន្ធសំខាន់ៗដទៃទៀត
- បន្តលើកកម្ពស់កិច្ចសហការជាមួយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន និងទិន្នន័យ ដែលចាំបាច់ ឱ្យមានភាពងាយស្រួលជាងមុន
- ពិនិត្យលទ្ធភាពដាក់ចេញនូវគោលការណ៍ណែនាំឱ្យច្បាស់លាស់ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការអនុវត្តប្រព័ន្ធ SARMIS
- បន្តផ្សព្វផ្សាយ និងបណ្តុះបណ្តាលជាបន្តបន្ទាប់នូវការប្រើប្រាស់ និងមុខងារថ្មីៗនៃកំណែប្រែលើប្រព័ន្ធ SARMIS ដើម្បីស្របតាមការអភិវឌ្ឍជាក់ស្តែង និងទំនើបកម្មនៃសង្គមឌីជីថល
- បន្តបំពេញការធ្វើសន្ទានកម្ម NRMIS និង SARMIS ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៃក្រសួង-ស្ថាប័ន ស្របតាមតម្រូវការចាំបាច់
- បន្តជំរុញការប្រើប្រាស់ e-Payment ឱ្យបានពេញលេញ ប្រកបដោយសុខដុមនីយកម្ម និងមានភាពងាយស្រួលក្នុងការទូទាត់ និង
- ពង្រឹងមុខងារពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

# ជំពូកទី៧
# ការគ្រប់គ្រងហានិភ័យ

កិច្ចការកែទម្រង់ និងការពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងចំណូលរបស់រដ្ឋ គឺជាការងារដ៏ស្មុគស្មាញមួយ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ពីគ្រប់តួអង្គពាក់ព័ន្ធ ដោយមើលលើគ្រប់ទិដ្ឋភាព ឬព្រឹត្តិការណ៍ដែលអាចជះឥទ្ធិពលដល់ការប្រមូលចំណូល ការពង្រឹងក្របខ័ណ្ឌអភិបាលកិច្ច និងគ្រប់គ្រងស្ថាប័ន និងបង្កភាពរាំងស្ទះដល់ការអនុវត្ត **យុទ្ធសាស្ត្រគៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា**។ ការគ្រប់គ្រងហានិភ័យ គឺគិតគូរលើការវិភាគមូលដ្ឋាននៃហានិភ័យដែលអាចកើតមានឡើងនាពេលអនាគត ការកំណត់នូវការប៉ាន់ប្រមាណ ផលប៉ះពាល់ផ្សេងៗ ព្រមទាំងការត្រៀមដាក់ចេញនូវយន្តការ និងវិធានការបង្ការនានា ស្របតាមស្ថានភាពចំពោះមុខ និងភាពចាំបាច់ផ្សេងទៀត ដើម្បីទប់ស្កាត់ និងកាត់បន្ថយនូវភាពខ្វះខាតលើគ្រប់ទិដ្ឋភាព និងបង្កើតវិការភាពសេដ្ឋកិច្ច (Economic Distortion)។

❖ **ហានិភ័យម៉ាក្រូសេដ្ឋកិច្ច** សំដៅដល់ព្រឹត្តិការណ៍ ដែលជះឥទ្ធិពលអវិជ្ជមានដោយផ្ទាល់ ឬដោយប្រយោល ដល់កំណើនសកម្មភាពសេដ្ឋកិច្ចជាតិ និងប៉ះពាលដល់ការប្រមូលចំណូលជាយថាហេតុ។ ភាគច្រើន នៃហានិភ័យម៉ាក្រូសេដ្ឋកិច្ច មានប្រភពពីកត្តាខាងក្រៅដែលអាចសាយភាយផលអវិជ្ជមានមកកាន់សេដ្ឋកិច្ចកម្ពុជា ។ ហានិភ័យម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យមសំខាន់ៗ រួមមាន ការបន្តថមថយកំណើនសេដ្ឋកិច្ចសកលនិងចិន ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ភាពតានតឹងនៃកត្តាភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម និងការប្រែប្រួលអាកាសធាតុ គ្រោះធម្មជាតិ និងការរាតត្បាតនៃជំងឺផ្សេងៗ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រនានា ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលបំណងពង្រឹងភាពធន់សង្គម-សេដ្ឋកិច្ច ដែលឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងវិបត្តិនាពេលអនាគត និងឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ដើម្បីជំរុញសម្ទុះនៃការអភិវឌ្ឍជាតិប្រកបដោយចីរភាព និងបរិយាប័ន្ន។

❖ **ហានិភ័យហិរញ្ញវត្ថុសាធារណៈជាក់លាក់** សំដៅដល់ព្រឹត្តិការណ៍ ឬ ផលប៉ះពាល់ ដែលកើតចេញពីផ្នែកណាមួយនៃវិស័យហិរញ្ញវត្ថុសាធារណៈ ដែលនាំឱ្យលម្ហថវិកា (Fiscal Space) មានការថមថយ ឬឱនភាពថវិកា (Budget Deficit) កាន់តែរីកធំ។ ជាមួយនឹងស្ថានភាពមិនប្រាកដប្រជាខ្ពស់នៃសេដ្ឋកិច្ចសកល ការដាក់ចេញនូវវិធានការ និងគោលនយោបាយទ្រទ្រង់ធុរកិច្ចជាបន្តបន្ទាប់ តាមរយៈការកាត់បន្ថយនូវបន្ទុកពន្ធអត្រាពន្ធ-អាករទាំងក្នុងស្រុក និងនាំចូល និងការអនុគ្រោះពន្ធ-អាករផ្សេងៗ ដើម្បីលើកទឹកចិត្តដល់អាជីវកម្ម និងទាក់ទាញការវិនិយោគ អាចបង្កឱ្យការប្រមូលចំណូលមិនសម្រេចបានទៅតាមការគ្រោង និងនាំឱ្យមានការថមថយនូវលទ្ធភាពទ្រទ្រង់ចំណាយសាធារណៈ ទន្ទឹមនឹងការកាត់បន្ថយចំណាយសាធារណៈក្នុងវិស័យផ្លូវការ ដែលអាចនាំឱ្យកាត់បន្ថយមូលដ្ឋានពន្ធផងដែរ។ ដើម្បីកាត់បន្ថយហានិភ័យនេះ រាជរដ្ឋាភិបាល នឹងដាក់ចេញនូវវិធានការគន្លឹះជាក់ស្តែង ទាន់ពេល និងចំគោលដៅ ដោយមានការត្រួតពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំនូវប្រសិទ្ធភាពនៃការផ្តល់ការលើកទឹកចិត្តពន្ធតាមរយៈការគ្រប់គ្រងចំណាយសារពើពន្ធ។

❖ **ហានិភ័យស្ថាប័ន** សំដៅដល់ហានិភ័យពាក់ព័ន្ធនឹងការរៀបចំ និងគ្រប់គ្រងរចនាសម្ព័ន្ធស្ថាប័ន សមត្ថភាព និងមូលធនមនុស្ស ក្នុងការសម្រេចគោលដៅដែលបានកំណត់ផ្សេងៗ។ ហានិភ័យកើតឡើង

រួមមានភាពមានកម្រិតនៃសមត្ថភាពរបស់មន្ត្រីជំនាញ ភាពខ្វះចន្លោះនៃអភិបាលកិច្ចរបស់ស្ថាប័នប្រមូលចំណូល និងការផ្តល់សេវាសាធារណៈ ព្រមទាំងបញ្ហាក្នុងការចែករំលែកទិន្នន័យ និងសង្គតិភាពទិន្នន័យ។ រាជរដ្ឋាភិបាលបានត្រៀមលក្ខណៈរួចជាស្រេច ក្នុងការឆ្លើយតបទៅនឹងហានិភ័យនេះដោយយកចិត្តទុកដាក់លើ៖ ១)-ការអភិវឌ្ឍមូលធនមនុស្ស សំដៅបង្កើនទំនុកចិត្តក្នុងការរៀបចំក្របខ័ណ្ឌច្បាប់/បទដ្ឋានគតិយុត្ត និងបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តការងារប្រមូលចំណូល ២)-ការពង្រឹងតួនាទីអង្គភាពក្រោមឱវាទ ក.ស.ហ.វ. ដើម្បីអាចសម្រួលដល់ការកំណត់អត្តសញ្ញាណតួអង្គសេដ្ឋកិច្ច ៣)-ការបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការកែទម្រង់រដ្ឋបាលប្រមូលចំណូល តាមរយៈការធ្វើឌីជីថលូបនីយកម្ម និងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ៤)-ការបន្តរៀបចំ និងកែលម្អក្របខ័ណ្ឌគតិយុត្តចាំបាច់នានា និង ៥)-ការអនុវត្តគោលនយោបាយលើកទឹកចិត្តដល់មន្ត្រីអនុវត្ត។

❖ **ហានិភ័យផ្នែកវប្បធម៌បង់ពន្ធ** សំដៅដល់បរិយាកាសដែលនាំឱ្យការបង់ពន្ធក្លាយជាជម្រើស មិនមែនជាកាតព្វកិច្ច។ នៅក្នុងស្ថានការណ៍ដែលកម្ពុជា ក៏ដូចជាសកលលោកកំពុងឆ្លងកាត់ភាពមិនប្រាកដប្រជាខ្ពស់ និងស្របពេលដែលកម្ពុជាកំពុងស្ថិតនៅពេលប្រជាជន និងធុរជន ស្ថិតក្នុងដំណាក់កាលស្តារសេដ្ឋកិច្ចឡើងវិញ វប្បធម៌បង់ពន្ធក៏កំពុងទទួលរងនូវការប៉ះទង្គិចជាបន្តបន្ទាប់។ ក្នុងន័យនេះ ការពង្រឹងឡើងវិញនូវវប្បធម៌បង់ពន្ធឱ្យបានល្អប្រសើរអាចនឹងទទួលបានលទ្ធផលដូចការគ្រោងទុកដែលមានកម្មវិបាកដល់ចំណូលពន្ធជាទូទៅ។ ក្នុងការកាត់បន្ថយហានិភ័យនេះ **យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ចាត់ទុកការពង្រឹងវប្បធម៌បង់ពន្ធជាអាទិភាព និងត្រូវលើកកម្ពស់ជាប្រចាំ តាមរយៈការផ្តល់សេវាបង់ពន្ធឱ្យកាន់តែប្រសើរ ការបង្កើនទំនុកចិត្តចំពោះពន្ធតាមរយៈការពង្រឹងប្រសិទ្ធភាពសេវាសាធារណៈ ការបណ្តុះស្មារតីជាតិនិយម តាមរយៈការបង់ពន្ធ និងកម្មវិធីផ្សេងៗ ដើម្បីជាការលើកទឹកចិត្តចំពោះការបង់ពន្ធ និងការចាត់វិធានការម៉ឺងម៉ាត់ចំពោះការគេចបន្លំពន្ធ។

# ជំពូកទី៨
# ការត្រួតពិនិត្យ និងវាយតម្លៃ

ប្រសិទ្ធភាព និងភាពជោគជ័យនៃការអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** ពឹងផ្អែកយ៉ាងខ្លាំងទៅលើការរៀបចំយន្តការត្រួតពិនិត្យ និងវាយតម្លៃ ដែលមានលក្ខណៈជាប្រព័ន្ធ មានភាពច្បាស់លាស់ និងធន្ទៈនយោបាយមោះមុត និងធនធានគ្រប់គ្រាន់ ព្រមទាំងការបែងចែកតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ទៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធនីមួយៗ ដើម្បីតាម-ដានលទ្ធផល តម្រង់ទិស និងជំរុញការអនុវត្តយុទ្ធសាស្ត្រនេះជាប្រចាំ ។

ការត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្រនេះ នឹងប្រើប្រាស់យន្តការដែលមានស្រាប់គឺៈ ១)-គណៈ-កម្មាធិការគោលនយោបាយសារពើពន្ធ ២)-គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ និង ៣)-គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃ ចំណូលមិនមែនសារពើពន្ធ។

គណៈកម្មាធិការគោលនយោបាយសារពើពន្ធមានតួនាទី និងមុខងារត្រួតពិនិត្យ និងតាមដានលើការអនុវត្តវិធានការគោលនយោបាយដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រនេះ ព្រមទាំងសម្របសម្រួលពិនិត្យ និងលើកការស្នើកែសម្រួលគោលនយោបាយសារពើពន្ធ ដោយឈរលើគោលការណ៍សមធម៌ សាមញ្ញភាព តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។ គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ មានតួនាទីតាមដានការអនុវត្តត្រួតពិនិត្យ និងវាយតម្លៃលើសកម្មភាព និងសូចនាករទាំងអស់ពាក់ព័ន្ធនឹង ការប្រមូលចំណូលសារពើពន្ធ ព្រមទាំងជំរុញ និងផ្តល់ការណែនាំលើការអនុវត្តផែនការសកម្មភាពនៃការប្រមូលចំណូលសារពើពន្ធ ឱ្យសម្រេចបានតាមទិសដៅ និងទាន់ពេលដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះ។ គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ មានតួនាទីតាមដានការអនុវត្តត្រួតពិនិត្យ និងវាយតម្លៃ លើសកម្មភាពនិងសូចនាករទាំងអស់ពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ព្រមទាំងជំរុញនិងផ្តល់ការណែនាំដល់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធលើការអនុវត្តផែនការសកម្មភាពនៃការប្រមូលចំណូលមិនមែនសារពើពន្ធ ឱ្យសម្រេចបានតាមទិសដៅ និងទាន់ពេលដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះ។

អគ្គនាយកដ្ឋានគោលនយោបាយ (អ.គ.ប.) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទីជាលេខាធិការដ្ឋាននៃគណៈកម្មាធិការទាំង ៣ ដែលនឹងរៀបចំក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃលម្អិត។ បន្ទាប់ពីទទួលបានការអនុម័តយុទ្ធសាស្ត្រនេះ ផែនការសកម្មភាពនឹងត្រូវរៀបចំ ដោយកំណត់នូវសូចនាករសមិទ្ធកម្មគន្លឹះ និងបន្ទាត់មូលដ្ឋាន លើគ្រប់វិធានការទាំងអស់ដែលបានដាក់ចេញ។ អ.គ.ប. នឹងត្រូវរៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីធ្វើការតាមដានវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ ព្រមទាំងរៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ ដាក់ជូនគណៈកម្មាធិការទាំង ៣។

ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ រាល់ការស្នើសុំការផ្លាស់ប្តូរគោលនយោបាយសារពើពន្ធត្រូវមានការពិភាក្សាកម្រិតបច្ចេកទេសជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ដើម្បីរៀបចំរបាយការណ៍ និងអនុសាសន៍ជូនគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ។

អង្គភាពក្រោមចំណុះ ក.ស.ហ.វ. និងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ មានភារកិច្ចរៀបចំនិងផ្តល់របាយការណ៍វឌ្ឍនភាពមកលេខាធិការដ្ឋាននៃគណៈកម្មាធិការទាំង ៣ រៀងរាល់ឆមាស ឬទៅតាមការស្នើសុំរបស់លេខាធិការដ្ឋាន ដើម្បីរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារជូនគណៈកម្មាធិការទាំង ៣ បានទាន់ពេល ។ របាយការណ៍វឌ្ឍនភាពប្រចាំឆមាស ត្រូវផ្ញើជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការទាំង ៣ យ៉ាងយូរត្រឹមដំណាច់ខែបន្ទាប់ ។

# ជំពូកទី៩
# សេចក្តីសន្និដ្ឋាន

**យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** នឹងបន្តក្លាយជាឧបករណ៍គោលនយោបាយ មួយដំណាក់កាលទៀត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាឱ្យបាននូវចីរភាពកំណើនសេដ្ឋកិច្ច ធានាឱ្យបាននូវយុត្តិធម៌ និងសមធម៌ក្នុងការបង់ពន្ធ និងបន្តធានាឱ្យបាននូវកំណើនចំណូល និងប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូលចរន្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការចំណាយរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្ត **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** និងចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ពោលគឺក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

**យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** មានចក្ខុវិស័យចូលរួមប្រែក្លាយប្រព័ន្ធចំណូលរដ្ឋឱ្យកាន់តែទំនើប មានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយសុតបរមា ដែលអាចឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ និងការវិវឌ្ឍនៃរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចកម្ពុជា។ **គោលបំណងនៃយុទ្ធសាស្ត្រ** គឺពង្រឹងការប្រមូលចំណូលឱ្យកាន់តែប្រសើរ តាមរយៈការបន្តធ្វើទំនើបកម្មរដ្ឋបាល និងគោល-នយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ដោយថ្លឹងថ្លែង បន្តរក្សាឱ្យបាននូវចលនការ និងសម្ទុះនៃសេដ្ឋកិច្ច ផ្តល់នូវភាពត្រឹមត្រូវ តម្លាភាព និងភាពយុត្តិធម៌ដល់អ្នកជាប់ពន្ធ ដោយផ្តោតលើចំណូលដែលជាសក្តានុពល និងមិនបង្កឱ្យមានវិការភាពសេដ្ឋកិច្ច។ **គោលដៅនៃយុទ្ធសាស្ត្រ** គឺ ទី១)-រក្សា និងជំរុញចំណូលចរន្តឱ្យបានក្នុងរង្វង់ ១៦% នៃ ផ.ស.ស នៅពេលកំណើនសេដ្ឋកិច្ចត្រឡប់មកកាន់គន្លងសក្តានុពលវិញ ទី២)-ធានាឱ្យបាននូវភាពច្បាស់លាស់ និងភាពត្រឹមត្រូវនៃប្រព័ន្ធពន្ធ និងភាពអាចព្យាករណ៍បាននៃការផ្លាស់ប្តូរ និងទី៣)-បន្តពង្រីកវិសាលភាព និងពង្រឹងគុណភាពប្រព័ន្ធចំណូលមិនមែនសារពើពន្ធ។

**យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា** នឹងបន្តជាឧបករណ៍គោលនយោបាយនៃការកែទម្រង់សម្រាប់ដោះស្រាយនូវបញ្ហាប្រឈម ដោយផ្តោតលើការងារចម្បងរួមមាន ១)-បន្តធ្វើទំនើបកម្ម និងពង្រឹងអភិបាលកិច្ចនិងស្ថាប័ន តាមរយៈការវិភាគមុខងារ និងកែសម្រួលរចនាសម្ព័ន្ធ ការពង្រឹងចំណេះដឹង និងក្រមប្រតិបត្តិវិជ្ជាជីវៈរបស់មន្ត្រី និងការប្រើប្រាស់បច្ចេកវិទ្យាចាំបាច់ពិសេសបច្ចេកវិទ្យាឌីជីថល ២)-ធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធជំនាន់ ២ បូក (Tax Administration 2 Plus) និងឈានឆ្ពោះទៅរដ្ឋបាលសារពើពន្ធជំនាន់ ៣ (Tax Administration 3.0) ដែលមានលក្ខណៈទំនើប និងផ្តល់សេវាជូនដល់អ្នកជាប់ពន្ធកាន់តែងាយស្រួល ៣)-បន្តធ្វើសមាហរណកម្ម និងសន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឱ្យបានពេញលេញ ធ្វើសាមញ្ញកម្ម និងឌីជីថលូបនីយកម្មនីតិវិធីគយ និងបំពាក់បច្ចេកវិទ្យាគយកាន់តែទំនើបសំដៅសម្រួលដល់រំហូរពាណិជ្ជកម្ម បង្កើនភាពប្រកួតប្រជែង និងពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល ៤)-រៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ទិន្នន័យចាំបាច់ និងធនធានមនុស្សដើម្បីចាប់ផ្តើមអនុវត្តពន្ធចំនួន ២ ប្រភេទ ដែលមានស្រាប់ក្នុងច្បាប់ស្តីពីសារពើពន្ធជាធរមាន រួមមានពន្ធ

លើប្រាក់ចំណូលរូបវន្តបុគ្គល និងពន្ធលើចំណេញមូលធន ៥)-បន្តកែទម្រង់អាករពិសេស ស្របតាមគោលការណ៍ណែនាំស្តីពីការកែទម្រង់អាករពិសេស ២០២៤-២០២៨ ៦)-ពិនិត្យឡើងវិញនូវចំណាយសារពើពន្ធ (Tax Expenditure) ដែលកើនឡើងជាបន្តបន្ទាប់ ៧)-បន្តចូលរួមអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធតាមរយៈការបង្កលក្ខណៈងាយស្រួលដល់ការឈានចូលក្នុងតំបន់នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬប្រព័ន្ធអភិវឌ្ឍអន្តរកាលមួយ មុននឹងធ្វើសមាហរណកម្មពេញលេញចូលប្រព័ន្ធផ្លូវការ និង៨)-បន្តពង្រឹងអភិបាលកិច្ចស្ថាប័ន និងគោលនយោបាយចំណូលមិនមែនសារពើពន្ធ។ យុទ្ធសាស្ត្រកៀរគរចំណូលរបស់ រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា នឹងដាក់ចេញនូវវិធានការគន្លឹះ ចំនួន **១៦២** វិធានការ ដោយបែងចែកជា ៣ ផ្នែកធំៗ រួមមាន ១)-ការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ ចំនួន **៥៤** វិធានការ ដោយក្នុងនោះការធ្វើទំនើបភាវូបនីយកម្ម នៃអ.ព.ដ. ចំនួន ២៣ វិធានការ និងការធ្វើទំនើបភាវូបនីយកម្ម នៃ អ.គ.រ. ចំនួន ៣១ វិធានការ ២)-ការធ្វើទំនើបកម្ម និងវិចារណកម្មគោលនយោបាយពន្ធ ចំនួន **២៥** វិធានការ និង ៣)-ការពង្រឹងរដ្ឋបាល និងគោលនយោបាយចំណូលមិនមែនសារពើពន្ធ ចំនួន **៨៣** វិធានការ។

ស្ថិតក្នុងបរិការណ៍បច្ចុប្បន្ន ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ជាកិច្ចការងារចាំបាច់បំផុត ប៉ុន្តែមានភាពលំបាក និងស្មុគស្មាញច្រើន ដោយសារវិបត្តិសកលបានកើតឡើងផ្ទួនៗគ្នា ដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សកម្មភាពសេដ្ឋកិច្ចកម្ពុជា និងម្យ៉ាងទៀត រាជរដ្ឋាភិបាលត្រូវបន្តអនុវត្តការងារកែទម្រង់រដ្ឋបាលសារពើពន្ធ និងវិចារណកម្មគោលនយោបាយពន្ធជាបន្តបន្ទាប់ទៀត ក្នុងគ្រាដែលរាជរដ្ឋាភិបាលបានធ្វើការកែទម្រង់នេះបានច្រើនរួចមកហើយ ក្នុងដំណាក់កាលទី ១ និងទី២។ ដូចនេះ ការដាក់ចេញវិធានការគោលនយោបាយក្នុងយុទ្ធសាស្ត្រនេះ ត្រូវបានធ្វើឡើងប្រកបដោយភាពប្រយ័ត្នប្រយែងខ្ពស់។ ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះបានជោគជ័យ ទាមទារឱ្យមានឆន្ទៈ និងការប្តេជ្ញាខ្ពស់ ដោយមានការចូលរួមយ៉ាងសស្រាក់សស្រាំ ពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងវិស័យឯកជនផងដែរ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។ បន្ថែមពីនេះ ការដាក់ចេញនូវយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា គឺជាការត្រៀមខ្លួនសម្រាប់ដំណាក់កាលបន្តបន្ទាប់ទៀត ដែលកម្ពុជាត្រូវបន្តធ្វើការកែទម្រង់ប្រព័ន្ធពន្ធឱ្យមានភាពធន់គ្រប់គ្រាន់ទៅនឹងបម្រែបម្រួលនៃបរិការណ៍សកល និងសម្របខ្លួនបានកាន់តែប្រសើរទៅនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ច៕

## បរិសិដ្ឋ៖

### ឧបសម្ព័ន្ធ ១. វិធានការនៃការធ្វើទំនើបភាវូបនីយកម្ម នៃអគ្គនាយកដ្ឋានពន្ធដារ

| ល.រ. | វិធានការ | ស្ថាប័នអនុវត្ត [5] | រយៈពេល |
|---|---|---|---|
| I. | ក្របខ័ណ្ឌអភិបាលកិច្ច និងស្ថាប័ន | | |
| ១ | បន្តពង្រឹងសមត្ថភាពមន្ត្រីពន្ធក្នុងការគ្រប់គ្រង និងវិភាគពីហានិភ័យតាមប្រភេទពន្ធ និងវិស័យសេដ្ឋកិច្ចសំខាន់ៗ ដើម្បីដាក់ចេញនូវវិធានការបង្ការរាល់ភាពអសកម្មនានាពេលបំពេញប្រតិបត្តិការប្រមូលពន្ធ ដើម្បីធានានូវតម្លាភាព និងយុត្តិធម៌ជូនអ្នកបង់ពន្ធ | អ.ព.ដ. | ២០២៤-២០២៨ |
| ២ | អភិវឌ្ឍថ្នាល E-learning ដើម្បីអាចឱ្យមន្ត្រីអាចបង្កើនជំនាញតាមប្រព័ន្ធឌីជីថលសម្រាប់ពង្រឹងជំនាញ និងសមត្ថភាពរបស់មន្ត្រី | អ.ព.ដ. | ២០២៤-២០២៥ |
| ៣ | បណ្តុះបណ្តាលសមត្ថភាព និងជំនាញរបស់មន្ត្រី និងការវាយតម្លៃសូចនាករសមិទ្ធកម្មគន្លឹះ ផ្អែកលើតួនាទី និងការទទួលខុសត្រូវ ដើម្បីធានាថាសមត្ថភាពរបស់មន្ត្រីត្រូវបានពង្រឹង និងអាចផ្គូរផ្គងជំនាញបុគ្គលិក ( Match staff skills ) ទៅនឹងតម្រូវការអ្នកជាប់ពន្ធ | អ.ព.ដ. | ២០២៤-២០២៨ |

[5] សម្គាល់៖ ស្ថាប័នអនុវត្តរួមមាន អ.ព.ដ.: អគ្គនាយកដ្ឋានពន្ធដារ, អ.គ.រ.: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អ.ទ.ច.: អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, អ.ស.ឌ.: អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល, អ.ស.ក: អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, អ.ហ.ថ: អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អ.ថ.: អគ្គនាយកដ្ឋានថវិកា, គ.ស.ហ.: គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក.ស.ហ.វ: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក.ប.ស្ថ: ក្រសួងបរិស្ថាន, ក.យ.: ក្រសួងយុត្តិធម៌, ក.ម.ផ.:ក្រសួងមហាផ្ទៃ, ច.ម.ព.: ចំណូលមិនមែនសារពើពន្ធ

| | | | |
|---|---|---|---|
| ៤ | ពង្រឹងការអនុវត្តនិយាមប្រតិបត្តិ (SOP) របស់អង្គភាពក្រោមឱវាទ អពដ ដោយមានការចូលរួមត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាព ពីអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្នុងការធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាពពេញលេញ | អ.ព.ដ., អ.ស.ក. | ២០២៥-២០២៨ |
| ៥ | ពង្រឹងអភិបាលកិច្ច និងស្ថាប័ន តាមរយៈការវិភាគមុខងារ និងកែសម្រួលរចនាសម្ព័ន្ធ | អ.ព.ដ. | ២០២៥-២០២៨ |
| II. | **មុខងារស្នូល** | | |
| ១ | បន្តលើកកម្ពស់សេវាអ្នកជាប់ពន្ធ ជាពិសេសឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល ដោយបន្តធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសមាហរណកម្មប្រព័ន្ធមុខងារស្នូល កាន់តែប្រទាក់ក្រឡាជាងមុន រួមមាន ការចុះបញ្ជីពន្ធដារ (E-registration) ការដាក់លិខិតប្រកាសពន្ធ (E-filing) និងការបង់ប្រាក់ពន្ធ (E-payment) | អ.ព.ដ. | ២០២៤-២០២៨ |
| ២ | បង្កើនប្រសិទ្ធភាពសវនកម្មពន្ធ និងកាត់បន្ថយការធ្វើសវនកម្មត្រួតគ្នា និងច្រើនលើកច្រើនសារ តាមរយៈការអនុវត្តសៀវភៅណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ (SOP on Auditing) ដើម្បីធានាអនុលោមភាពពន្ធដារ និងគុណភាពសេវាអ្នកជាប់ពន្ធ ។ល។ | អ.ព.ដ. | ២០២៤-២០២៥ |
| ៣ | បង្កើនប្រសិទ្ធភាពនៃការដោះស្រាយបណ្តឹងតវ៉ាប្រកបដោយទំនុកចិត្តរវាងមន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីការដោះស្រាយបណ្តឹងតវ៉ា | អ.ព.ដ. | ២០២៤-២០២៨ |
| ៤ | បង្កើនប្រសិទ្ធភាព និងយន្តការនៃការស៊ើបអង្កេតបទល្មើសពន្ធដារ តាមរយៈការអនុវត្តសៀវភៅណែនាំ ស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌពីពន្ធដារ និងបែបបទនិងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌស្តីពីពន្ធដារ (SOP on Investigation) ដើម្បីធានាឱ្យមាននូវតម្លាភាព និងធានានូវការប្រកួតប្រជែងស្មើភាពគ្នា និងបង្កើតឱ្យមានភាពជឿទុកចិត្តពីសាធារណជន | អ.ព.ដ. | ២០២៤-២០២៨ |

| | | | |
|---|---|---|---|
| ៥ | បន្តពង្រឹងការគ្រប់គ្រងបំណុលពន្ធ សំដៅកាត់បន្ថយជាអតិបរមានូវបំណុលបច្ចុប្បន្ន និងចៀសវាងការកើនឡើងបំណុលពន្ធអនាគត | អ.ព.ដ. | ២០២៤-២០២៨ |
| ៦ | ជំរុញ និងលើកទឹកចិត្ត អ្នកជាប់ពន្ធឱ្យមកចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ជាពិសេសសហគ្រាសធុនតូច និងមធ្យម | អ.ព.ដ. | ២០២៤-២០២៨ |
| ៧ | ធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់សហគ្រាសស្ថិតក្រោមរបបស្វ័យប្រកាស តាមរយៈការវិភាគ និងចាត់ថ្នាក់នូវទំហំផលរបរ និងទ្រព្យសកម្ម ប្រកបដោយតម្លាភាព និងយុត្តិធម៌ | អ.ព.ដ. | ២០២៤-២០២៨ |
| ៨ | ពង្រឹងយន្តការនៃការអនុវត្តប្រព័ន្ធបង្វិលសងអាករលើតម្លៃបន្ថែម ដើម្បីលើកកម្ពស់ និងធានានូវប្រសិទ្ធភាព ក្នុងការស្នើសុំជាតុចូលអាករលើតម្លៃបន្ថែមលើការកាត់បន្ថយរយៈពេល និងចៀសវាងការយោងឥណទានអាករលើតម្លៃបន្ថែមលើសលប់ក្នុងរយៈពេលយូរ | អ.ព.ដ. | ២០២៤-២០២៨ |
| ៩ | ពង្រឹងគុណភាពឯកសារវិភាគហានិភ័យទូទៅរបស់រដ្ឋបាលសារពើពន្ធ ដោយត្រូវកំណត់នូវវិធីសាស្ត្រ ឱ្យសមស្របទៅនឹងឧត្តមានុវត្តន៍អន្តរជាតិ ដែលជួយដល់ការលើកកម្ពស់ប្រសិទ្ធភាពមុខងារស្នូល ព្រមទាំងដំណើរការដោយស្វ័យប្រវត្តិក្នុងការគ្រប់គ្រង និងប្រមូលពន្ធឱ្យមានប្រសិទ្ធភាព តម្លាភាព ចំគោលដៅ និងទាន់ពេល | អ.ព.ដ. | ២០២៤-២០២៨ |
| ១០ | សិក្សារៀបចំអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ដើម្បីត្រៀមអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល | អ.ព.ដ. | ២០២៤-២០២៨ |
| ១១ | អនុវត្តសាកល្បងនូវប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក (E-invoicing system) ដោយ ១). សិក្សាស្វែងយល់ពីភាពជាដៃគូជាមួយវិស័យឯកជន ដើម្បីអនុវត្តប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក ដែលសម្រួលដល់ការរាយការណ៍ និងសុពលភាពប្រតិបត្តិការទាន់ពេល ២). រៀបចំលិខិតបទដ្ឋានគតិយុត្ត និង | អ.ស.ឌ និង អ.ព.ដ. | ២០២៤-២០២៨ |

| | | | |
|---|---|---|---|
| | ឯកសារណែនាំគ្រប់ជ្រុងជ្រោយ ដើម្បីដាក់ឱ្យដំណើរការសាកល្បងនូវវិក្កយបត្រអេឡិចត្រូនិក (E-invoicing) និង | | |
| ១២ | សិក្សាអំពីលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តប្រព័ន្ធ Self-service ជាមគ្គុទេសក៍សម្រាប់អ្នកជាប់ពន្ធ ដើម្បីអាចផ្តល់លទ្ធភាពដល់អ្នកជាប់ពន្ធ ដែលបានចុះបញ្ជីក្នុងប្រព័ន្ធពន្ធដារ អាចដឹងពី ប្រភេទពន្ធ-អាករដែលខ្លួនត្រូវបង់ តាមដានទិន្នន័យបំណុលពន្ធ ដឹងពីស្ថានភាព នៃការចុះធ្វើសវនកម្ម និងទិន្នន័យផ្សេងៗទៀត ដើម្បីចូលរួមក្នុងការបង្កើនចំណេះដឹងលើកាតព្វកិច្ចពន្ធ និងអាចទទួលដំណឹងពាក់ព័ន្ធផ្សេងៗពី អ.ព.ដ. | អ.ព.ដ. | ២០២៤-២០២៨ |
| **III.** | **មុខងារគាំទ្រ** | | |
| ១ | សហការជាមួយបណ្តាគ្រឹះស្ថានសិក្សា ដោយអនុវត្តកម្មវិធីបណ្តុះបណ្តាល ស្តីពីវប្បធម៌ពន្ធដារ ក្នុងកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា និងបង្កើនមាតិកាវីដេអូណែនាំទៅកាន់អ្នកជាប់ពន្ធ តាមរយៈបណ្តាញសង្គមនានា ឬ គេហទំព័ររបស់ អ.ព.ដ. ដោយណែនាំអំពីនីតិវិធី ផ្សេងៗ រួមមានដូចជា វិធីសាស្ត្រនៃការបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធអនឡាញ និងការស្នើសុំវិញ្ញាបនបត្រអ្នកជាប់ពន្ធ ជាដើម | អ.ព.ដ. | ២០២៤-២០២៦ |
| ២ | ពង្រឹងសង្គតិភាព នៃអត្តសញ្ញាណកម្មអ្នកជាប់ពន្ធរវាង អ.ព.ដ. និង អ.គ.រ. និងស្វ័យប្រវត្តិកម្មក្នុងការផ្ទៀងផ្ទាត់ និងផ្ទៀងផ្ទាត់ទិន្នន័យ រវាងអគ្គនាយកដ្ឋានទាំងពីរ ក្នុងកម្មវត្ថុពង្រឹងអនុលោមភាពពន្ធលើពាណិជ្ជកម្មឆ្លងកាត់ច្រកព្រំដែន ដើម្បីចៀសវាងការគេចវេះ និងក្លែងបន្លំពន្ធ និង | អ.ព.ដ. | ២០២៥-២០២៨ |
| ៣ | បន្តរៀបចំជាទៀងទាត់នូវការសិក្សាលើកម្រិតនៃការពេញចិត្តអ្នកជាប់ពន្ធ (Satisfaction survey) លើសេវាអ្នកជាប់ពន្ធ ដើម្បីកែលម្អសេវាកម្មអ្នកជាប់ពន្ធ | អ.ព.ដ. | ២០២៤-២០២៨ |
| ៤ | សិក្សាសមិទ្ធិលទ្ធភាពក្នុងការកសាង និងអភិវឌ្ឍអត្តសញ្ញាណឌីជីថលរបស់អ្នកជាប់ពន្ធ ដែលមានការចូលរួម និងអាចចែករំលែកក្នុងចំណោមអន្តរស្ថាប័ននៃរាជរដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធនានា | មជ្ឈមណ្ឌលធុរកិច្ចថ្មី "តេជោ" និង អ.ព.ដ. | ២០២៥-២០២៦ |

| | | | |
|---|---|---|---|
| | សំដៅកាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធក្នុងការរាយការណ៍ និងបំពេញបែបបទនីតិវិធីរដ្ឋបាលនានា ព្រមទាំងអាចកាត់បន្ថយបន្ទុកការងារដល់រដ្ឋបាលសារពើពន្ធក្នុងការផ្ទៀងផ្ទាត់ព័ត៌មានអ្នកជាប់ពន្ធ | | |
| ៥ | សិក្សាសមិទ្ធិលទ្ធភាពរៀបចំក្របខ័ណ្ឌថ្នាលព័ត៌មានឌីជីថល (Framework for digital platforms) សម្រាប់ប្រមូល និងផ្ទៀងផ្ទាត់ព័ត៌មានពាក់ព័ន្ធនឹងប្រាក់ចំណូលរូបវន្តបុគ្គល និងក្រុមហ៊ុន ការផ្តល់សេវាស្នាក់នៅ ការធ្វើដំណើរ និងសេវាផ្សេងទៀត និងប្រតិបត្តិការពាណិជ្ជកម្មឆ្លងដែន (Cross-border exchange of tax information) ដោយមានកិច្ចសហការរវាងរដ្ឋាភិបាល និងរដ្ឋាភិបាលនៃប្រទេសដៃគូ តាមរយៈថ្នាលឌីជីថលរួម (Single portal digital platform) ដែលអាចរាយការណ៍ផ្ទាល់ទៅរដ្ឋបាលពន្ធ និងផ្ទៀងផ្ទាត់ដោយស្វ័យប្រវត្តិលើកាតព្វកិច្ចបង់ពន្ធ និងការស្នើសុំការលើកលែងពន្ធ | អគ្គលេខាធិការដ្ឋានគណៈកម្មការធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និង អ.ព.ដ. | ២០២៥-២០២៦ |
| ៦ | រៀបចំនូវក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីគ្រប់គ្រងការចែករំលែក និងប្រើប្រាស់ព័ត៌មាន និងទិន្នន័យពាក់ព័ន្ធរវាងរដ្ឋបាលសារពើពន្ធ និងអន្តរក្រសួង-ស្ថាប័ន ដើម្បីគាំទ្រដល់ការធ្វើសង្គតិភាពអត្តសញ្ញាណនៃអ្នកជាប់ពន្ធ ការអភិវឌ្ឍអត្តសញ្ញាណឌីជីថល និងការរៀបចំក្របខ័ណ្ឌថ្នាលព័ត៌មានឌីជីថលសម្រាប់ប្រមូល និងផ្ទៀងផ្ទាត់ព័ត៌មានពាក់ព័ន្ធរបស់អ្នកជាប់ពន្ធ ដោយត្រូវធានានូវសុវត្ថិភាពទិន្នន័យ ការពារ និងប្រយុទ្ធប្រឆាំងនឹងការជ្រៀតចូលក្នុងប្រព័ន្ធពីសំណាក់ជនខាងក្រៅ ដោយគ្មានការអនុញ្ញាត ការបំពានទិន្នន័យក្នុងប្រព័ន្ធ និងការ ប្រើប្រាស់ទិន្នន័យអ្នកជាប់ពន្ធដោយខុសច្បាប់ | អ.ស.ឧ. និង អ.ព.ដ. | ២០២៤-២០២៨ |

## ឧបសម្ព័ន្ធ ២. វិធានការនៃការធ្វើទំនើបភាវូបនីយកម្ម នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

| ល.រ. | វិធានការ | ស្ថាប័នអនុវត្ត | រយៈពេល |
|---|---|---|---|
| I. | កិច្ចសម្រួលពាណិជ្ជកម្ម | | |
| ១ | បន្តជំរុញការអនុវត្តវិធានការកែទម្រង់គន្លឹះ និងមុតស្រួចផ្នែកកិច្ចសម្រួលពាណិជ្ជកម្ម ក្រោមដែនសមត្ថកិច្ចគយ ដែលបានដាក់ចេញ ក្នុងវេទិការាជរដ្ឋាភិបាលផ្នែកឯកជនលើកទី ១៩ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ | អ.គ.រ. | ២០២៤-២០២៥ |
| ២ | បន្តជំរុញក្រសួង-ស្ថាប័នពាក់ព័ន្ធ ចូលរួមអនុវត្តប្រព័ន្ធបញ្ចរតែមួយជាតិ ឱ្យបានពេញលេញ និងជំរុញបញ្ចប់មុខងារពាក់ព័ន្ធដែលនៅសេសសល់ រួមទាំងពង្រឹងការតាមដាន និងវាយតម្លៃការអនុវត្តគម្រោង | អ.គ.រ. | ២០២៤-២០២៦ |
| ៣ | ជំរុញការអនុវត្តយន្តការផ្តល់ការលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាសធុនតូច និងមធ្យម | អ.គ.រ. | ២០២៤-២០២៨ |
| ៤ | ផ្តល់សេវាធ្វើការបន្ថែមម៉ោងរបស់មន្ត្រីគយនៅពេលយប់នៅតាមផែស្ងួតដោយរៀបចំកំណត់ប្រាក់ម៉ោងឱ្យបានសមរម្យ ដើម្បីពន្លឿនការនាំចេញ | អ.គ.រ. | ២០២៤-២០២៨ |
| ៥ | សិក្សាលទ្ធភាពក្នុងការអភិវឌ្ឍមុខងារជំនួសឱ្យហត្ថលេខាឌីជីថលសម្រាប់នីតិវិធីគយ ដើម្បីផ្តល់បន្ថែមនូវសុវត្ថិភាព និងភាពងាយស្រួល ក្នុងការផ្ទៀងផ្ទាត់ប្រតិបត្តិការ | អ.គ.រ. | ២០២៥-២០២៦ |

| | | | |
|---|---|---|---|
| ៦ | ជំរុញការអនុវត្តពេញលេញនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-Arrival Processing) តាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីបង្កើនប្រសិទ្ធភាពនៃការងារគ្រប់គ្រងហានិភ័យគយ កាត់បន្ថយពេលឆ្លងកាត់ព្រំដែន និងចំណាយប្រតិបត្តិការផ្សេងៗ | អ.គ.រ. | ២០២៤-២០២៧ |
| ៧ | ជំរុញបង្កើនចំនួន និងសម្រួលនីតិវិធីដល់ការស្នើសុំវិញ្ញាបនបត្រសមាជិកក្រុមធុរជនល្អបំផុត (Best Traders) និងប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (AEO) ក៏ដូចជាកាត់បន្ថយតម្រូវការឯកសាររឹងក្នុងការស្នើសុំ | អ.គ.រ. | ២០២៥-២០២៦ |
| ៨ | ជំរុញឱ្យមានការប្រើប្រាស់មុខងារទូទាត់ប្រាក់តាមមធ្យោបាយអេឡិចត្រូនិក (e-payment) ឱ្យបានជាអតិបរមា និងបន្តពង្រីកវិសាលភាពនៃគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ដើម្បីអនុវត្តមុខងារនៃប្រព័ន្ធនេះ | អ.គ.រ. | ២០២៥-២០២៧ |
| ៩ | ពិនិត្យលទ្ធភាពក្នុងការកែសម្រួលតម្លៃឯកតា និងរយៈពេលនៃការផ្ដត់ផ្គង់សេវាគយ (services fee) ឱ្យស្របតាមការវិវឌ្ឍនៃសេដ្ឋកិច្ច-សង្គមកម្ពុជា និងឧត្តមានុវត្តន៍អន្តរជាតិ និងក្នុងតំបន់ | អ.គ.រ. | ២០២៥-២០២៧ |
| ១០ | ធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីបង្វិលសងវិញនូវប្រាក់ពន្ធ-អាករគយតាមប្រព័ន្ធអេឡិចត្រូនិក (e-refund) ឱ្យមានស្វ័យប្រវត្តិកម្ម និងឌីជីថលូបនីយកម្ម | អ.គ.រ. | ២០២៥-២០២៨ |
| ១១ | បន្តចូលរួមជំរុញការអនុវត្តគោលការណ៍អធិការកិច្ចតែមួយ និងទីលានត្រួតពិនិត្យគយរួមគ្នា ជាមួយភាគីប្រទេសវៀតណាម និងថៃ នៅច្រកព្រំដែនអន្តរជាតិបាវិត និងប៉ោយប៉ែត | អ.គ.រ. | ២០២៥-២០២៧ |
| ១២ | ធ្វើវិសិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យគយ តាមរយៈការបំពាក់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) និងបច្ចេកវិទ្យាទំនើបផ្សេងទៀត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យអនុលោមភាពគយ និងពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល | អ.គ.រ. | ២០២៥-២០២៨ |

| | | | |
|---|---|---|---|
| ១៣ | ធ្វើវិសិដ្ឋកម្មប្រព័ន្ធអាស៊ីគូដា និងជំរុញការប្រើប្រាស់ប្រព័ន្ធនេះឱ្យទៅជាប្រព័ន្ធស្នូល តាមរយៈការធ្វើសន្ទានកម្មជាមួយប្រព័ន្ធអេឡិចត្រូនិកពាក់ព័ន្ធ | អ.គ.រ. | ២០២៥-២០២៨ |
| ១៤ | សិក្សា និងរៀបចំយន្តការគ្រប់គ្រងថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (e-commerce platform) ដើម្បីប្រមូលពន្ធ-អាករគយ លើទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន ឱ្យកាន់តែមានប្រសិទ្ធភាព | អ.គ.រ. | ២០២៦-២០២៧ |
| II. | **ការពង្រឹងអភិបាលកិច្ច និងស្ថាប័ន** | | |
| ១ | កំណត់សូចនាករគន្លឹះជាក់លាក់ សម្រាប់តាមដាន និងវាយតម្លៃប្រសិទ្ធភាព នៃសកម្មភាពអនុវត្តច្បាប់ និងការអនុវត្តការងាររបស់មន្ត្រីគយ ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃរដ្ឋបាលគយ | អ.គ.រ. | ២០២៥-២០២៧ |
| ២ | កំណត់ និងអនុវត្តវិធានការរដ្ឋបាលលើមន្ត្រីគយដែលបំពានក្រមប្រតិបត្តិវិជ្ជាជីវៈ ច្បាប់ និងបទប្បញ្ញត្តិការងារផ្ទៃក្នុងពាក់ព័ន្ធ | អ.គ.រ. | ២០២៥-២០២៦ |
| ៣ | បន្តជំរុញការកែលម្អប្រព័ន្ធតាមដាន និងវាយតម្លៃប្រសិទ្ធភាពការងាររបស់មន្ត្រីគយ | អ.គ.រ. | ២០២៥-២០២៨ |
| ៤ | ពង្រឹងអភិបាលកិច្ច និងស្ថាប័ន តាមរយៈការវិភាគមុខងារ និងកែសម្រួលរចនាសម្ព័ន្ធ | អ.គ.រ. | ២០២៥-២០២៨ |
| III. | **មុខងារគាំទ្រ** | | |
| ១ | បន្តជំរុញការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ឱ្យស្របតាមផែនការ ព្រមទាំងបង្កើនចំនួនមន្ត្រីនិងអង្គភាពសវនកម្មគយ ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែង | អ.គ.រ. | ២០២៤-២០២៦ |

| | | | |
|---|---|---|---|
| ២ | ពង្រឹងប្រសិទ្ធភាពអនុលោមភាពលើមុខទំនិញជាសក្តានុពលនៃការប្រមូលចំណូល ដូចជាគ្រឿងអេឡិចត្រូនិក និងទំនិញយុទ្ធសាស្ត្រផ្សេងទៀត | អ.គ.រ. | ២០២៥-២០២៦ |
| ៣ | បន្តតាមដាន និងវាយតម្លៃការងារបង្ការ និងបង្ក្រាបបទល្មើសគយ និងពង្រឹងបន្ថែមសមត្ថភាពជំនាញរបស់មន្ត្រី ដើម្បីឆ្លើយតបឱ្យបានជាអតិបរមាទៅនឹងបទល្មើសគយដែលកើតឡើងក្នុងរូបភាពថ្មីៗ និងកាន់តែស្មុគស្មាញ | អ.គ.រ. | ២០២៥-២០២៨ |
| ៤ | សម្រួលយន្តការក្នុងការចែករំលែកព័ត៌មានជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រទេសជាដៃគូពាណិជ្ជកម្មឱ្យមានភាពងាយស្រួល និងឆាប់រហ័ស ក៏ដូចជាពង្រឹងការឆ្លើយតបទៅនឹងតម្រូវការព័ត៌មានដែលបានស្នើសុំ ឱ្យមានប្រសិទ្ធភាព | អ.គ.រ. | ២០២៥-២០២៦ |
| ៥ | រៀបចំយន្តការតាមដាន និងវាយតម្លៃការអនុវត្តវិធានការជំរុញការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ អ.គ.រ. និងផែនការអភិវឌ្ឍន៍ស្ថាប័ន | អ.គ.រ. | ២០២៥-២០២៦ |
| ៦ | បន្តជំរុញការបណ្តុះបណ្តាលអំពីនីតិវិធី ការបំពេញបែបបទគយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគយ  និងការផ្តល់អាជ្ញាបណ្ណជើងសាគយ | អ.គ.រ. | ២០២៤-២០២៨ |
| ៧ | បង្កើតយន្តការ (hotline) ឆ្លើយតបបញ្ហាពាក់ព័ន្ធការងារគយ និងភាពមិនប្រក្រតីផ្សេងៗ | អ.គ.រ. | ២០២៥-២០២៦ |
| ៨ | ពង្រឹងសង្គតិភាព នៃលេខអត្តសញ្ញាណកម្មសារពើពន្ធ (VAT TIN) រវាង  អ.គ.រ. និង អ.ព.ដ. ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការចែករំលែកព័ត៌មាន និងយន្តការតាមដានទំនិញនាំចូល និងទំនិញលក់ចេញក្នុងស្រុក | អ.គ.រ. | ២០២៥-២០២៨ |

| | | | |
|---|---|---|---|
| ៩ | បន្តពង្រឹងសមត្ថភាព និងបង្កើនចំនួនមន្ត្រីជំនាញបច្ចេកទេសផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែង និងការវិវឌ្ឍនៃបច្ចេកវិទ្យាថ្មី | អ.គ.រ. | ២០២៤-២០២៨ |
| ១០ | កសាងយន្តការនិរន្តភាព និងចីរភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដូចជាពង្រឹងសុវត្ថិភាពមជ្ឈមណ្ឌលផ្ទុកទិន្នន័យរួម និងរៀបចំផែនការសង្គ្រោះប្រព័ន្ធក្នុងករណីមានគ្រោះអាសន្ន | អ.គ.រ. | ២០២៦-២០២៨ |
| ១១ | បន្តជំរុញធ្វើសន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ អ.គ.រ. (ASYCUDA e-Customs Pre-Arrival Processing ។ល។) ឱ្យកាន់តែទូលាយ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ | អ.គ.រ. | ២០២៤-២០២៨ |
| ១២ | ធ្វើសាមញ្ញកម្មនីតិវិធី ក្នុងការដាក់បណ្តឹងតវ៉ារបស់ធុរជន និងពង្រឹងយន្តការក្នុងការឆ្លើយតបឱ្យមានភាពគ្រប់ជ្រុងជ្រោយ និងអព្យាក្រឹត | អ.គ.រ. | ២០២៥-២០២៨ |
| ១៣ | ជំរុញបង្កើតមន្ទីរពិសោធន៍គយ សម្រាប់ត្រួតពិនិត្យគុណភាពទំនិញ ដើម្បីពន្លឿនដល់ការធ្វើបែបបទទំនិញពីគយ និងចូលរួមចំណែកដល់ការការពារសុខភាពអ្នកប្រើប្រាស់ និងពង្រឹងការងារបង្ការនិងបង្ក្រាបមុខទំនិញហាមឃាត់ដែលប៉ះពាល់សុខភាព | អ.គ.រ. | ២០២៥-២០២៧ |

## ឧបសម្ព័ន្ធ ៣. វិធានការនៃការធ្វើទំនើបកម្ម និងវិចារណកម្មគោលនយោបាយពន្ធ

| ល.រ. | វិធានការ | ស្ថាប័នអនុវត្ត | រយៈពេល |
|---|---|---|---|
| **ក. ពន្ធលើប្រាក់ចំណូល** | | | |
| ១ | សិក្សាពីបច្ច័យនៃការអនុវត្ត Inclusive Framework on Base Erosion Profit Shifting Project លើការប្រមូលចំណូលពន្ធលើប្រាក់ចំណូល និងការអនុវត្តរបបលើកទឹកចិត្តពន្ធក្រោមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា | អ.ព.ជ. និង អ.គ.ប. | ២០២៤-២០២៥ |
| ២ | ពិនិត្យ និងពង្រឹងយន្តការអនុវត្តវិធានបង្វែរថ្លៃ (Transfer Pricing Rules) ជាពិសេសចំពោះសហគ្រាសបុត្រសម្ព័ន្ធ និងអ្នកជាប់ពន្ធនិវាសនជនដែលកំពុងទទួលបានការលើកទឹកចិត្តពន្ធ | អ.ព.ជ. | ២០២៥-២០២៦ |
| ៣ | ពិនិត្យមើលឡើងវិញនូវអត្រាពន្ធលើប្រាក់ចំណូល និងរបបលើកទឹកចិត្តពន្ធ ក្នុងបរិបទនៃការអនុវត្តអត្រាពន្ធអប្បបរមាជាសកល នៃពន្ធលើប្រាក់ចំណូល ដើម្បីធានាឧត្តមភាពនៃការប្រកួតប្រជែងក្នុងការទាក់ទាញការវិនិយោគពីបរទេសមកកម្ពុជានិងរក្សាឱ្យបាននូវចំណូលពន្ធលើប្រាក់ចំណូល | អ.ព.ជ. | ២០២៥-២០២៧ |
| **ខ. ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល** | | | |
| ១ | ជំរុញការអនុវត្តវិធានការទាំងអស់នៃក្របខ័ណ្ឌគោលនយោបាយនេះស្របតាមផែនការសកម្មភាពសម្រាប់អនុវត្តក្របខ័ណ្ឌគោលនយោបាយសម្រាប់ត្រៀមអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល | គ.ស.ហ | ២០២៤-២០២៨ |
| **គ. អាករពិសេស** | | | |

| | | | |
|---|---|---|---|
| ១ | ជំរុញការអនុវត្តវិធានការ ស្របតាមផែនការសកម្មភាពសម្រាប់អនុវត្តគោលការណ៍ណែនាំស្តីពីការកែទម្រង់អាករពិសេស | អ.គ.ប., អ.គ.រ., និង អ.ព.ដ. | ២០២៤-២០២៨ |
| **ឃ. អាករលើតម្លៃបន្ថែម** | | | |
| ១ | ពិនិត្យលទ្ធភាពក្នុងការកែសម្រួលការអនុវត្តអត្រាសូន្យសម្រាប់ការទិញនូវវត្ថុធាតុដើម ដែលផលិតក្នុងស្រុក ដើម្បីសម្រួលបន្ទុករដ្ឋបាលក្នុងការបង្វិលសងអាករលើតម្លៃបន្ថែមទៅកាន់សហគ្រាសផ្គត់ផ្គង់ក្នុងស្រុក តាមរយៈការបង្កើនប្រសិទ្ធភាពនៃយន្តការបង្វិលសងអាករលើតម្លៃបន្ថែម | អ.ព.ដ. | ២០២៥-២០២៦ |
| ២ | សិក្សា និងរៀបចំយន្តការដែលកំណត់ជាកាតព្វកិច្ច ចំពោះការប្រមូលអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញ និងសេវាលើថ្នាលឌីជីថល ដោយអ្នកផ្គត់ផ្គង់និវាសនជន និងអ្នកផ្គត់ផ្គង់អនិវាសនជន ដោយធានាភាពមិនត្រួតគ្នានៃការប្រមូលពន្ធ | អ.ព.ដ. និង អ.គ.ប. | ២០២៦-២០២៨ |
| ៣ | ពិនិត្យឡើងវិញនូវការលើកលែងអាករលើតម្លៃបន្ថែម ក្នុងវិស័យម្ហូបអាហារមួយចំនួន | អ.គ.ប. | ២០២៥-២០២៦ |
| **ង. ពន្ធពាក់ព័ន្ធនឹងអចលនទ្រព្យ** | | | |
| ១ | សិក្សា និងពិនិត្យលទ្ធភាពក្នុងការរៀបចំប្រព័ន្ធទិន្នន័យប្រមូលផ្តុំ ដែលអាចធ្វើសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងអចលនទ្រព្យផ្សេងទៀតសម្រាប់ការអនុវត្តពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬកាន់កាប់អចលនទ្រព្យ | អ.ព.ដ. | ២០២៤-២០២៥ |
| ២ | រៀបចំយន្តការទទួលមតិយោបល់ពីអ្នកជាប់ពន្ធ និងសាធារណជនពាក់ព័ន្ធនឹងការអនុវត្តពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធប្រថាប់ត្រា ដើម្បីធានាឱ្យបាននូវការអនុវត្តប្រកបដោយសុក្រឹតភាព សមធម៌ និងយុត្តិធម៌ | អ.ព.ដ. | ២០២៤-២០២៥ |

| | | | |
|---|---|---|---|
| ៣ | ពិនិត្យលទ្ធភាពក្នុងការពង្រីកវិសាលភាពនៃការប្រមូលពន្ធលើអចលនទ្រព្យនៅតាមទីប្រជុំជននៃខេត្តដែលមានសក្តានុពល | អ.ព.ដ. | ២០២៦-២០២៨ |
| ៤ | បន្តធ្វើបច្ចុប្បន្នភាពថ្លៃអចលនទ្រព្យសម្រាប់ជាមូលដ្ឋានគិតពន្ធប្រថាប់ត្រារៀងរាល់ ៥ ឆ្នាំម្តង | អ.ព.ដ. | ២០២៦-២០២៨ |
| **ច. ការគ្រប់គ្រងចំណាយសារពើពន្ធ** | | | |
| ១ | រៀបចំយន្តការគ្រប់គ្រង និងចែករំលែកទិន្នន័យចំណាយសារពើពន្ធរួមមួយ សម្រាប់ជាមូលដ្ឋានក្នុងការវិភាគចំណាយសារពើពន្ធ | អ.គ.ប, អ.ព.ដ., និង អ.គ.វ. | ២០២៥-២០២៦ |
| ២ | សិក្សា និងវិភាគចំណាយសារពើពន្ធ ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្តរបបលើកទឹកចិត្តពន្ធ | អ.គ.ប, អ.ព.ដ., និង អ.គ.វ. | ២០២៥-២០២៦ |
| ៣ | ធ្វើការវាយតម្លៃប្រសិទ្ធភាព និងគុណប្រយោជន៍ លើគោលការណ៍លើកទឹកចិត្តដល់ឧស្សាហកម្មផ្គុំ និងដំឡើងយានយន្ត ដើម្បីរៀបចំយុទ្ធសាស្ត្រជំរុញការវិនិយោគ ក្នុងវិស័យផ្គុំ និងដំឡើងយានយន្ត និងឧស្សាហកម្មគាំទ្រ | អ.គ.ប, អ.ព.ដ., និង អ.គ.វ. | ២០២៥-២០២៦ |
| ៤ | ធ្វើការវាយតម្លៃប្រសិទ្ធភាព និងគុណប្រយោជន៍ លើការអនុវត្តរបបលើកទឹកចិត្តពន្ធនៅក្នុងច្បាប់ស្តីពីវិនិយោគ និងការលើកទឹកចិត្តពន្ធផ្សេងៗតាមការចាំបាច់ ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តរបបលើកទឹកចិត្តពន្ធ | អ.គ.ប, អ.ព.ដ., និង អ.គ.វ. | ២០២៦-២០២៨ |
| ៥ | ធ្វើការវាយតម្លៃប្រសិទ្ធភាព និងគុណប្រយោជន៍ លើការលើកលែងអាករលើតម្លៃបន្ថែម និងការដាក់អាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ដោយថ្លឹងថ្លែងរវាងប្រសិទ្ធភាពសេដ្ឋកិច្ច ចំណូល និងសមធម៌នៃការបង់ពន្ធ | អ.គ.ប, អ.ព.ដ., និង អ.គ.វ. | ២០២៦-២០២៨ |

| | | | |
|---|---|---|---|
| ៦ | សិក្សាលទ្ធភាពក្នុងការផ្លាស់ប្តូរ ពីការផ្តល់ការលើកទឹកចិត្តលើប្រាក់ចំណូល (Profit-based incentives) ទៅជាការលើកទឹកចិត្តលើការចំណាយ (cost-based incentives) ក្នុងការទាក់ទាញវិនិយោគ និងធានាប្រសិទ្ធភាពនៃរបបលើកទឹកចិត្តពន្ធ | អ.គ.ប, អ.ព.ដ., និង អ.គ.វ. | ២០២៦-២០២៨ |
| **ឆ. ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម** | | | |
| ១ | ពិនិត្យ និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តអនុក្រឹត្យលេខ ៥០, ៥១, និង ១២៤ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ និងផ្នែកគយសម្រាប់សហគ្រាសធុនតូច និងមធ្យម និងកែសម្រួលការអនុវត្តយន្តការលើកទឹកចិត្តពន្ធ សម្រាប់ការលើកកម្ពស់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ដើម្បីបំពេញតម្រូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យស្របតាមគោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងករណីចាំបាច់ | អ.គ.ប, អ.ព.ដ., និង អ.គ.វ. | ២០២៤-២០២៥ |
| ២ | សិក្សា និងកំណត់ឡើងវិញនូវនិយមន័យ និងវិស័យអាទិភាពនៃសហគ្រាសធុនតូច និងមធ្យមឱ្យស្របទៅតាមឧត្តមានុវត្តន៍អន្តរជាតិ | អ.គ.ប, អ.ព.ដ., និង អ.គ.វ. | ២០២៥-២០២៧ |
| ៣ | ផ្សព្វផ្សាយ និងជំរុញការផ្តល់ការលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម ដើម្បីលើកកម្ពស់ផលិតកម្មក្នុងស្រុក និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម | អ.ព.ដ. និង អ.គ.វ. | ២០២៤-២០២៥ |
| ៤ | បន្តផ្សព្វផ្សាយ និងជំរុញការផ្តល់ការលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម ដើម្បីលើកកម្ពស់ផលិតកម្មក្នុងស្រុក និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម | អ.ព.ដ. និង អ.គ.វ. | ២០២៦-២០២៨ |
| **ជ. ពន្ធក្នុងវិស័យល្បែងពាណិជ្ជកម្ម** | | | |
| ១ | ពង្រឹងយន្តការអនុវត្តពន្ធលើប្រាក់ចំណូល និងពន្ធ-អាករផ្សេងទៀត លើអាជីវកម្មល្បែងពាណិជ្ជកម្មទាំងសកម្មភាពល្បែងពាណិជ្ជកម្ម និងសកម្មភាពដទៃទៀតដែលជ្រកក្រោមអាជីវកម្មល្បែងពាណិជ្ជកម្ម | អ.ព.ដ. | ២០២៥-២០២៧ |

| | | | |
|---|---|---|---|
| **ឈ. ពន្ធលើសេវាកម្មឌីជីថល** | | | |
| ១ | សិក្សាសមិទ្ធិលទ្ធភាពក្នុងការអនុវត្តពន្ធសេវាកម្មឌីជីថល ការកំណត់អត្រាពន្ធ ការវិភាគចំណេញខាត (Costs and benefits) និងនីតិវិធីរដ្ឋបាលនៃការអនុវត្តពន្ធនេះ | អ.គ.ប. | ២០២៥-២០២៧ |
| **ញ. ពន្ធលើការបំភាយកាបូន (Carbon Tax)** | | | |
| ១ | សិក្សាសមិទ្ធិលទ្ធភាពក្នុងការអនុវត្តពន្ធលើការបំភាយកាបូន ដើម្បីវាយតម្លៃភាពរួចរាល់ (Readiness Assessment) នៃការអនុវត្តពន្ធលើការបំភាយកាបូន ដែលរួមមាន ការវិភាគបន្ទុកពន្ធ ការវិភាគមូលដ្ឋានគិតពន្ធ និងអត្រាពន្ធ ក្របខ័ណ្ឌពេលដែលត្រូវអនុវត្ត ព្រមទាំងសមត្ថភាពស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលសារពើពន្ធ | អ.គ.ប. | ២០២៥-២០២៧ |

## ឧបសម្ព័ន្ធ ៤. វិធានការនៃការពង្រឹងរដ្ឋបាល និងគោលនយោបាយចំណូលមិនមែនសារពើពន្ធ

| ល.រ. | វិធានការ | ស្ថាប័នអនុវត្ត | ពេលវេលា |
|---|---|---|---|
| I. | ការពង្រឹងអភិបាលកិច្ច និងស្ថាប័ននៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | | |
| ១ | ជំរុញឱ្យក្រសួង-ស្ថាប័ន និង អង្គភាពពាក់ព័ន្ធ រៀបចំកិច្ចប្រជុំប្រចាំត្រីមាស/ឆ្នាំ ដើម្បីធ្វើការពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការដែលបានដាក់ចេញ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ច.ម.ព. | ២០២៤-២០២៦ |
| ២ | ពង្រឹងយន្តការផ្តល់ព័ត៌មាន ទិន្នន័យ និងរបាយការណ៍វឌ្ឍនភាពឱ្យបានទាន់ពេល | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ច.ម.ព. | ២០២៤-២០២៦ |
| ៣ | ពង្រឹងការគ្រប់គ្រង និងពិនិត្យឡើងវិញ លើការអនុវត្តច្បាប់ពាក់ព័ន្ធនានា ទៅតាមមុខងារមន្ត្រីអនុវត្តផ្ទាល់ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ច.ម.ព. | ២០២៤-២០២៦ |
| ៤ | ពង្រឹងការទទួលខុសត្រូវរបស់មន្ត្រីទទួលបន្ទុកឱ្យបានខ្ជាប់ខ្ជួន តាមរយៈការចងក្រងនូវច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តនានា | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ច.ម.ព. | ២០២៤-២០២៧ |
| ៥ | អនុវត្តការវិភាគមុខងារតាមក្រសួង-ស្ថាប័ន ដោយផ្តោតលើការកែទម្រង់និងការពង្រឹងរចនាសម្ព័ន្ធពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការប្រមូលចំណូលមិនមែនសារពើពន្ធ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ច.ម.ព. | ២០២៤-២០២៦ |
| ៦ | បែងចែក និងរៀបចំការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ច.ម.ព. | ២០២៤-២០២៧ |

| | | | |
|---|---|---|---|
| ៧ | បន្តការពង្រឹងស្ថាប័ន ដោយពង្រឹងការអនុវត្តមុខងារនិងរចនាសម្ព័ន្ធដែលបានកែទម្រង់ ព្រមទាំងពង្រឹងយន្តការស្ថាប័ននិងធនធានមនុស្ស | ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ច.ម.ព. | ២០២៥-២០២៧ |
| ៨ | ពង្រឹងចំណេះដឹងមន្ត្រីនិងក្រុមប្រតិបត្តិវិជ្ជាជីវៈ ដោយរួមបញ្ចូលជាមួយនឹងការជំរុញការប្រើប្រាស់បច្ចេកវិទ្យា | ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ច.ម.ព. | ២០២៥-២០២៧ |
| ៩ | ពង្រឹងកាតព្វកិច្ចទទួលខុសត្រូវរបស់អង្គភាពទទួលបន្ទុក តាមរយៈការរៀបចំផែនការគ្រប់គ្រង ឬថ្លឹងថ្លែងរវាងចំណាយនិងចំណូលឱ្យមានប្រសិទ្ធភាព លើការងារពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ | ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ច.ម.ព. | ២០២៤-២០២៧ |
| ១០ | ពង្រឹងការគ្រោង និងព្យាករណ៍ចំណូល នៅតាមក្រសួង-ស្ថាប័ន និងគិតតាមមុខចំណូលនីមួយៗ | ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ច.ម.ព. | ២០២៥-២០២៧ |
| ១១ | ពង្រឹងបន្ថែមនូវប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ពិសេសលើការងារផ្តល់សេវាសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ | ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ច.ម.ព. & អ.ទ.ប. | ២០២៥-២០២៨ |
| ១២ | សិក្សាវាយតម្លៃអំពីចំណូលមិនមែនសារពើពន្ធ ដើម្បីតម្រង់ទិសគោលនយោបាយចំណូលមិនមែនសារពើពន្ធ | ក្រុមការងារ ក.ស.ហ.វ (អ.គ.ប. & អ.ទ.ប.) | ២០២៦-២០២៨ |
| II. | **ការពង្រឹងមុខងារស្នូលក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ** | | |
| **ក. ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ** | | | |

| | | | |
|---|---|---|---|
| ១ | បង្កើត និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ ដើម្បីពង្រឹងគណនេយ្យភាព តាមរយៈការរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយនូវលិខិតបទដ្ឋានគតិយុត្តនានា ក្នុងវិស័យសំខាន់ៗ | អ.ទ.ប. | ២០២៤-២០២៦ |
| ២ | ពង្រឹងការយកចិត្តទុកដាក់ក្នុងការប្រមូលធាតុចូល និងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមរបស់វិស័យឯកជន តាមរយៈវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន | ក.ស.ហ.វ(អ.ទ.ប. & អ.ហ.ថ) & ក.ម.ផ | ២០២៤-២០២៦ |
| ៣ | ពង្រឹងការទទួលខុសត្រូវ និងកំណត់មុខងារច្បាស់លាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនាមជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ & អ.ហ.ថ | ២០២៤-២០២៧ |
| ៤ | រៀបចំឱ្យបាននូវការកត់ត្រាលម្អិតតាមមុខសញ្ញាចំណូលតូចៗ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ប.ម.ព. & អ.ទ.ប. | ២០២៤-២០២៦ |
| ៥ | ពង្រឹងប្រសិទ្ធភាពយន្តការអន្តរស្ថាប័នប្រទាក់ក្រឡាគ្នារវាងក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយ ក.សហវ ក្នុងការគ្រប់គ្រង និងការកៀរគរចំណូល | អ.ទ.ប.<br>ក្រសួង-ស្ថាប័ន | ២០២៤-២០២៦ |
| ៦ | គ្រប់គ្រង និងប្រមូលចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋឱ្យបានពេញលេញ និងប្រកបដោយគណនេយ្យភាព ដោយផ្អែកលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | អ.ទ.ប. | ២០២៤-២០២៦ |
| ៧ | ដោះស្រាយ និងជម្រះករណីមិនប្រក្រតីពីការប្រមូលចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ដោយជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានាឱ្យបានម៉ឺងម៉ាត់ | អ.ទ.ប. | ២០២៤-២០២៦ |
| ៨ | ជំរុញការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ និងចុះបញ្ជីដីរដ្ឋឱ្យបានពេញលេញ ទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | អ.ទ.ប. | ២០២៤-២០២៦ |

| | | | |
|---|---|---|---|
| ៩ | ជំរុញការរៀបចំផែនការនៃការតឹងទារបំណុលមិនមែនសារពើពន្ធ ផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន | អ.ទ.ច. | ២០២៤-២០២៦ |
| ១០ | ធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល | អ.ទ.ច. | ២០២៥-២០២៦ |
| ១១ | បន្តរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ សម្រាប់អនុវត្តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ | អ.ទ.ច. | ២០២៤-២០២៧ |
| ១២ | ពង្រឹងការគ្រប់គ្រង ដោយពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងពង្រឹងយន្តការត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីធានាបាននូវការអភិរក្ស ការអភិវឌ្ឍន៍ ការគ្រប់គ្រង និងការប្រើប្រាស់ ប្រកបដោយនិរន្តរភាព និងស្ថេរភាពនៃធនធានធម្មជាតិ | អ.ទ.ច. | ២០២៤-២០២៧ |
| ១៣ | បន្តរៀបចំឱ្យបាននូវការកត់ត្រាលម្អិតតាមមុខសញ្ញាចំណូលតូចៗ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | អ.ទ.ច. | ២០២៦-២០២៨ |
| ១៤ | បន្តធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល | អ.ទ.ច. | ២០២៦-២០២៧ |
| ១៥ | ពន្លឿនក្រសួង ស្ថាប័នក្នុងការបំពេញឱ្យបានប្រតិបត្តិការជាប្រក្រតីតាមការប្រើប្រាស់ប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មាន លើរាល់ប្រតិបត្តិការទាក់ទងនឹងការប្រមូលចំណូលពីទ្រព្យសម្បត្តិរដ្ឋ | អ.ទ.ច. & ក្រសួង-ស្ថាប័ន | ២០២៥-២០២៧ |
| ១៦ | ពិនិត្យ និងជំរុញក្រុមហ៊ុនដែលទទួលបានសិទ្ធិពីរដ្ឋ សម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មធនធានរ៉ែ ឧស្ម័ន និងប្រេងកាត ជាដើម ឱ្យបន្ត | អ.ទ.ច. & ក្រសួង-ស្ថាប័ន | ២០២៤-២០២៧ |

| | | | |
|---|---|---|---|
| | ដំណើរការ អនុវត្តតាមកិច្ចសន្យា ឬចាត់វិធានការសមស្របណាមួយចំពោះករណីមិនមានអនុលោមភាព | | |
| ១៧ | បន្តសិក្សាលទ្ធភាពកែសម្រួលកម្រៃសេវា និងអត្រាសួយសារពាក់ព័ន្ធនឹងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងការកែសម្រួលកិច្ចសន្យាដីសម្បទានឱ្យស្របតាមទិដ្ឋភាពសេដ្ឋកិច្ច និងតម្លៃសេដ្ឋកិច្ច | អ.ទ.ច. & អ.គ.ប. | ២០២៥-២០២៧ |
| ១៨ | ជំរុញយន្តការតាមដាន និងវាយតម្លៃ លើការអនុវត្តរបស់ក្រុមហ៊ុនឯកជនដែលទទួលបានសិទ្ធិពីរដ្ឋក្នុងការសិក្សាស្វែងរក និងធ្វើអាជីវកម្មធនធានរ៉ែឧស្ម័ន និងប្រេងកាត ឱ្យស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន | អ.ទ.ច. | ២០២៥-២០២៨ |
| ១៩ | ជំរុញការបង្កើតបរិយាកាសទាក់ទាញធុរកិច្ច និងការវិនិយោគ ដល់វិស័យឯកជន ក្នុងការធ្វើអាជីវកម្មលើទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានអនុញ្ញាត ដើម្បីបង្កើនចំណូលបន្ថែម | អ.ទ.ច. | ២០២៦-២០២៨ |
| **ខ. ចំណូលពីសហគ្រាសសាធារណៈ** | | | |
| ១ | ពង្រឹងឱ្យបានពេញលេញ លើការគ្រប់គ្រង និងការកត់ត្រាចំណូលពី សហគ្រាសសាធារណៈ ភាគហ៊ុនរបស់រដ្ឋ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដែលត្រូវបង់ភាគលាភ ឬអតិរេកសាច់ប្រាក់ ភាគលើសនៃទុនទំនេរ និងការបង់សាច់ប្រាក់ ឬសមមូលជាសាច់ប្រាក់ជាចំណែករបស់រដ្ឋ | ក.ស.ហ.វ., ក្រសួងអាណាព្យាបាលបច្ចេកទេស និងសហគ្រាសសាធារណៈនីមួយៗ | ២០២៤-២០២៧ |
| ២ | ពន្លឿនការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង សហគ្រាសសាធារណៈ និងភាគហ៊ុនរបស់រដ្ឋ ដោយឆ្លុះបញ្ចាំងគ្រប់ជ្រុងជ្រោយលើទិដ្ឋភាពចំណូល និងពង្រឹងការអនុវត្តច្បាប់ | ក.ស.ហ.វ. | ២០២៤-២០២៦ |

| | | | |
|---|---|---|---|
| ៣ | បន្តជំរុញការបង់ និងការកត់ត្រាចំណូលពី សហគ្រាសសាធារណៈ ជាពិសេស សហគ្រាសសាធារណៈ ដែលទទួលបានការលើកលែងការបង់ភាគលាភ | ក.ស.ហ.វ., ក្រសួងអាណាព្យាបាលបច្ចេកទេស និងសហគ្រាសសាធារណៈនីមួយៗ | ២០២៤-២០២៨ |
| ៤ | ពិនិត្យលទ្ធភាពបង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃ សហគ្រាសសាធារណៈ និងភាគហ៊ុនរបស់រដ្ឋ និង សាកល្បងសិក្សាវាយតម្លៃអំពីប្រសិទ្ធភាព ភាពចាំបាច់នៃគោលនយោបាយ និងកម្មវិបាកនៃសហគ្រាសសាធារណៈ | កសហវ, ក្រសួងអាណាព្យាបាលបច្ចេកទេស និងសហគ្រាសសាធារណៈនីមួយៗ | ២០២៥-២០២៨ |
| ៥ | ត្រូវសិក្សា ពិនិត្យ និងធ្វើការកែសម្រួលបទប្បញ្ញត្តិ/លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសហគ្រាសសាធារណៈ ដោយដាក់ចេញឱ្យស្របតាមខ្លឹមសារនៃច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ | ក.ស.ហ.វ. | ២០២៤-២០២៨ |
| ៦ | ពង្រឹងការគ្រប់គ្រង និងប្រមូលចំណូល ស្របតាមច្បាប់ថ្មី | ក.ស.ហ.វ., ក្រសួងអាណាព្យាបាលបច្ចេកទេស និងសហគ្រាសសាធារណៈនីមួយៗ | ២០២៤-២០២៨ |
| **គ. ចំណូលពីសេវាសាធារណៈ** | | | |

| | | | |
|---|---|---|---|
| ១ | ដាក់ចេញលិខិតបទដ្ឋានគតិយុត្តក្នុងការរៀបចំឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ចំពោះការប្រមូលចំណូលពីសេវាសាធារណៈ | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៥-២០២៧ |
| ២ | បន្តពិនិត្យ និងកែសម្រួល ថ្លៃសេវាសាធារណៈនានា ដែលប៉ះពាល់ឬអាចជះឥទ្ធិពលដល់ទេសចរណ៍ អាជីវកម្ម និងការទាក់ទាញវិនិយោគ និងឱ្យស្របតាមស្ថានភាពសេដ្ឋកិច្ចនិងសង្គម | ក្រសួង-ស្ថាប័ន | ២០២៥-២០២៨ |
| ៣ | បន្តពង្រឹងគុណភាពសេវា និងជំរុញដំណើរការទូទាត់តាមរយៈប្រព័ន្ធបច្ចេកវិទ្យាឱ្យបានពេញលេញ | ក្រសួង-ស្ថាប័ន | ២០២៥-២០២៨ |
| ៤ | ពង្រឹង និងកសាងសមត្ថភាពតាមរយៈ ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ទាំងនៅកម្រិតថ្នាក់ដឹកនាំ និងកម្រិតបច្ចេកទេស | ក្រសួង-ស្ថាប័ន | ២០២៥-២០២៨ |
| ៥ | ពិនិត្យអាជ្ញាបណ្ណឡើងវិញចំពោះ មុខសញ្ញាអាជ្ញាបណ្ណដែលមានគោលបំណងដូចគ្នា និងការបែងចែកសមត្ថកិច្ច | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៥-២០២៨ |
| ៦ | បែងចែកសមត្ថកិច្ចគ្រប់គ្រង និងប្រមូលចំណូលពីសេវាសាធារណៈរបស់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ការផ្ទេរមុខងារពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ) | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៥-២០២៨ |
| ៧ | សិក្សា និងពិនិត្យលទ្ធភាពរៀបចំប្រព័ន្ធបច្ចេកវិទ្យា សម្រាប់ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធអនឡាញ | ក្រសួង-ស្ថាប័ន | ២០២៤-២០២៨ |
| ៨ | រៀបចំគោលការណ៍ ពិនិត្យឡើងវិញនូវកម្រងសេវាសាធារណៈ និងថ្លៃសេវា | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៦-២០២៧ |

| | | | |
|---|---|---|---|
| ៩ | រៀបចំក្រុមការងារ ដើម្បីសិក្សា និងរៀបចំវិធីសាស្ត្រ សម្រាប់កំណត់ថ្លៃសេវា ឱ្យស្ថិតក្នុងបទដ្ឋានរួម | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៦-២០២៨ |
| ១០ | ពង្រឹងការផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យា (សេវាអនឡាញ) ជាពិសេសការផ្តល់សេវាចំពោះធុរកិច្ច | ក្រសួង-ស្ថាប័ន | ២០២៤-២០២៨ |
| **ឃ. ចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្ម** | | | |
| ១ | ជំរុញការអនុម័តច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក និងរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ ឬចាត់ចែងទ្រព្យសម្បត្តិរឹបអូសពីបទល្មើសនានា និងបង់ចំណូលចូលថវិការដ្ឋ ស្របតាមនីតិវិធីជាធរមាន | ក.ឃ. | ២០២៤-២០២៦ |
| ២ | បន្តសិក្សា និងកំណត់ភាពមិនប្រក្រតីនៃការបង់ប្រាក់របស់ពិរុទ្ធជនឱ្យបានច្បាស់លាស់ | ក្រសួង-ស្ថាប័ន | ២០២៥-២០២៧ |
| ៣ | ជំរុញសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ក្នុងការចេញសេចក្តីសម្រេចស្ថាពរ ដែលពាក់ព័ន្ធនឹងបទល្មើសមានវត្ថុតាងរឹបអូសជាទ្រព្យសម្បត្តិរដ្ឋមានតម្លៃសេដ្ឋកិច្ចខ្ពស់ ឬងាយបាត់បង់តម្លៃសេដ្ឋកិច្ច | ក.ឃ. | ២០២៥-២០២៧ |
| ៤ | ពង្រឹងយន្តការច្បាស់លាស់ សម្រាប់ត្រួតពិនិត្យ តាមដាន និងជំរុញការបង់ប្រាក់ពិន័យតាមសេចក្តីសម្រេចជាស្ថាពរ របស់សាលាជម្រះក្តី | ក.ឃ. | ២០២៦-២០២៨ |
| ៥ | ពិនិត្យកែសម្រួលឡើងវិញ នូវលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការបែងចែកប្រាក់រង្វាន់ ពីចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្ម | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៦-២០២៨ |
| ៦ | ពង្រឹងក្របខណ្ឌការងាររបស់សាលាជម្រះក្តី ក្នុងការចាត់ចែងទ្រព្យសម្បត្តិផ្សេងៗ ឱ្យក្លាយជាចំណូលចូលរដ្ឋ | ក.ឃ. | ២០២៤-២០២៨ |

| | | | |
|---|---|---|---|
| ៧ | សិក្សាវាយតម្លៃ ពីប្រសិទ្ធភាពនៃវិធានការពិន័យ និងការដាក់ទណ្ឌកម្មពាក់ព័ន្ធនឹងការប្រមូលចំណូល និងទប់ស្កាត់ការកើនឡើងនៃបទល្មើស | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៤-២០២៨ |
| ៨ | សិក្សា និងពិនិត្យធ្វើបច្ចុប្បន្នភាពលើអត្រាប្រាក់ពិន័យ និងទណ្ឌកម្ម | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៥-២០២៧ |
| **ង. ចំណូលមិនមែនសារពើពន្ធដទៃទៀត** | | | |
| ១ | រៀបចំលិខិតបទដ្ឋានគតិយុត្តឱ្យបានលម្អិតក្នុងការកំណត់និងចាត់ថែងប្រភេទចំណូលមិនមែនសារពើពន្ធដទៃទៀតដូចខាងលើ | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៥-២០២៦ |
| ២ | ពិនិត្យលទ្ធភាពប្រមូលចំណូលពីវិស័យសក្តានុពលថ្មីៗ ឬពុំទាន់មានយន្តការប្រមូលច្បាស់លាស់ | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៥-២០២៦ |
| ៣ | ពង្រីកការអនុវត្តយន្តការផលទានកាបូន និងពង្រឹងការប្រមូលចំណូល | ក.ស.ហ.វ.និង ក.ប.ស្ថ, | ២០២៥-២០២៧ |
| ៤ | បន្ថែមការរៀបចំយន្តការឱ្យបានច្បាស់លាស់ក្នុងការគ្រប់គ្រង ដូចជា ចំណូលពីប្រទានកម្ម ទ្រព្យគ្មានម្ចាស់គ្រប់គ្រង អច្ច័យទាន និងចំណូលពីទ្រព្យនិទាឃាទ ជាដើម | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៥-២០២៦ |
| ៥ | សិក្សាស្រាវជ្រាវស្វែងរកប្រភពចំណូលថ្មីឱ្យអស់លទ្ធភាព សមស្របតាមស្ថានភាពសេដ្ឋកិច្ច | អ.ទ.ច. & អ.គ.ប. | ២០២៤-២០២៨ |
| ៦ | បន្តសិក្សាអំពីប្រភពចំណូលមិនមែនសារពើពន្ធផ្សេងៗ នៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ | ក.ស.ហ.វ.និង ក្រសួង-ស្ថាប័ន | ២០២៥-២០២៨ |

| | | | |
|---|---|---|---|
| ៧ | បន្តពង្រឹងការយន្តការប្រមូលចំណូលពីឥណទានកាបូនឱ្យមានប្រសិទ្ធភាព ស្របតាមតម្លៃសេដ្ឋកិច្ច | អ.ទ.ច. & ក.ប.ស្ថ | ២០២៥-២០២៨ |
| ៨ | រៀបចំយន្តការទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល តាមរយៈគណៈកម្មការអន្តរក្រសួង | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ប.ម.ព. & អ.ទ.ច. | ២០២៥-២០២៨ |
| III. | **ពង្រឹងមុខងារគាំទ្រការគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ** | | |
| ១ | បន្តជំរុញឱ្យមានការប្រើប្រាស់ NRMIS និង SARMIS ពេញលេញក្នុងក្រសួង-ស្ថាប័នគ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | អ.ទ.ច. & អ.ថ. | ២០២៤-២០២៦ |
| ២ | បន្តកែសម្រួល និងធ្វើបច្ចុប្បន្នភាព NRMIS និង SARMIS ដោយបន្ថែមមុខងារឱ្យគ្រប់តាមតម្រូវការប្រើប្រាស់ទាំងសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងធ្វើទំនើបកម្ម ដើម្បីដាក់ចេញឱ្យបាននូវប្រព័ន្ធដំណើរការគ្រប់ជ្រុងជ្រោយ ប្រកបដោយលក្ខណៈឌីជីថល និងស្វ័យប្រវត្តិកម្ម | អ.ទ.ច. | ២០២៤-២០២៧ |
| ៣ | ជំរុញការធ្វើសន្ធានកម្ម NRMIS និង SARMIS ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុង ក.ស.ហ.វ. ជាពិសេស FMIS និងប្រព័ន្ធនៃក្រសួង-ស្ថាប័នផ្សេងទៀត | អ.ទ.ច. & ក្រសួង-ស្ថាប័នពាក់ព័ន្ធ ប.ម.ព. | ២០២៤-២០២៧ |
| ៤ | បន្ថែមការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបំពេញការអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព | អ.ទ.ច. | ២០២៤-២០២៦ |
| ៥ | បំពេញឱ្យបាននូវការធ្វើសន្ធានកម្ម និងកាត់បន្ថយបញ្ហាប្រឈមពាក់ព័ន្ធនឹងផ្នែករឹង ផ្នែកទន់ ទិន្នន័យ មនុស្ស និងដំណើរការ | អ.ទ.ច. | ២០២៤-២០២៦ |

| | | | |
|---|---|---|---|
| ៦ | ពង្រឹងយន្តការចែករំលែកព័ត៌មាន ទិន្នន័យ និងឯកសារពាក់ព័ន្ធពីក្រសួង-ស្ថាប័ន | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ថ.ម.ព. | ២០២៤-២០២៦ |
| ៧ | ពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់គាំទ្រ និងអនុវត្តប្រព័ន្ធ NRMIS និង ប្រព័ន្ធ SARMIS | អ.ទ.ច. | ២០២៤-២០២៦ |
| ៨ | សម្រេចឱ្យបាននូវភាពត្រឹមត្រូវនៃការកំណត់លេខកូដចំណូលមិនមែនសារពើពន្ធ និងចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកា | អ.ទ.ច. | ២០២៤-២០២៦ |
| ៩ | ផ្ដោតការយកចិត្តទុកដាក់លើការជ្រើសរើសមន្ត្រីបច្ចេកទេស និងផ្ដល់ការបណ្ដុះបណ្ដាលនៅកន្លែងបំពេញការងារ និង/ឬ ផ្ដល់ជំនួយបច្ចេកទេស និងការសម្របសម្រួលដោយផ្ទាល់ ឬតាមប្រព័ន្ធអនឡាញ | អ.ទ.ច. | ២០២៤-២០២៧ |
| ១០ | ផ្សព្វផ្សាយ បណ្ដុះបណ្ដាល និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) V2 ឱ្យពេញលេញ | អ.ទ.ច. | ២០២៤-២០២៦ |
| ១១ | ពង្រឹងសមត្ថភាពស្ថាប័នក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ជាពិសេសការអនុវត្តឱ្យបានពេញលេញនូវប្រព័ន្ធ (SARMIS) V2 | អ.ទ.ច. | ២០២៤-២០២៦ |
| ១២ | ជំរុញការអនុវត្តការបង់ចំណូលតាមប្រព័ន្ធ e-payment ឱ្យបានពេញលេញ | អ.ទ.ច. & ក្រសួង-ស្ថាប័នពាក់ព័ន្ធ ថ.ម.ព. | ២០២៤-២០២៦ |
| ១៣ | សិក្សា និងរៀបចំបង្កើតយន្តការឌីជីថលក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យ សម្រាប់គោលដៅនៃការប្រមូលចំណូលមិនមែនសារពើពន្ធ | អ.ទ.ច. និង អ.ស.ឧ. | ២០២៤-២០២៥ |

| | | | |
|---|---|---|---|
| ១៤ | ជំរុញការបញ្ចូលរាល់ប្រតិបត្តិការចំណូលមិនមែនសារពើពន្ធ នៅថ្នាក់រដ្ឋបាលកណ្ដាលក្រសួង-ស្ថាប័ន និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រព័ន្ធ NRMIS និងការធ្វើសន្ទានកម្មទិន្នន័យជាមួយប្រព័ន្ធ FMIS ប្រព័ន្ធ SARMIS និងប្រព័ន្ធសំខាន់ៗដទៃទៀត | អ.ទ.ច. & អ.ថ. | ២០២៤-២០២៧ |
| ១៥ | បន្តលើកកម្ពស់កិច្ចសហការជាមួយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន និងទិន្នន័យ ដែលចាំបាច់ ឱ្យមានភាពងាយស្រួលជាងមុន | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ច.ម.ព. | ២០២៤-២០២៧ |
| ១៦ | ពិនិត្យលទ្ធភាពដាក់ចេញនូវគោលការណ៍ណែនាំឱ្យច្បាស់លាស់ ស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការអនុវត្តប្រព័ន្ធ SARMIS | អ.ទ.ច. | ២០២៥-២០២៧ |
| ១៧ | បន្តផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលជាបន្តបន្ទាប់នូវការប្រើប្រាស់ និងមុខងារថ្មីៗនៃកំណែប្រែលើប្រព័ន្ធ SARMIS ដើម្បីស្របតាមការអភិវឌ្ឍន៍ជាក់ស្ដែង និងទំនើបកម្មនៃសង្គមឌីជីថល | អ.ទ.ច. | ២០២៥-២០២៨ |
| ១៨ | បន្តបំពេញការធ្វើសន្ទានកម្ម NRMIS និង SARMIS ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៃក្រសួង-ស្ថាប័ន ស្របតាមតម្រូវការចាំបាច់ | អ.ទ.ច. | ២០២៥-២០២៨ |
| ១៩ | បន្តជំរុញការប្រើប្រាស់ e-Payment ឱ្យបានពេញលេញ ប្រកបដោយសុខដុមនីយកម្ម និងមានភាព-ងាយស្រួលក្នុងការទូទាត់ | អ.ទ.ច. | ២០២៦-២០២៨ |
| ២០ | ពង្រឹងមុខងារពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល | អ.ទ.ច. & អ.ស.ឧ. | ២០២៦-២០២៨ |

## ឧបសម្ព័ន្ធ ៥. វិធានការគោលនយោបាយ និងសកម្មភាពគាំទ្រដែលបាន និងកំពុងអនុវត្តក្នុងឆ្នាំ ២០២៤

| ល.រ. | វិធានការ |
|---|---|
| I. | អគ្គនាយកដ្ឋានពន្ធដារ |
| ១ | អនុវត្តវិធានការកែទម្រង់មុតស្រួចដាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ |
| ២ | បន្តអនុវត្តរហូតដល់ដំណាច់ឆ្នាំ២០២៥ នូវការលើកទឹកចិត្តចំពោះអ្នកអភិវឌ្ឍអចលនទ្រព្យ និងប្រជាពលរដ្ឋជាម្ចាស់អចលនទ្រព្យ រួមមាន ការលើកលែងពន្ធលើចំណេញមូលធនលើអចលនទ្រព្យ អនុញ្ញាតការបង់ពន្ធជាកញ្ចប់តាមគម្រោងដល់ក្រុមហ៊ុនអភិវឌ្ឍសំណង់ លើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លំនៅដ្ឋានគ្រប់ប្រភេទ ដែលមានលក្ខណៈជាបុរី ដែលមានតម្លៃក្រោម ឬស្មើ ៧ម៉ឺនដុល្លា |
| ៣ | លើកលែងការយកពន្ធលើដីធ្លីមិនបានប្រើប្រាស់ សម្រាប់ដីក្រោម ៥ ហិកតា ក្នុងមួយកន្លែង |
| ៤ | បន្តអនុវត្តរហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៥ ដោយអនុញ្ញាតឱ្យអ្នកជាប់ពន្ធធ្វើការកែតម្រូវលិខិតប្រកាសពន្ធឡើងវិញដោយស្ម័គ្រចិត្ត ដោយមិនជាប់ប្រាក់ពិន័យ (១០%) និងការប្រាក់ (១,៥% ក្នុង១ខែ) ដែលកន្លងមកមានប្រសិទ្ធភាពត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៤ |
| ៥ | បន្តលើកលែងការចុះសវនកម្មដល់កន្លែងសម្រាប់អ្នកជាប់ពន្ធតូច ទាំងក្នុងអំឡុងពេលប្រតិបត្តិការអាជីវកម្មធម្មតា និងក្នុងពេលស្នើសុំបិទអាជីវកម្ម |
| ៦ | បន្តអនុវត្តគោលការណ៍មិនយកពន្ធលើដីកសិកម្ម ដីស្រែជាលក្ខណៈគ្រួសារ ពន្ធនាំចូលសម្ភារៈកសិកម្ម កសិផលកសិកម្ម រួមមាន៖ ដីគ្រប់ប្រភេទ ពូជដំណាំគ្រប់ប្រភេទ បសុឱសថ ចំណីសត្វ ពូជសត្វ គ្រឿងយន្ត និងឧបករណ៍កសិកម្មមួយចំនួន |
| ៧ | ចាត់ទុកជាបន្ទុករដ្ឋនូវអាករលើតម្លៃបន្ថែម ព្រមទាំងព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងអនុញ្ញាតឱ្យរួចកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធលើការទូទាត់ដល់សហគ្រាសដាំដុះ ផលិត និងផ្គត់ផ្គង់ក្នុងស្រុកឬនាំចេញ ផលិតផលកសិកម្មចំនួន ១១មុខ (ស្រូវ អង្ករ ពោត សណ្តែក ម្រេច ដំឡូងមី |

| | |
|---|---|
| | គ្រាប់ស្វាយចន្ទី ដំរកៅស៊ូ មៀនប៉ៃលិន ស្វាយ និងចេក) ការចិញ្ចឹមសត្វ វារីវប្បកម្ម និងផលិតផលដូងប្រេងនៅក្នុងស្រុកដែលជាវត្ថុធាតុដើមផលិតចំណីសត្វ |
| ៨ | បន្តការអនុវត្តរហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៥ នូវការលើកទឹកចិត្តផ្នែកពន្ធដារចំពោះខេត្តសៀមរាបកន្លងមក រួមមាន លើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ វៀរលែងតែ អាករលើតម្លៃបន្ថែម និងអាករលើការស្នាក់នៅ លើកលែងពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំ២០២៣ និងមិនចុះធ្វើសវនកម្មលើអាជីវកម្មក្នុងវិស័យទេសចរណ៍ |
| ៩ | បន្តការអនុវត្តរហូតដល់ដំណាច់ឆ្នាំ២០២៨ នូវការលើកទឹកចិត្តពន្ធដារចំពោះគ្រឹះស្ថានសិក្សាទូទាំងប្រទេស |
| ១០ | រៀបចំសៀវភៅណែនាំស្តង់ដារនីតិវិធីប្រតិបត្តិ (SOP) ចំនួន ៤ ទាក់ទិននឹងប្រភេទការងារ និងប្រភេទពន្ធរវាងមន្ត្រីពន្ធដារនិងមន្ត្រីពន្ធដារ និងរវាងមន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ |
| ១១ | បន្តអភិវឌ្ឍ ធ្វើបច្ចុប្បន្នភាព និងធ្វើកំណែប្រែលើប្រព័ន្ធ និងកម្មវិធីរបស់អគ្គនាយកដ្ឋានពន្ធដារ |
| ១២ | ពង្រឹងការអនុវត្តការងារប្រមូលចំណូលពន្ធដែលកំណត់ដោយនាយកដ្ឋានសវនកម្មសហគ្រាស |
| ១៣ | ពង្រឹងការរៀបចំ (Budget Strategic Plan - BSP) របស់អគ្គនាយកដ្ឋានពន្ធដារ ស្របតាមផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ |
| ១៤ | រៀបចំសេចក្តីពិពណ៌នាមុខតំណែង និងលក្ខខណ្ឌការងាររបស់មន្ត្រីរាជការពន្ធដារ |
| ១៥ | ចុះពិនិត្យផ្ទាំងផ្សព្វផ្សាយតាមដងផ្លូវ ក្នុងរាជធានីភ្នំពេញ ឱ្យបានចំនួន ១៤ខណ្ឌ |
| ១៦ | រៀបចំបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជូនអ្នកជាប់ពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជនទូទៅ |

| | |
|---|---|
| ១៧ | រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីបទប្បញ្ញត្តិស្តីពីពន្ធដារជូនអ្នកជាប់ពន្ធ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា |
| ១៨ | រៀបចំបណ្តុះបណ្តាលច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជូនមន្ត្រីរាជការពន្ធដារទូទាំងប្រទេស |
| ១៩ | ពង្រឹងសមត្ថភាពមន្ត្រីលើការប្រើប្រាស់ប្រព័ន្ធ-កម្មវិធីរបស់អគ្គនាយកដ្ឋានពន្ធដារ និងមន្ត្រីជំនាញបច្ចេកវិទ្យាព័ត៌មានតាមរយៈការបណ្តុះបណ្តាល |
| ២០ | បង្កើនភាពងាយស្រួលក្នុងការប្រើប្រាស់សេវាអេឡិចត្រូនិក សម្រាប់ការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ |
| ២១ | រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជូនអ្នកជាប់ពន្ធ |
| ២២ | បន្តរៀបចំសិក្ខាសាលាស្តីពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជូនអ្នកជាប់ពន្ធដែលចុះបញ្ជីថ្មី |
| ២៣ | បន្តរៀបចំវគ្គបណ្តុះបណ្តាលជូនសាធារណជនអំពីជំនាញពន្ធដារ |
| ២៤ | បន្តបញ្ជ្រាបការយល់ដឹងពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងអត្ថប្រយោជន៍នៃការបង់ពន្ធនៅតាមបណ្តាវិទ្យាល័យ និងសាកលវិទ្យាល័យ |
| ២៥ | បន្តរៀបចំការផ្សព្វផ្សាយពីការប្រើប្រាស់ប្រព័ន្ធ និងកម្មវិធីរបស់អគ្គនាយកដ្ឋានពន្ធដារ |
| ២៦ | បន្តផ្សព្វផ្សាយគោលនយោបាយ និងបទប្បញ្ញត្តិស្តីពីពន្ធដារ តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម (ដូចជា Facebook Telegram...) |
| ២៧ | បន្តរៀបចំកម្មវិធី "ពន្ធដារកម្ពុជា-GDT Cambodia" ដែលធ្វើការផ្សាយផ្ទាល់តាមរយៈ Facebook Page ផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ |
| ២៨ | បន្តដោះស្រាយរាល់ចម្ងល់ និងបញ្ហាផ្សេងៗរបស់អ្នកជាប់ពន្ធដែលមានលក្ខណៈស្មុគស្មាញឱ្យបានឆាប់រហ័សតាមរយៈក្រុមគ្រូបង្គោល |

| | |
|---|---|
| ២៩ | បន្តដោះស្រាយរាល់ចម្ងល់ និងបញ្ហានានារបស់អ្នកជាប់ពន្ធតាមរយៈកម្មវិធី GDT Live Chat, Call Center 1277, Facebook, Telegram |
| ៣០ | បន្តរៀបចំកម្មវិធីជួបពិភាក្សាជាប្រចាំជាមួយវិស័យឯកជន |
| ៣១ | បន្តចូលរួមក្នុងវេទិកា/សិក្ខាសាលា/កម្មវិធី ពាក់ព័ន្ធនឹងពន្ធដារ ដែលរៀបចំដោយវិស័យឯកជន ឬស្ថាប័នផ្សេងទៀត |
| ៣២ | ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ ការចែករំលែកព័ត៌មាន និងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ៣៣ | រៀបចំស្ទង់មតិអំពីកម្រិតនៃភាពពេញចិត្តអ្នកជាប់ពន្ធ (Satisfaction survey) លើការផ្តល់សេវា ដើម្បីកែលម្អសេវាអ្នកជាប់ពន្ធ |
| ៣៤ | រៀបចំលិខិតបទដ្ឋានគតិយុត្តថ្មីៗ ដើម្បីឆ្លើយតបទៅនឹងច្បាប់ស្តីពីសារពើពន្ធ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធដារ ស្របតាមគោល-នយោបាយរបស់រាជរដ្ឋាភិបាល |
| ៣៥ | ពង្រឹង និងជំរុញការចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធនៅក្នុងប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីពន្ធដារ |
| ៣៦ | ពង្រឹងយន្តការការងារកៀរសហគ្រាសចេញពីប្រព័ន្ធគ្រប់គ្រងអ្នកជាប់ពន្ធ |
| ៣៧ | ជំរុញការចុះបញ្ជីអចលនទ្រព្យ និងពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ |
| ៣៨ | ពង្រឹងការងារចាត់ចែងលិខិតប្រកាស |
| ៣៩ | ជំរុញការប្រកាសពន្ធតាមអនឡាញដើម្បីអភិវឌ្ឍប្រព័ន្ធពន្ធដារកម្ពុជាឱ្យក្លាយជារដ្ឋបាលសារពើពន្ធឌីជីថល |

| | |
|---|---|
| ៤០ | ពង្រឹងយន្តការត្រួតពិនិត្យការដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធអនឡាញ (e-Filing GDT Tax Prefiling App និង TOI e-Filing) |
| ៤១ | ពង្រឹងនីតិវិធីនៃការស្នើសុំផ្អាកដំណើការសកម្មភាពអាជីវកម្មជាបណ្តោះអាសន្ន ឬបើកដំណើរការសកម្មភាពអាជីវកម្មឡើងវិញ |
| ៤២ | ពង្រឹងការត្រួតពិនិត្យឯកសារវិភាគហានិភ័យទូទៅរបស់សហគ្រាស |
| ៤៣ | ពង្រឹងការអនុវត្តច្បាប់លើអ្នកជាប់ពន្ធដែលមានអនុលោមភាពទាប |
| ៤៤ | បន្តពង្រឹងការគ្រប់គ្រងប្រមូលបំណុលពន្ធ កំណត់បំណុលពន្ធជាអាទិភាពដែលអាចប្រមូលបានតាមរយៈការធ្វើចំណាត់ថ្នាក់បំណុលពន្ធ |
| ៤៥ | បន្តពង្រឹងការអនុវត្តវិធានការទារ និងតឹងទារបំណុលពន្ធ |
| ៤៦ | ពង្រឹង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធបណ្តាញ និងសេវូបករណ៍ |
| ៤៧ | ថែទាំឧបករណ៍បច្ចេកវិទ្យាគាំទ្រដល់មជ្ឈមណ្ឌលទិន្នន័យទី១ មជ្ឈមណ្ឌលទិន្នន័យទី២ និងមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ |
| ៤៨ | ពង្រឹងការគ្រប់គ្រងឧបករណ៍បច្ចេកវិទ្យាព័ត៌មាននៅតាមអង្គភាពក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ |
| ៤៩ | ពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធគាំទ្រសេវាកម្មបច្ចេកវិទ្យាព័ត៌មាន (Helpdesk System) ដើម្បីកាត់បន្ថយឱ្យបានជាអតិបរមានូវការប្រើប្រាស់នីតិវិធីរដ្ឋបាល |
| ៥០ | ធ្វើឱ្យប្រសើរឡើងនូវរាល់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ |

| | |
|---|---|
| ៥១ | សហការ និងត្រៀមលក្ខណៈបច្ចេកទេសរៀបចំសន្ធានកម្មដើម្បីចែករំលែកទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នដទៃ |
| ៥២ | បន្តធ្វើបច្ចុប្បន្នភាព និងធ្វើកំណែប្រែលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ |
| ៥៣ | ធានាឱ្យបាននូវការរក្សា សង្គ្រោះ និងទាញយកទិន្នន័យឱ្យមាននិរន្តរភាព (Backup and restore) |
| ៥៤ | រៀបចំ និងដាក់ឱ្យអនុវត្តផែនការបណ្តុះបណ្តាល របស់អគ្គនាយកដ្ឋានពន្ធដារ |
| ៥៥ | រៀបចំផ្សព្វផ្សាយ ចែករំលែក និងបណ្តុះបណ្តាលវគ្គបណ្តុះបណ្តាលខ្លីៗដែលមន្ត្រីទទួលបានពីការចូលរួមការបណ្តុះបណ្តាលនៅក្នុងនិងក្រៅប្រទេស |
| ៥៦ | ពង្រឹងការអនុវត្តគោលការណ៍ស្តីពីការគ្រប់គ្រងចាត់ចែងមន្ត្រី (Authorized Staffing Pattern - ASP) ស្របតាមជំនាញ ទំហំ និងតម្រូវការជាក់ស្តែងនៃការងាររបស់អង្គភាពពន្ធដារ |
| ៥៧ | ពង្រឹងការអនុវត្តប្រព័ន្ធកំណត់ចំណាត់ថ្នាក់នៃកម្រិតប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ប្រធានអង្គភាព (Merit & Demerit System - MDS) |
| ៥៨ | ត្រួតពិនិត្យ ធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិការងារ (Standard Operating Procedures - SOP) របស់អង្គភាពពន្ធដារ |
| ៥៩ | រៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីនិយាមនីតិវិធីប្រតិបត្តិការងារ (SOP Booklets) សម្រាប់ផ្សព្វផ្សាយជូនអ្នកជាប់ពន្ធ |
| ៦០ | បង្កើនប្រសិទ្ធភាព និងសុក្រឹតភាពព័ត៌មានមន្ត្រីតាមរយៈការធ្វើបច្ចុប្បន្នភាពទិន្នន័យនៅក្នុងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស |

| | |
|---|---|
| ៦១ | ពិនិត្យលទ្ធភាពលើការពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ |
| ៦២ | រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធដារតាមរយៈការជ្រើសរើសអង្គភាពពន្ធដារដែលមានហានិភ័យខ្ពស់ |
| ៦៣ | រៀបចំផែនការសកម្មភាពកែលម្អស្របតាមអនុសាសន៍សវនកម្មផ្ទៃក្នុង ចំពោះអង្គភាពដែលរងសវនកម្មផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានពន្ធដារ |
| ៦៤ | តាមដាន និងជំរុញអង្គភាពពន្ធដារឱ្យកែលម្អតាមអនុសាសន៍សវនកម្មរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ |
| ៦៥ | រៀបចំវគ្គបណ្តុះបណ្តាលស្តីពីថវិកាសមិទ្ធកម្ម |
| ៦៦ | រៀបចំផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិលរបស់អគ្គនាយកដ្ឋានពន្ធដារ |
| ៦៧ | រៀបចំកញ្ចប់ថវិកាសមិទ្ធកម្មប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធដារ |
| ៦៨ | សិក្សារៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធបេសកកម្ម |
| ៦៩ | ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីធៀបជាមួយនឹងលទ្ធផលការងារជារៀងរាល់ឆមាស និងប្រចាំឆ្នាំ |
| ៧០ | បន្តពង្រឹងការផ្សព្វផ្សាយ និងការអនុវត្តប្រកបដោយការយកចិត្តទុកដាក់នូវវិធានការលើកទឹកចិត្ត និងសម្រួលផ្នែកពន្ធដារជូនវិស័យឯកជននាពេលកន្លងមក |

| | |
|---|---|
| ៧១ | បន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្ត (ប្រកាស សេចក្តីណែនាំ សេចក្តីជូនដំណឹង) ក្នុងការអនុវត្តនូវវិធានការលើកទឹកចិត្ត និងសម្រួលផ្នែកពន្ធដារជូនវិស័យឯកជន ក៏ដូចជាគាំទ្រដល់ច្បាប់ស្តីពីសារពើពន្ធឆ្នាំ២០២៣ |
| ៧២ | បន្តផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ បទប្បញ្ញត្តិស្តីពីពន្ធលើចំណេញមូលធន ការងារកែទម្រង់និងទំនើបកម្មរដ្ឋបាលសារពើពន្ធ និងបន្តពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ ដូចជាការបន្តផ្សព្វផ្សាយ និងពង្រឹងការអនុវត្តវិធានវិក្កយបត្រ និងកម្មវិធីវិក្កយបត្រនាំសំណាង ការរៀបចំកម្មវិធីរៀនអំពីពន្ធដារតាមអនឡាញ សិក្ខាសាលា វិបស្សនាផ្សេងៗ ពិសេសការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" ដោយមានការជួបជជែកជាមួយអ្នកជាប់ពន្ធផ្ទាល់តាមរយៈប្រព័ន្ធបណ្តាញសង្គម GDT Facebook Live និងសេវាឆ្លើយតបតាមរយៈប្រព័ន្ធទូរស័ព្ទ Call Center |
| ៧៣ | បន្តធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធស្របតាមចក្ខុវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការប្រែក្លាយខ្លួនទៅជារដ្ឋបាលសារពើពន្ធទំនើបជំនាន់ ៣.០ (Tax Administration 3.0) |
| ៧៤ | ពង្រឹងការកត់ត្រាបំណុលពន្ធ អនុវត្តការប្រមូលបំណុលពន្ធ និងវិធានការតឹងទារបំណុលពន្ធ ជាពិសេសបំណុលពន្ធធំៗដែលមានសក្តានុពលដោយកំណត់ជាបំណុលអាទិភាព |
| ៧៥ | បន្តការងារកែទម្រង់ និងបណ្តុះបណ្តាលធនធានមនុស្ស ព្រមទាំងបន្តពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពម៉ឺងម៉ាត់តែទន់ភ្លន់ ដោយផ្អែកលើទិដ្ឋភាពច្បាប់ក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធ |
| **II.** | **អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា** |
| ១ | អនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ |
| ២ | លើកលែងការបង់កម្រៃបែបបទគយ (Customs Processing Fee) ចំពោះទំនិញនាំចេញ-នាំចូល ដែលមានតម្លៃក្រោម ១ ០០០ ដុល្លារអាមេរិក និងកាត់បន្ថយកម្រៃប្រតិវេទន៍គយពី ១៥ ០០០ រៀល មក ៨ ០០០ រៀល ក្នុងមួយប្រតិវេទន៍ចំពោះទំនិញនាំចេញ-នាំចូល ដែលមានតម្លៃក្រោម ១ ០០០ ដុល្លារអាមេរិក |

| | |
|---|---|
| ៣ | លើកលែងការបង់កម្រៃស្កែន ចំពោះកុងតឺន័រ ដែលមិនបានឆ្លងកាត់ម៉ាស៊ីនស្កែន |
| ៤ | បន្តធ្វើការងារជាមួយវិស័យឯកជន ក្នុងការកាត់បន្ថយថ្លៃសេវាឡជីស្ទីក តាមរយៈការពិនិត្យឡើងវិញនូវថ្លៃសេវានានា និង ការកាត់បន្ថយ ឬ ការធ្វើសាមញ្ញបនីយកម្មនីតិវិធីគយ ព្រមទាំងការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន |
| ៥ | ជំរុញការអនុវត្តពេញលេញការបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-Arrival Processing) តាមប្រព័ន្ធអេឡិចត្រូនិក |
| ៦ | ដាក់ឱ្យអនុវត្តការបំពេញបែបបទគយចំពោះបញ្ញើប្រៃសណីយ៍ បញ្ញើរហ័សនិងទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន |
| ៧ | ធ្វើស្វ័យប្រវត្តិកម្មពេញលេញនីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងសំអាងដើមកំណើតទំនិញ ក្នុងប្រព័ន្ធប្រតិវេទន៍តម្លៃគិតពន្ធគយ (CVDS) និងតភ្ជាប់ប្រព័ន្ធជាមួយ ASYCUDA តាមរយៈការធ្វើស្វ័យប្រវត្តិកម្មពេញលេញនីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងសំអាងដើមកំណើតទំនិញ ក្នុងប្រព័ន្ធ CVDS ការតភ្ជាប់ប្រព័ន្ធដើម្បីបញ្ជូនដោយស្វ័យប្រវត្តិនូវទិន្នន័យប្រតិវេទន៍តម្លៃគិតពន្ធគយ ការបញ្ជាក់ តម្លៃគិតពន្ធគយ និងការផ្តល់អត្រាពន្ធអនុគ្រោះពីប្រព័ន្ធ CVDS ទៅប្រព័ន្ធ ASYCUDA និងការលើកលែងតម្រូវការបោះពុម្ពលិខិតបញ្ជាក់ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងលិខិតបញ្ជាក់ការផ្ទៀងផ្ទាត់សំអាងដើមកំណើតទំនិញទម្រង់ក្រដាស |
| ៨ | ដាក់ផែនការឆ្លើយតបទៅនឹងការលើកឡើងអំពីថ្លៃចំណាយខ្ពស់ ការប្រើប្រាស់ឯកសារក្នុងទម្រង់រឹង (Hard Copy)ច្រើន និងការជួបគ្នាផ្ទាល់ជាមួយមន្ត្រីច្រើនកន្លែងតាមរយៈការកាត់បន្ថយថ្លៃចំណាយ លើការបំពេញបែបបទបញ្ចេញទំនិញពីគយ និងកែសម្រួលថ្លៃសេវាឱ្យបានសមរម្យឡើងវិញ ការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ឯកសារភ្ជាប់ក្នុងទម្រង់អេឡិចត្រូនិកជាឯកសារផ្លូវការ ការកែសម្រួលនីតិវិធីប្រតិវេទន៍គយក្នុងប្រព័ន្ធ ASYCUDA និងប្រព័ន្ធ E-Customs ដោយជំរុញការប្រើប្រាស់ឯកសារទម្រង់អេឡិចត្រូនិក និងកាត់បន្ថយឯកសារជាក្រដាស និងការពង្រឹងយន្តការច្រកចេញ-ចូលតែមួយនៅការិយាល័យគយ ដោយកាត់បន្ថយនីតិវិធី និងការជួបគ្នាផ្ទាល់ជាមួយមន្ត្រី |
| ៩ | ជំរុញ និងបញ្ចប់ការអនុវត្តប្រព័ន្ធបញ្ចរតែមួយជាតិ (National Single Window) ដំណាក់កាលទី៣ |
| ១០ | កាត់បន្ថយការត្រួតពិនិត្យទំនិញនាំចេញឱ្យនៅក្រោម ១០% ព្រមទាំងលើកលែងការបង់កម្រៃស្កែន ចំពោះកុងតឺន័រដែលមិនបានឆ្លងកាត់ម៉ាស៊ីនស្កែន |

| | |
|---|---|
| ១១ | បន្តជំរុញការបណ្តុះបណ្តាល និងការផ្តល់អាជ្ញាបណ្ណជើងសារគយផ្តល់សេវាធ្វើការបន្ថែមម៉ោងរបស់មន្ត្រីគយនៅពេលយប់នៅតាមផែស្ងួតដោយរៀបចំការកំណត់ប្រាក់ម៉ោងឱ្យបានសមរម្យ ដើម្បីពន្លឿនការនាំចេញ |
| ១២ | បន្តជំរុញការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ( AEO ) និងកែលម្អប្រព្រឹត្តកម្មលើកទឹកចិត្តសម្រាប់ធុរជនល្អបំផុត ( Best Traders ) |
| ១៣ | ពង្រឹងការគ្រប់គ្រងលើការនាំចូលសាច់ជ្រូកបង្កក មាន់ ស៊ុត និងត្រី ខុសច្បាប់ តាមរយៈការសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ពង្រឹងឱ្យបានម៉ត់ចត់បំផុតនូវការហាមនាំចូលម្ហូប ឬចំណីអាហារណាដែលខូចគុណភាពឬគុណភាពទាប កំណត់ច្រកទ្វារព្រំដែនដែលអនុញ្ញាតឱ្យមានការនាំចូលសាច់ជ្រូកបង្កក មាន់ ស៊ុត និងត្រី ធ្វើវិសោធនកម្ម អនុក្រឹត្យលេខ ១៧ អនក្រ.បក ដើម្បីតម្រូវឱ្យមានការស្នើសុំលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជំរុញកិច្ចសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រើប្រាស់ប្រព័ន្ធបញ្ជរតែមួយជាតិ ( National Single Window ) សម្រាប់សម្រួលដល់ការស្នើសុំលិខិតអនុញ្ញាតឱ្យបានលឿន |
| ១៤ | ធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១២ អនក្រ.បក ដោយសហការជាមួយវិស័យឯកជន ដើម្បីកំណត់លើមធ្យមភាគ និងរូបមន្តមូលដ្ឋានគិតពន្ធជ័រកៅស៊ូនាំចេញរបស់កម្ពុជា ដើម្បីឱ្យកាន់តែមានភាពប្រាកដនិយម |
| ១៥ | កែលម្អគោលនយោបាយពន្ធនិងអាករឱ្យសមស្របតាមការវិវឌ្ឍនៃសេដ្ឋកិច្ចនិងសង្គម |
| ១៦ | បណ្តុះវប្បធម៌នៃការបង់ពន្ធត្រឹមត្រូវ និងតម្លាភាពនៃការផ្តល់សេវាសាធារណៈតាមរយៈការបង្កើតយន្តការឆ្លើយតបបញ្ហាពាក់ព័ន្ធនឹងការងារគយ |
| ១៧ | ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការត្រួតពិនិត្យដោយបច្ចេកវិទ្យាត្រួតពិនិត្យតាមរយៈការពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកបច្ចេកវិទ្យាត្រួតពិនិត្យ |
| ១៨ | ធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីគយតាមរយៈការដាក់អនុវត្តនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ និងការរៀបចំលិខិតបទដ្ឋានគតិយុត្ត/នីតិវិធីគាំទ្រការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ |

| | |
|---|---|
| ១៩ | ពង្រឹងកិច្ចសហប្រតិបត្តិការគយតាមរយៈការបន្តពង្រឹងកិច្ចសហប្រតិបត្តិការគយជាមួយអាជ្ញាធរដែនដីនិងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត, ការបន្តពង្រឹងការអនុវត្តកិច្ចសហប្រតិបត្តិការគយទ្វេភាគី តំបន់ និងពហុភាគី និងការចែករំលែក និងផ្លាស់ប្តូរព័ត៌មានចារកម្មគយក្នុងក្របខ័ណ្ឌ WCO ( CEN CENComm  RILO Networks ) ASEAN ( ANS ) ASEM ( OLAF ) ។ល។ |
| ២០ | ពង្រឹងប្រសិទ្ធភាពការងារសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយតាមរយៈការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីលើការងារសវនកម្ម |
| ២១ | ពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងជើងសាគយនិង/ឬប្រតិវេទករតាមរយៈបណ្តុះបណ្តាលជើងសាគយ/ប្រតិវេទករ លើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគយ និងការរៀបចំការប្រឡងជ្រើសរើសជើងសាគយ |
| ២២ | ពង្រឹងការងារស៊ើបអង្កេតបទល្មើសគយតាមរយៈការបណ្តុះបណ្តាលជំនាញស៊ើបអង្កេតបទល្មើសគយដល់មន្ត្រីគយ |
| ២៣ | គ្រប់គ្រងទិន្នន័យ និងស្ថិតិដោយធ្វើវិសិដ្ឋកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យនិងស្ថិតិ និងប្រើប្រាស់បច្ចេកវិទ្យាថ្មីសម្រាប់រៀបចំ និងវិភាគទិន្នន័យ ( Python Machine Learning AI ) |
| ២៤ | អភិវឌ្ឍ និងពង្រីកមុខងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយអភិវឌ្ឍមុខងារគ្រប់គ្រងសន្និធិគយបណ្តោះអាសន្ន, រៀបចំបង្កើតបណ្ណាល័យអេឡិចត្រូនិកធ្វើសមាហរណកម្មមុខងារប្រតិវេទន៍គយសង្ខេបក្នុងប្រព័ន្ធអាស៊ីគូដា ពង្រីកមុខងារ និងវិសាលភាពប្រព័ន្ធបញ្ជរតែមួយជាតិ, ពង្រីកមុខងារ និងវិសាលភាពប្រព័ន្ធបញ្ជរតែមួយអាស៊ាន អភិវឌ្ឍមុខងារប្រើប្រាស់ឯកសារប្រតិវេទន៍គយអាស៊ាន ( ACDD ) រៀបចំមុខងារប្រព័ន្ធដើម្បីគាំទ្រការអនុវត្តនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ សម្រាប់កញ្ចប់បញ្ញើប្រៃសណីយ៍ កញ្ចប់បញ្ញើរហ័ស តាមផ្លូវទឹក និងផ្លូវគោក ជាដើម |
| ២៥ | ពង្រឹងសមត្ថភាពគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ និងសុវត្ថិភាពប្រព័ន្ធដោយពង្រីកសមត្ថភាពមជ្ឈមណ្ឌលទិន្នន័យទៅជាមជ្ឈមណ្ឌលស្តង់ដារ Tier III ( DATA Center Tier III Standard ) និងប្រើប្រាស់បច្ចេកវិទ្យាថ្មីសម្រាប់រៀបចំ និងពង្រឹងសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធ ( Desktop Workspaces - DaaS ZTNA ... ) |

| | |
|---|---|
| ២៦ | គ្រប់គ្រងធនធានមនុស្ស តាមរយៈការគ្រប់គ្រងមន្ត្រីគយ និងរដ្ឋាករតាមប្រព័ន្ធបច្ចេកវិទ្យា និងការត្រួតពិនិត្យការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់អង្គភាពគយ និងរដ្ឋាករ |
| ២៧ | អភិវឌ្ឍធនធានមនុស្សតាមរយៈការអនុវត្តផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសគយ និងជំនាញពាក់ព័ន្ធ |
| ២៨ | លើកកម្ពស់សមត្ថភាពការងារតាមរយៈការវាយតម្លៃសមិទ្ធកម្មការងារដើម្បីផ្តល់ការលើកទឹកចិត្ត ឬដាក់ទណ្ឌកម្ម |
| ២៩ | លើកកម្ពស់សុចរិតភាព និងប្រឆាំងអំពើពុករលួយតាមរយៈការពង្រឹងការអនុវត្តការទទួលព័ត៌មានត្រឡប់ និងទទួលពាក្យបណ្តឹង និងចុះធ្វើសវនកម្មផ្ទៃក្នុងតាមអង្គភាពគយនិងរដ្ឋាករ |
| ៣០ | កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបំពាក់មធ្យោបាយបំពេញការងារតាមរយៈការសិក្សាលទ្ធភាពបង្កើតមន្ទីរពិសោធន៍គយ |
| ៣១ | ពង្រឹងប្រសិទ្ធភាពលើការត្រួតពិនិត្យផ្ទៀងផ្ទាត់ឯកសារ និងការត្រួតពិនិត្យរូបវន្តតាមរយៈការពង្រឹងការផ្ទៀងផ្ទាត់ឯកសារប្រកាសតម្លៃគិតពន្ធគយ, ចំណាត់ថ្នាក់ទំនិញ ដើមកំណើតទំនិញ និងឯកសារពាក់ព័ន្ធ និងការជ្រើសរើសឯកសារដើម្បីស្នើសុំធ្វើការត្រួតពិនិត្យរូបវន្តនៅពេលធ្វើបែបបទបញ្ចេញទំនិញពីគយជាក់ស្តែង |
| ៣២ | ពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យដោយម៉ាស៊ីនស្កែន តាមរយៈការជ្រើសរើសកុងតឺន័រឆ្លងកាត់ចូលតំបន់សេដ្ឋកិច្ចពិសេសដើម្បីត្រួតពិនិត្យដោយម៉ាស៊ីនស្កែន ដោយផ្អែកលើសូចនាករហានិភ័យ និងគោលការណ៍ត្រួតពិនិត្យចោះៗ ការត្រួតពិនិត្យដោយម៉ាស៊ីនស្កែនផ្អែកលើសូចនាករហានិភ័យ និងចំពោះកុងតឺន័រដែលបានជ្រើសរើសឱ្យឆ្លងកាត់ម៉ាស៊ីនស្កែន និងការកំណត់សូចនាករសមិទ្ធផលជាក់លាក់តាមម៉ាស៊ីនស្កែននីមួយៗ ព្រមទាំងចាត់មន្ត្រីទទួលបន្ទុកតាមដាននិងជំរុញការអនុវត្ត |
| ៣៣ | បង្កើនសកម្មភាពត្រួតពិនិត្យអនុលោមភាពនៅកណ្តាលទី និងចុងទីតាមរយៈការបង្កើនសកម្មភាពត្រួតពិនិត្យអនុលោមភាពនៅកណ្តាលទីផ្អែកតាមសូចនាករហានិភ័យដែលបានកំណត់ ការត្រួតពិនិត្យអនុលោមភាពអាជីវកម្មដ្ឋាន និងឃ្លាំងស្តុកទំនិញមានវេទយិតភាព ផ្អែកតាមមុខសញ្ញាហានិភ័យ និងការត្រួតពិនិត្យអនុលោមភាពរថយន្តផ្ទុកទំនិញនាំចូលនៅពេលមកដល់ភូមិសាស្ត្ររាជធានីភ្នំពេញ ផ្អែកតាមមុខសញ្ញាហានិភ័យ |

| | |
|---|---|
| ៣៤ | ពង្រឹងការគ្រប់គ្រងការនាំចូល និងចែកចាយប្រេងឥន្ធនៈនិងហ្គាសទាំងលើដីគោក និងផ្ទៃសមុទ្រតាមរយៈការបង្កើនសកម្មភាពត្រួតពិនិត្យអនុលោមភាព និងបង្ក្រាបសកម្មភាពចរាចរចែកចាយផលិតផលតេលសិលាដែលចេញក្រៅផ្ទៃសមុទ្រមកដល់ដីគោក |
| ៣៥ | ពង្រឹងវិន័យការងារនិងក្រមសីលធម៌វិជ្ជាជីវៈ និងចាត់វិធានការតឹងរឹងខាងវិន័យចំពោះមន្ត្រីគយនិងរដ្ឋាករដែលបានបង្កបាតុភាពអសកម្ម |
| ៣៦ | ឃ្លាំមើលនិងចុះល្បាតតាមភូមិសាស្ត្រមានវេទយិតភាពខ្ពស់ចំពោះបទល្មើសគយ |
| III. | **អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ** |
| ១ | ជំរុញឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធរៀបចំកិច្ចប្រជុំប្រចាំត្រីមាសឬប្រចាំឆ្នាំ |
| ២ | ពង្រឹងយន្តការផ្តល់ព័ត៌មាននិងទិន្នន័យច្បាស់លាស់ |
| ៣ | ពិនិត្យឡើងវិញលើការអនុវត្តច្បាប់ទៅតាមមុខងារអនុវត្ត |
| ៤ | កំណត់ទោសទណ្ឌនិងការទទួលខុសត្រូវ |
| ៥ | ពង្រឹងភាពម្ចាស់ការនិងការទទួលខុសត្រូវរបស់អង្គភាពទទួលបន្ទុក |
| ៦ | បង្កើតនិងធ្វើបច្ចុប្បន្នភាពគោលនយោបាយ ដើម្បីពង្រឹងគណនេយ្យភាពតាមរយៈការរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយនូវលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យសំខាន់ៗ |
| ៧ | ពង្រឹងការយកចិត្តទុកដាក់ក្នុងការប្រមូលធាតុចូលនិងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមរបស់វិស័យឯកជន តាមរយៈវេទិការដ្ឋាភិបាលជាមួយឯកជន |

| | |
|---|---|
| ៨ | បែងចែកសមត្ថកិច្ចគ្រប់គ្រង និងប្រមូលចំណូលសេវាសាធារណៈរបស់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ការផ្ទេរមុខងារពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យថ្នាក់ក្រោមជាតិ) និងសិក្សា និងពិនិត្យលទ្ធភាពរៀបចំប្រព័ន្ធបច្ចេកវិទ្យា សម្រាប់ការផ្តល់សេវាតាមប្រព័ន្ធអនឡាញ |
| ៩ | ជំរុញការរៀបចំផែនការនៃការតឹងទារបំណុលមិនមែនសារពើពន្ធ ផ្អែកតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន |
| ១០ | ធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល |
| ១១ | ពង្រឹងការគ្រប់គ្រងនិងការអនុវត្តលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល |
| ១២ | ជំរុញយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ |
| ១៣ | ពង្រឹងនិងកសាងសមត្ថភាពតាមរយៈការផ្សព្វផ្សាយនិងការបណ្តុះបណ្តាល |
| ១៤ | ពិនិត្យនិងរៀបចំយន្តការឱ្យបានច្បាស់លាស់ក្នុងការគ្រប់គ្រងលើប្រភពចំណូលមួយចំនួនដែលពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រង |
| ១៥ | សិក្សាស្រាវជ្រាវស្វែងរកប្រភពចំណូលថ្មីឱ្យអស់លទ្ធភាព សមស្របតាមស្ថានភាពសេដ្ឋកិច្ច |
| ១៦ | ជំរុញការប្រើប្រាស់និងបន្តអភិវឌ្ឍលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) |
| ១៧ | ជំរុញការប្រើប្រាស់និងបន្តអភិវឌ្ឍលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS) |
| ១៨ | ជំរុញការប្រើប្រាស់ e-Payment |

| | |
|---|---|
| ១៩ | ជំរុញការធ្វើសន្ទានកម្មប្រព័ន្ធ NRMIS និងប្រព័ន្ធ SARMIS ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាពិសេសប្រព័ន្ធ FMIS និងប្រព័ន្ធក្រសួង-ស្ថាប័នផ្សេងទៀត |
| ២០ | ពង្រឹងសមត្ថភាពតាមមូលដ្ឋានតាមរយៈការបណ្តុះបណ្តាលនិងផ្សព្វផ្សាយ |